ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




## មជ្ឈមណ្ឌល ឯកសារខេត្តកំពង់ចាម

- កញ្ញា ប៊ូ សំណាង គឺជាការសន្យា និងសេចក្ដីសង្ឃឹមថ្មីសម្រាប់កម្ពុជា
- មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលប័ណ្ណសរសើរពីរដ្ឋបាលខេត្តកំពង់ចាម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខពិសេស ឆ្នាំ២០២៣

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

លេខពិសេស ឆ្នាំ២០២៣

## មាតិកា

### ផ្នែកសំបុត្រ


- កញ្ញា ប៊ូ សំណាង គឺជាការសន្យា និង.......... ១
- មជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលប័ណ្ណសរសើរពីរដ្ឋបាលខេត្តកំពង់ចាម ...................... ២


### ផ្នែកឯកសារ


- អៀត ប៊ុនលី ៖ សមាជិកសន្តិសុខឃុំចក ...... ៤


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ជួបប្រជុំពិភាក្សាជាមួយអាជ្ញាធរស្រុកកំពង់សៀម ... ៧
- ការអប់រំពីបញ្ហាសុខភាពផ្លូវចិត្តដល់អ្នករស់ .. ៩
- គម្រោងសូត្រចាមរបស់មជ្ឈមណ្ឌល........ ១២
- ពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប.. ១៥
- មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមរៀបចំពិធីបង្សុកូលឧទ្ទិសកុសលដល់ជនរងគ្រោះ .... ១៩
- រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងស្រុកកំពង់សៀម ........... ២១
- ឯកអគ្គរដ្ឋទូតហ្វីលីពីនប្រចាំកម្ពុជា ទស្សនកិច្ចមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម ........២៨
- ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ........................៣០
- ស្ងួះ ហានីហ្វុះ ៖ គ្រួសារខ្ញុំគឺជាអ្នកតម្បាញ...៣៣
- ម៉ៅ វណ្ណា ៖ ខ្ញុំនៅចាំពាក្យសម្ដីរបស់មិត្ត ថាច.. ៣៥
- ឡៀន គីមសាន ៖ អតីតប្រធានក្រុម .........៣៨
- ជា ខេងថៃ ៖ ប្រធានមន្ទីរពាណិជ្ជកម្ម.........៤០
- ទូទ័ល សារ៉ាស់៖ អ្នកត្បាញក្រមាឲ្យអង្គការ .. ៤៣
- ស្រេង ស៊ីថា ៖ ខ្មែរក្រហមសម្លាប់ .......... ៤៥




កញ្ញា ប៊ូ សំណាង គឺអត្តពលិកក្នុងវិញ្ញាសារត់ចម្ងាយ ៥០០០ម៉ែត្រ កីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ កាលពីថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣។
( Đức Đồng - VnExpress/មជ្ឈមណ្ឌលឯកសារកម្ពុជា )

### ផ្នែកវេទិកាពិភាក្សាសាធារណៈ


- វេទិកាអប់រំអំពីការថែទាំសុខភាព និងពិនិត្យសុខភាពជូនជនពិការ ដែលរស់រានមាន .... ៤៨
- ការចងចាំអំពីជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ក្នុងពិធីបុណ្យដាលាន...... ៥១
- វេទិកាប្រវត្តិសាស្ត្រ និងសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការនៅស្រុកកោះសូទិន........................... ៥៣
- សិស្សវិទ្យាល័យ សម្ដេចតេជោ ហ៊ុនសែនសង្កើបចូលរួមវេទិកាថ្នាក់រៀនចុងសប្ដាហ៍ .........៥៧


### ផ្នែកស្រាវជ្រាវរកគ្រួសារ


- កូប ហ្វាទីម៉ះ៖ របបខ្មែរក្រហមធ្វើឲ្យខ្ញុំក្លាយជាកូនកំព្រា និងជាស្ត្រីមេម៉ាយ .................. ៦០


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, សោម ប៊ុនថន, កែវ សុភី, អេង វណ្ណីកា, គីម សុវណ្ណដានី, មីន សាណាស់, ទូច វណ្ណេត, ស៊ាង ចិន្ដា, សុខ វណ្ណៈ និង លី ដេវីត
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាក ចាន់សុនិតា **អ្នកបកប្រែ៖** លឹម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# កញ្ញា ប៊ូ សំណាង គឺជាការសន្យា និង សេចក្តីសង្ឃឹមថ្មីសម្រាប់កម្ពុជា

**ឆាំង យុ**




*កញ្ញា ប៊ូ សំណាង គឺអត្តពលិកក្នុងវិញ្ញាសារត់ចម្ងាយ ៥០០០ម៉ែត្រ កីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ កាលពីថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣។ (Đức Đồng - VnExpress/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

"ស្ថិតនៅក្រោមភ្លៀងធ្លាក់ជោគជាំ កញ្ញានៅតែរត់បន្ត ថ្វីត្បិតតែមកដល់ទីចុងក្រោយគេបង្អស់យ៉ាងណាក្តី នាងក្តោបបានការចាប់អារម្មណ៍យ៉ាងខ្លាំង ដោយមនុស្សម្នាជាច្រើនងឿងឆ្ងល់ថាតើនាងកំពុងគិតអំពីអ្វីៗ តាមរយៈទឹកភ្នែករបស់នាង ក្រោមភ្លៀងមូសុង ដែលកំពុងបង្អុរចុះជោគជាំ យើងចាប់ផ្តើមមើលឃើញកាន់តែច្បាស់នូវរូបភាពប្រជាជាតិកម្ពុជាមួយ សម្រាប់ប្រជាជនកម្ពុជាគ្រប់រូបៗ នោះគឺជាប្រជាជាតិមួយដែលយើងចែករំលែកសេចក្តីស្រឡាញ់ស្មើៗគ្នា។ ខ្ញុំមិនបានយំតាមនាងទេ ក៏ប៉ុន្តែបេះដូងខ្ញុំៗ មើលឃើញអំពីការរត់របស់នាង អមជាមួយនឹងទឹកភ្នែកស្រក់ចុះលើផ្ទៃមុខនេះគឺអាចចាត់ទុកថាជាខណៈពេលបន្ទូរអារម្មណ៍មួយ សម្រាប់ប្រជាជនកម្ពុជាទាំងអស់ ក្នុងការរំសាយបោលនូវរាល់សោកនាដកម្មនៃសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ដែលបានស្ថិតនៅអន្ទោលតាមយើងអស់រយៈកាលរាប់ទសវត្សរ៍កន្លងមកហើយ។ អារម្មណ៍របស់នាង គួបផ្សំជាមួយនឹងភ្លៀងមូសុង អាចចាត់ទុកថាជាការបង្កើតការសន្យា និងសេចក្តីសង្ឃឹមថ្មីមួយ សម្រាប់កម្ពុជា ដែលបន្ទាប់ពីភាពសោកសៅ អត្តពលិករត់ប្រណាំងមា ឧតូចមួយរូបនេះ ប្រៀបដូចទៅនឹងប្រទេសកម្ពុជាដ៏តូចមួយនេះដែរ អាចកសាងសេចក្តីសង្ឃឹមជាថ្មីឈានទៅកាន់ថ្ងៃស្អែកដ៏ប្រសើរ និងត្រចះត្រចង់"។

**ឆាំង យុ**

*អ្នករស់រានមានជីវិតម្នាក់ពីរបបខ្មែរក្រហម និងជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា*

# មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលប័ណ្ណសរសើរពីរដ្ឋបាលខេត្តកំពង់ចាម

**សោម ចិន្តា**



នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម អ៊ុន ចាន់ដា អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ប្រគល់ប័ណ្ណសរសើរជូនលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម តំណាងឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារ ឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម អ៊ុន ចាន់ដា អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ប្រគល់ប័ណ្ណសរសើរជូនលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម តំណាងឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារ ឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកំពង់ចាម។ នៅក្នុងឱកាសនោះ ឯកឧត្តម អ៊ុន ចាន់ដា ក៏បានរំឭកឡើងវិញអំពីប្រជាជនដែលធ្វើការងារនៅតាមវាលស្រែ ទំនប់ និងប្រឡាយគ្មានពេលសម្រាក នៅក្នុងរបបខ្មែរក្រហម ដែលបណ្ដាលឲ្យប្រជាជនបាក់កម្លាំង ដែលទាំងនេះយើងត្រូវចងចាំ។

មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម គឺជាសាខាមួយក្នុងចំណោមសាខាទាំង៦របស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមមាន ១) មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ២) មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ៣) មជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ ៤) មជ្ឈមណ្ឌលឯកសារ កោះធ្ម ៥) មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ៦) មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។

មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានដើរតួ

នា ទីជាមជ្ឈមណ្ឌលស្រាវជ្រាវសម្រាប់សិស្សនិស្សិត អ្នកស្រាវជ្រាវ និងសាធារណជនជាពិសេសអ្នកដែលរស់នៅក្នុងខេត្តកំពង់ចាម។ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមមានគោលបំណងផ្តល់នូវប្រភពធនធានសម្បូរបែប ទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីលើកកម្ពស់ការយល់ដឹង និងចំណេះដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមក្នុងចំណោមប្រជាជនដែលរស់នៅក្នុងខេត្តកំពង់ចាម។ បណ្ណសារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រួមមាន ឯកសារចម្លើយ សារភាពសក្ខីកម្មរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ខ្សែភាពយន្ត និងរូបថត។

មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តអនុវត្តកិច្ចការងារស្នូលរបស់ខ្លួននៅតាមមូលដ្ឋាន ក្នុងការចងក្រងឯកសារ អប់រំ និងផ្សព្វផ្សាយស្តីអំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលគ្រប់គ្រងប្រទេសកម្ពុជាចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

ចាប់តាំងពីមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមបង្កើតឡើងជាផ្លូវការនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ មជ្ឈមណ្ឌលនេះបានបើកទទួលសាធារណជន អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គណៈប្រតិភូ គ្រូបង្រៀន សិស្សានុសិស្ស និង យុវជន រាប់ពាន់នាក់ ដែលមកទស្សនកិច្ច និងសិក្សាស្រាវជ្រាវ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
រដ្ឋបាលខេត្តកំពង់ចាម
បណ្ណសរសើរ
អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម
សូមសរសើរចំពោះ
អង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា
ដែលមានកិច្ចសហប្រតិបត្តិការល្អជាមួយនឹងរដ្ឋបាលខេត្ត
ក្នុងការផ្តល់សេវាសង្គមនានា សម្រាប់ឆ្នាំ២០២២។
ថ្ងៃ.សុក្រ..៤..រោច.....ខែ.ផល្គុន...ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
កំពង់ចាម ថ្ងៃទី..១០...ខែ..មីនា........ឆ្នាំ២០២៣
អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម
អ៊ុន_ចាន់ដា
យោងសេចក្តីសម្រេចលេខ: ០៣៩/២៣ ស.ស.រ
ចុះថ្ងៃព្រហស្បតិ៍៣រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ត្រូវនឹងថ្ងៃទី..០៩.....ខែ..មីនា..ឆ្នាំ២០២៣
ចុះបញ្ជីលេខ : ......១៣០.............ប្រ.ប្រ

នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម អ៊ុន ចាន់ដា អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ប្រគល់បណ្ណសរសើរជូនលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម តំណាងឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារ ឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អៀត ប៊ុនលី ៖ សមាជិកសន្តិសុខឃុំចក ស្រុកអូររាំងឪ

*វ៉ែន សុភី*



កម្មាភិបាលខ្មែរក្រហមចូលរួមវគ្គបណ្តុះបណ្តាលនយោបាយ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អៀត ប៊ុនលី ភេទប្រុស មានអាយុ២៨ឆ្នាំ នៅក្នុងឆ្នាំ១៩៧៧។ ខ្ញុំមានស្រុកកំណើតនៅភូមិចក ឃុំចក ស្រុកអូររាំងឪ ខេត្តកំពង់ចាម បច្ចុប្បន្ន ខេត្តត្បូងឃ្មុំ។ ខ្ញុំមានបងប្អូនបង្កើតចំនួនប្រាំបួននាក់ គឺប្រុសចំនួនប្រាំពីរនាក់ និងស្រីចំនួនពីរនាក់។ បងប្អូនរបស់ខ្ញុំមានគ្រួសារចំនួនពីរនាក់ និងនៅលីវចំនួនប្រាំពីរនាក់។ នៅក្នុងចំណោមបងប្អូនទាំងអស់មានបងប្អូនចំនួនបីនាក់បានចូលធ្វើបដិវត្តន៍។ បងប្រុសម្នាក់ចូលធ្វើជាទាហានឈ្មោះ ថន បច្ចុប្បន្នធ្វើជាកម្មករនៅចម្ការកៅស៊ូក្រែប នៅស្រុកមេមត់។

ខ្ញុំមានឪពុកឈ្មោះ ធួ អាយុ៥៥ឆ្នាំ និងម្តាយឈ្មោះ សៀត អាយុ៥០ឆ្នាំ។ ឪពុកម្តាយរបស់ខ្ញុំធ្វើស្រែ។ ខ្ញុំបានចូលធ្វើបដិវត្តន៍នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៧១ តាមរយៈឈ្មោះ យ៉ាន គឺជាអ្នកនាំចូល។ យ៉ាន មាននាទីគឺជាប្រធានឃុំចក ស្រុកអូររាំងឪ។ មុនដំបូងខ្ញុំបានទទួលការអប់រំពីឈ្មោះយ៉ាន។ យ៉ានបានអប់រំខ្ញុំអំពីការធ្វើបដិវត្តន៍មានការលំបាកស្មុគស្មាញ សម្រាប់ប្រជាជន និងកងទ័ព។ នៅក្នុងតំបន់រំដោះ ការរស់នៅមានការខ្វះខាតស្លៀកពាក់ ការស៊ីចុកមិនគ្រប់គ្រាន់ និងគ្មានសិទ្ធិសេរីភាពឡើយ។ ដូច្នេះការសប្បាយរីករាយរបស់យើងក៏មិនមានដែរ។ ចំណែកឯសម្ភារសឹក និងស្បៀងអាហារសម្រាប់ធ្វើសង្គ្រាមជាមួយសត្រូវមានតិចតួច មិនអាចវាយយកឈ្នះសត្រូវបានទេ។ ប្រសិនបើពិនិត្យមើលប្រជាជន និងកងទ័ពនៅទីក្រុងភ្នំពេញវិញ គឺរស់នៅសប្បាយចិត្ត និងហូបចុកគ្រប់គ្រាន់។ កងទ័ពមានបុណ្យស័ក្តិ មានប្រាក់ខែ មិនតែប៉ុណ្ណោះសម្ភារធ្វើសង្គ្រាមទំនើបៗគ្រប់គ្រាន់។ ក្រោយពីខ្ញុំបានស្តាប់ការ

អប់រំរបស់យ៉ាន មកខ្ញុំក៏យល់ស្របតាមយោបល់នេះទាំងស្រុង។ ខ្ញុំបានធ្វើការសម្រេចចិត្តធ្វើសកម្មភាពប្រឆាំងដាច់ខាតជាមួយបដិវត្តន៍។ បន្ទាប់មកខ្ញុំបានឡើងធ្វើជាឈ្លបនៅឃុំចក ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ យ៉ាន។

តមកទៀតខ្ញុំត្រូវបានចាត់តាំងឲ្យនៅក្នុងកងវរសេនាតូចលេខ២២៥ ប្រចាំតំបន់២២។ នៅក្នុងកងវរសេនាតូចលេខ២២៥របស់ខ្ញុំគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ ស្រ៊ិន ដែលមានតួនាទីជានយោបាយកងវរសេនាតូចលេខ២២៥។ កងវរសេនាតូចលេខ២២៥នេះ បច្ចុប្បន្នអង្គការបញ្ចូលទៅក្នុងកងវរសេនាធំលេខ១៥២ ដែលមានអ្នកទទួលខុសត្រូវឈ្មោះ ស្រ៊ិន ដដែល។

នៅខែកក្កដា ឆ្នាំ១៩៧២ យ៉ានបានខ្ទេសនាមនិងបញ្ចូលខ្ញុំជាសមាជិកខ្មែរស នៅមន្ទីរឃុំចក។ យប់នោះមានអ្នកចូលរួមមួយចំនួន គឺឈ្មោះ ផុន នាទីជាអនុប្រធានសន្តិសុខ ឃុំចក ស្រុកអូររាំងឪ, ឈ្មោះ ថុន នាទីជាសមាជិកឈ្លបឃុំចក ស្រុកអូររាំងឪ និង ខ្ញុំព្រមទាំងអ្នកចូលរួមប្រជុំមួយចំនួនទៀត មានឈ្មោះ ខែម ម៉ា នាទី ជាអនុប្រធានឃុំចក ស្រុកអូររាំងឪ, ឈ្មោះ ជ័យ នាទី ជាប្រធានឈ្លបឃុំចក ស្រុកអូររាំងឪ, ឈ្មោះ ជា នាទី ជាអនុប្រធានឃុំចក ស្រុកអូររាំងឪ។ ផែនការ និងខ្លឹមសារដែលខ្ញុំបានចូលជាខ្មែរស គឺនៅពេលយាមត្រូវចាប់ប្រជាជនមិនឲ្យដើររកស៊ី, ធ្វើយ៉ាងណាឲ្យប្រជាជនមានទំនាស់ជាមួយអង្គការ, ត្រូវបំផុសប្រជាជនឲ្យមានទំនាស់ជាមួយប្រធានភូមិពីរឿងធ្វើសំបុត្រ, ត្រូវបំផ្លាញសម្ភារនៅក្នុងមន្ទីរ, ដើរកៀងគរកម្លាំងសេរីឲ្យបានច្រើនដើម្បីងាយស្រួលបញ្ចូលជាខ្មែរស។

ក្រោយពីខ្ញុំបានចូលជាខ្មែរស ខ្ញុំបានចូលរួមសកម្មភាពប្រជុំចំនួនបីលើកគឺ៖ ទី១) នៅខែសីហា ឆ្នាំ១៩៧២។ ខ្ញុំបានប្រជុំនៅក្នុងភូមិចម្លាក់ ស្រុកអូររាំងឪ។ យ៉ានបានចូលរួមប្រជុំចាប់ពីម៉ោង៨:00 ដល់ម៉ោង១១:00យប់ ដែលមានសមាជិកចូលរួមឈ្មោះ ផុន នាទីអនុប្រធានសន្តិសុខឃុំចក, ថុន នាទីសមាជិកឈ្លបឃុំចក និងខ្ញុំ។ លើកទី២) នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧២ ដែលការប្រជុំនៅវាលស្រែ ក្នុងភូមិវាលកើត ឃុំចក ដែលមានឈ្មោះ ខែមម៉ា មាននាទីជាប្រធានឃុំចក។ ការប្រជុំលើកទី៣) នៅក្នុងខែមករា ឆ្នាំ១៩៧៣ ប្រជុំនៅវាលស្រែស្តែ ឃុំកោះញែក ស្រុកអូររាំងឪ។ ប្រជុំលើកទីបីនេះមានប្រធានដឹកនាំប្រជុំឈ្មោះ ជ័យ មាននាទី ជាប្រធានឈ្លបឃុំចក។ ខ្លឹមសារសំខាន់នៅក្នុងការប្រជុំទាំងបីលើកគឺ៖ ត្រូវបំផុសយុទ្ធជនឲ្យមានទំនាស់ជាមួយអង្គការពីរឿងធ្វើការងារ, ត្រូវដើរបំផុសយុទ្ធជនឲ្យខ្លាចសមរភូមិ, បំផុសយុទ្ធជនឲ្យមានទំទាស់ជាមួយបក្ខជនអំពីរឿងចូលក្រុមសហករណ៍, ជំទាស់ជាមួយមេភូមិពីបញ្ហាដើរទៅណាមកណាមិនបាន, ត្រូវដើរកម្ទេចកម្លាំងបដិវត្តន៍, ពេលចូលធ្វើទ័ពបំផុសទ័ពឲ្យខ្លាចសមរភូមិ, ប្រើសញ្ញាសម្គាល់ខ្មែរស គឺមូរដៃអាវខាងឆ្វេងផ្គត់ ឯដៃខាងស្តាំមិនបាច់មូរទេ។

ខ្ញុំបានធ្វើសកម្មភាពជាច្រើននៅក្នុងតួនាទីជាឈ្លបឃុំចក ដូចជា បំផុសយុវជនភូមិមិនឲ្យទៅមុខ, មិនឲ្យជឿជាក់លើអង្គការ, ចាប់ប្រជាជន១០នាក់ចងដោយគ្មានមូលហេតុ, បំផុសប្រជាជនធ្វើបាតុកម្មប្រឆាំងនឹងបក្សពីរឿងប្រមូលកម្លាំងចូលក្រុមសហករណ៍, ខ្ញុំបានបំផុស កសាង អប់រំកម្លាំងបានចំនួន៥នាក់បន្ថែមទៀត ដោយ២នាក់រួមមានឈ្មោះ បេង នាទីជាយុទ្ធជនឈ្លបឃុំចក ស្រុកអូររាំងឪ, ឈ្មោះ ហឿន នាទីជាប្រធានពួកឃុំចក បច្ចុប្បន្នស្លាប់ បញ្ចូលជាខ្មែរសេរីនៅខែកញ្ញា ឆ្នាំ១៩៧២ នៅភូមិស្រែស្តែ ឃុំកោះញែក និង៣នាក់ទៀតបានអប់រំតែមិនទាន់បញ្ចូលជាខ្មែរស មានឈ្មោះយ៉ន នាទីជាយុទ្ធជនឈ្លបឃុំចក ស្រុកអូររាំងឪ, ឈ្មោះខឿន នាទីជាប្រធានពួកឈ្លបឃុំចក ស្រុកអូររាំងឪ, ឈ្មោះអុន នាទីជាយុទ្ធជនឈ្លបឃុំចក ស្រុកអូររាំងឪ។

ក្រោយមកខ្ញុំក៏ត្រូវបានខ្ទេសនាមឲ្យចូលជាសមាជិក សេ.អ៊ី.អា នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ដោយមានអ្នកចូលរួមចំនួនបីនាក់។ យើងចូល សេ.អ៊ី.អា នៅភូមិកៀនឃ្លាំង ប៉ុបន្ទាយថ្មីខាងកើតស្ពានជ្រោយចង្វារ។ អ្នកចូលរួមមានឈ្មោះ យឿន នាទីនីរសារកងធំ១៩០ វរសេនាតូចលេខ២២៥ វរសេនាធំលេខ១៥២, ឈ្មោះសារ៉េត នាទីជាយុទ្ធជនពេទ្យ វរសេនាតូចលេខ២២៥ និងខ្ញុំ។ នៅពេលចូល សេ.អ៊ី.អា នេះ

ឈ្មោះ ស្រ៊ិន បានប្រាប់ថា នៅក្នុងកងវរសេនាតូចលេខ២២៥ នេះ មាន សេ.អ៊ី.អា ចូលមុន គាត់ចំនួន៥នាក់ គឺមានឈ្មោះ លឹម នាទីជាយោធាកងតូចទី៣ កងធំទី១៩០ វរសេនាតូចលេខ២២៥ បច្ចុប្បន្ននៅកងដដែលនៅធ្វើស្រែខាងកើតស្ពានជ្រោយចង្វារ, ឈ្មោះ ផល់ នាទីជាយុទ្ធជនពិការ នៅក្នុងមន្ទីរវរសេនាធំលេខ១៥២ បច្ចុប្បន្ននៅដេកពេទ្យនៅក្នុងមន្ទីរពេទ្យព-៩៨, ឈ្មោះរឿន នាទីជាយុទ្ធជននៅរោងជាងធ្វើសម្ភារកសិកម្មប្រចាំមន្ទីរ វរសេនាធំលេខ១៥២, ឈ្មោះធី នាទីជានយោបាយកងតូចស៊ើបការណ៍ប្រចាំកងវរសេនាតូចលេខ២២៥ វរសេនាធំលេខ១៥២ និងឈ្មោះអឿន នាទីជាប្រធានក្រុមខាងរោងជាងធ្វើកាណូតប្រចាំវរសេនាធំលេខ១៥២។ ពេលនោះ ខ្ញុំមិនបានធ្វើសកម្មភាពជាមួយគ្នាទេ។ ពេលចូលជា សេ.អ៊ី.អា ខ្ញុំបានធ្វើសកម្មភាពជាច្រើន ដូចជាបំផុសយុទ្ធជននៅក្នុងអង្គភាពឲ្យទំនាស់ជាមួយអង្គការពីរឿង ធ្វើការងារគ្មានពេលសម្រាក, បំផុសបុរស និងនារីឲ្យទំនាស់ជាមួយបក្សពីរឿងមិនរៀបការឲ្យ, បំផ្លាញសម្ភារ, ត្រូវកៀងគរក្រុមសេរីឲ្យបានច្រើនដើម្បីងាយស្រួលបញ្ចូលជា សេ.អ៊ី.អា។

ខ្ញុំបានបំផុស និងអប់រំកសាងកម្លាំងបានចំនួនប្រាំនាក់ និងមិនទាន់ចូលជា សេ.អ៊ី.អា ចំនួនបីនាក់ មានឈ្មោះ អុន នាទីជាយុទ្ធជនកងតូចទី៣ កងធំ១៩០ វរសេនាតូចលេខ២២៥ វរសេនាធំលេខ១៥២, ឈ្មោះ ជឿន នាទីជាយុទ្ធជនកងតូចទី៣ កងធំ១៩០ វរសេនាតូចលេខ២២៥ វរសេនាធំលេខ១៥២, ឈ្មោះ ផន នាទីជាប្រធានពួក កងតូច០២ កងធំ១៩០ វរសេនាតូចលេខ២២៥ វរសេនាធំលេខ១៥២ និង២នាក់ទៀតមានឈ្មោះហេង នាទីប្រធានពួក កងតូចទី៣ កងធំ១៩០ វរសេនាតូចលេខ២២៥ វរសេនាធំលេខ១៥២, ឈ្មោះនី នាទីជាយុទ្ធជនកងតូចទី៣កងធំ១៩០វរសេនាតូចលេខ២២៥វរសេនាធំលេខ ១៥២ ហើយបានបញ្ចូលជា សេ.អ៊ី.អា នៅខែកញ្ញា ឆ្នាំ១៩៧៦ នៅភូមិកៀនឃ្លាំង ខាងកើតស្ពានជ្រោយចង្វារ ដោយក្នុងពេលនោះមានឈ្មោះ ស្រ៊ិន បានចូលរួមក្នុងកម្មវិធីនេះដែរ។ កំណត់ហេតុចម្លើយសារភាពនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧៧។

**កំណត់ចំណាំ៖ អត្ថបទនេះ ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J00៨៥២។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ អៀត ប៊ុនលី ពិតប្រាកដណានោះទេ។**



កម្មាភិបាលខ្មែរក្រហមនៅតាមមន្ទីរ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ជួបប្រជុំ

## ពិភាក្សាជាមួយអាជ្ញាធរស្រុកកំពង់សៀមស្ដីអំពីគម្រោងប្រវត្តិសាស្ត្រ និងសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

*អេង វណ្ណីកា*



លោកស្រី សុខ ម៉ាលីស អភិបាលរងស្រុកកំពង់សៀម (រូបទីពីររាប់ពីឆ្វេង) និងលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (ទូច វណ្ណេត / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំដោយ ទូច វណ្ណេត, អេង វណ្ណីកា និង ស៊ាង ចិន្តា ទទួលបានការអនុញ្ញាតឲ្យចូលជួបប្រជុំជាមួយលោកស្រី សុខ ម៉ាលីស អភិបាលរងស្រុកកំពង់សៀម និងមន្ត្រីពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីការស្នើសុំកិច្ចសហការ និងការអនុញ្ញាតឲ្យអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមចុះបំពេញកិច្ចការងារទៅលើគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៅតាមភូមិ និងឃុំនានាក្នុងស្រុកកំពង់សៀម។

ជាកិច្ចចាប់ផ្ដើម លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលជាសាខារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ថ្លែងអំណរគុណដល់លោកស្រីអភិបាលរងស្រុក ចំពោះការអនុញ្ញាតឲ្យក្រុមការងារចូលជួបប្រជុំ និងបង្ហាញអំពីគោលបំណងនៃគម្រោង ដែលរួមមាន៖ ទី១) ធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅតាមគោលដៅដែលបានកំណត់, ទី២) លើកកម្ពស់ការយល់ដឹងអំពីសុខភាពសាធារណៈ និងការទទួលបានសេវាកម្មសុខភាព

សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទី៣) ធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមសហគមន៍។

ដើម្បីសម្រេចបាននូវគោលបំណងនេះ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ស្នើសុំការអនុញ្ញាតពីលោកអភិបាល នៃគណៈអភិបាលស្រុកកំពង់សៀម ក្នុងការចុះអនុវត្តសកម្មភាពការងារគម្រោងនៅក្នុងភូមិ និងឃុំនានាក្នុងស្រុកកំពង់សៀម និងកិច្ចសហការក្នុងការជ្រើសរើសអ្នកស្ម័គ្រចិត្តចេញពីមូលដ្ឋានភូមិ និងឃុំនានាក្នុងស្រុកកំពង់សៀមចំនួន ២០នាក់ដើម្បីចុះអនុវត្តកិច្ចការងារក្នុងពេលឆាប់ៗនេះ។

លោកស្រី សុខ ម៉ាលីស អភិបាលរងស្រុក ថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ក្នុងការកំណត់យកស្រុកកំពង់សៀមជាគោលដៅអាទិភាព និងសម្តែងការពេញចិត្តចំពោះគម្រោងនេះដែលយកចិត្តទុកដាក់ទៅលើមិនត្រឹមតែបទពិសោធន៍ជីវិតនោះឡើយ ក៏ប៉ុន្តែថែមទាំងស្ថានភាពសុខភាពបច្ចុប្បន្នរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ លោកស្រីអភិបាលរងស្រុកបន្ថែមទៀតថា «សន្តិភាពគឺពិតជាមានសារសំខាន់ណាស់ ដែលយើងគ្រប់គ្នាត្រូវតែចូលរួមការពារ។ ការស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអាចជួយលើកកម្ពស់ការអត់ឱន និងការយោគយល់គ្នា ដើម្បីទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញ។ បន្ថែមលើនេះទៀត គម្រោងប្រវត្តិសាស្ត្រ និងសុខភាពនេះ គឺល្អសម្រាប់យុវជន-យុវនារី ក៏ដូចជារូបខ្ញុំផ្ទាល់ ដែលកើតក្រោយរបបខ្មែរក្រហមអាចចុះជួបនិងស្តាប់អំពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានភូមិនិងឃុំរបស់ខ្លួន ដើម្បីយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងចូលរួមការពារសន្តិភាព និងការអភិវឌ្ឍ»។

ជាចុងបញ្ចប់នៃកិច្ចប្រជុំនេះ លោកស្រីអភិបាលរងស្រុក ផ្តល់កិច្ចសហការក្នុងការជួយជ្រើសរើសយុវជន-យុវនារីស្ម័គ្រចិត្តក្នុងស្រុក ដើម្បីចូលរួមបំពេញកិច្ចការងារក្នុងការជួយដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងភូមិសាស្ត្រស្រុកកំពង់សៀម។



លោកស្រី សុខ ម៉ាលីស អភិបាលរងស្រុកកំពង់សៀម។
(ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការអប់រំពីបញ្ហាសុខភាពផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតែសំខាន់

**គីម សុវណ្ណដានី**



នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការចិត្តសង្គម អន្តរវប្បធម៌ សហការធ្វើសិក្ខាសាលាស្ដីពីការអប់រំ និងដោះស្រាយបញ្ហាសុខភាពផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅក្នុងភូមិរំចេក នៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទោះបីជារបបខ្មែរក្រហមបានដួលរលំទៅអស់រយៈពេល ៤៤ឆ្នាំទៅហើយក្ដី តែការនឹកឃើញពីការធ្វើទារុណកម្ម ការបង្អត់អាហារ និងការបង្ខំឲ្យធ្វើការលើសកម្លាំង នៅដក់ជាប់ក្នុងការចងចាំរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដដែល ពិសេសអ្នកដែលមានជីវភាពក្រលំបាក ដែលជារឿយៗតែងតែតូចចិត្ត និងខឹងសម្បារដល់របបខ្មែរក្រហមដែលបានធ្វើឲ្យក្រុមគ្រួសាររបស់គាត់បែកបាក់ បាត់បង់សមាជិកគ្រួសារ រហូតដល់ធ្វើឲ្យគាត់ជួបតែភាពលំបាកមកដល់សព្វថ្ងៃ ផ្ទុយទៅនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានជីវភាពធូរធារ ដែលមិនសូវព្រួយបារម្ភ ឬនឹកឃើញអតីតកាលដ៏ជូរចត់ៗ ជាក់ស្ដែង ទិន្នន័យដែលប្រមូលបានពីការចុះទៅសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី ៥០ឆ្នាំឡើង ដោយអ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ២០២២កន្លងមកនេះ សរុបមានចំនួន៣៥៣០៨នាក់ ក្នុងចំណោមនេះមានអ្នកមានវិបត្តិផ្លូវចិត្តចំនួន ៦៥៣៨នាក់ ស្មើនឹង ២០%។

គម្រោង ជនរងគ្រោះដោយអំពើទារុណកម្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលជំនួយពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ កន្លងមកធ្លាប់បានសហការជាមួយអង្គការចិត្តសង្គម អន្តរវប្បធម៌ បង្កើតកម្មវិធីអប់រំពីបញ្ហាសុខភាពផ្លូវចិត្តដល់ជនរងគ្រោះពីរបបខ្មែរក្រហម និងអតីតកងទ័ពខ្មែរក្រហម រស់នៅខេត្តកណ្ដាល និងខេត្តតាកែវ ដែលជាខេត្តគ្រប់គ្រងដោយ តាម៉ុក លេខាភូមិភាគនិរតីនៅក្នុងរបបខ្មែរក្រហម។ ក្នុងចំណោមអ្នកផ្ដល់បទសម្ភាសន៍ប្រមាណជា ២២២នាក់ ក្រុមការងាររបស់អង្គការចិត្តសង្គម អន្តរវប្បធម៌ រកឃើញអ្នកមានជំងឺបាត់ស្បាតប្រមាណជា ៦០នាក់ និងមានសភាពធ្ងន់ធ្ងរ មធ្យម និងខ្សោយ។

នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការចិត្តសង្គម អន្តរវប្បធម៌ សហការធ្វើសិក្ខាសាលាស្ដីពីការអប់រំ និងដោះស្រាយបញ្ហាសុខភាពផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលរស់នៅក្នុងភូមិរំចេក នៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ សិក្ខាសាលាប្រព្រឹត្តទៅរយៈពេល២ម៉ោង ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៥០នាក់ ដែលធ្លាប់បានផ្ដល់បទសម្ភាសន៍ដល់អ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រស់នៅស្រុកកោះសូទិន និងស្រុកកំពង់សៀម ខេត្តកំពង់ចាម កាលពីចុងឆ្នាំ២០២២ កន្លងមក។

គោលជំហរ និងកម្មវត្ថុ គឺជាកម្លាំងដ៏រឹងមាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានសេចក្ដីរំពឹងថា សង្គមយើងទទួលស្គាល់ការខំប្រឹងប្រែងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានចូលរួមកសាងប្រទេស ពង្រឹងសន្តិភាព និងការអភិវឌ្ឍន៍មួយដើម្បីអនាគតកូនចៅជំនាន់ក្រោយៗទៀត។



នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការចិត្តសង្គម អន្តរវប្បធម៌ សហការធ្វើសិក្ខាសាលាស្ដីពីការអប់រំ និងដោះស្រាយបញ្ហាសុខភាពផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលរស់នៅក្នុងភូមិរំចេក នៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)









នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការចិត្តសង្គម អន្តរវប្បធម៌ សហការធ្វើសិក្ខាសាលាស្តីពីការអប់រំ និងដោះស្រាយបញ្ហាសុខភាពផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលរស់នៅក្នុងភូមិរំចេក នៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# គម្រោងសូត្រចាមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

***មីន សាណាស់***



*ស្ត្រីជនជាតិចាម នៅស្រុកកោះសូទិន ខេត្តកំពង់ចាម កំពុងត្បាញសូត្រ។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

គម្រោងសូត្រចាមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បង្កើតឡើងក្នុងគោលបំណងដើម្បីរក្សាការចងចាំរបស់ជនជាតិចាមអំពីសូត្រ និងតម្បាញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ, លើកកម្ពស់ការយល់ដឹង និងផ្សព្វផ្សាយ និងរៀបចំផែនការអភិវឌ្ឍនៅពេលអនាគត។ គម្រោងនេះនឹងគាំទ្រស្ត្រី និងអ្នករស់នៅក្នុងសហគមន៍បង្កើតជាសិប្បកម្មតម្បាញធុនតូច ដោយចាប់ផ្ដើមពីគំនិត កីមួយ និងសូត្រមួយសំពត់។

នៅដំណាក់កាលដំបូងនៃគម្រោងសូត្រចាមនឹងផ្ដោតសំខាន់ៗទៅលើសកម្មភាពដូចតទៅ គឺ១) ចុះស្រាវជ្រាវ និងចងក្រងឯកសារ ២) សិក្សាពីសិល្បៈ និងសហគមន៍តម្បាញសូត្រចាម ៣) ធ្វើពិសោធន៍ និងរៀបចំការបណ្ដុះបណ្ដាលសម្រាប់សហគមន៍ ៤) ត្បាញ ៥) ធ្វើការផ្សព្វផ្សាយ និងដាក់តាំងបង្ហាញពីផលិតផលតម្បាញរបស់សហគមន៍ចាម។ គម្រោងស្រាវជ្រាវ សូត្រចាមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឧបត្ថម្ភដោយប្រទេសតួកគី តាមរយៈទីភ្នាក់ងារ សហប្រតិបត្តិការ និងអភិវឌ្ឍន៍របស់ប្រទេសតួកគីដោយសហការជាមួយ ស្ថានទូតតួកគីប្រចាំនៅប្រទេសកម្ពុជា។

ក្រុមការងារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា រួមមាន ស៊ាង ចិន្តា, ឡុង អូន និង មីន សាណាស់

បានចុះទៅសម្ភាសន៍អ្នករស់រាន មានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិចាម អំពីរឿងរ៉ាវជីវិតដែលបានឆ្លងកាត់របបខ្មែរក្រហម និងការប្រកបរបរចិញ្ចឹមគ្រួសារជាមួយការត្បាញសូត្រ ការប្រើសិល្បៈត្បាញគោម ការរចនាម៉ូត និងការប្រើប្រាស់ពណ៌ក្នុងការត្បាញ។

**ម៉ាត់ ម៉ៃស្នះ** ភេទស្រី អាយុ៧២ឆ្នាំ រស់នៅស្រុកកោះសូទិន ខេត្តកំពង់ចាម បានរៀបរាប់ថា «តម្បាញសូត្រចាម អាចឲ្យខ្ញុំចិញ្ចឹមម្ដាយ កូន និងក្មួយក្រោយពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩»។

ក្រោយរបបខ្មែរក្រហម គ្រួសារខ្ញុំរស់រានមានជីវិតតែស្ត្រី និងក្មេងៗតែប៉ុណ្ណោះ ហេតុនេះ ខ្ញុំនិងម្ដាយរបស់ខ្ញុំខិតខំសុះស្វែងទៅរកត្រីដើម្បីលក់សន្សំលុយទិញកីទុកត្បាញក្រណាត់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ។ ខ្ញុំនៅចាំថា ម្ដាយខ្ញុំ និងស្ត្រីចាមក្នុងភូមិសុទ្ធតែមានចំណេះដឹងខាងតម្បាញសូត្រ ហើយនៅតាមផ្ទះនីមួយៗមានកីតម្បាញគ្រប់ៗគ្នា។ ចំណែកខ្ញុំមានជំនាញចងគោម និងត្បាញតពីម្ដាយរបស់ខ្ញុំ ហើយម្ដាយរបស់ខ្ញុំក៏ទទួលចំណេះដឹងតពីយាយរបស់ខ្ញុំដែរ។

ម្ដាយរបស់ខ្ញុំឈ្មោះ ម៉ៃយ៉ំ ពេលនៅរស់គាត់ប្រកបរបរតម្បាញ ចំណែកឪពុករបស់ខ្ញុំឈ្មោះ ម៉ាត់ មានមុខរបរជាអ្នកនេសាទ។ កាលពីសម័យមុន ជនជាតិចាមមករស់នៅក្នុងប្រទេសកម្ពុជាមានមុខរបរតែពីរប៉ុណ្ណោះ គឺនេសាទ និងតម្បាញ ហើយកូនៗដែលកើតមកត្រូវតែមានចំណេះដឹងក្នុងការប្រកបរបរនេះ។ ឪពុករបស់ខ្ញុំបានបង្រៀនបងប្រុស និងប្អូនប្រុសខ្ញុំអំពីជំនាញនេសាទត្រី ចំណែកម្ដាយរបស់ខ្ញុំបានបង្រៀនខ្ញុំនិងបងប្អូនស្រីៗអំពីសិល្បៈចរបាប់, តម្បាញ, ចាក់ផ្កាលើពូកខ្នើយ ជាដើម។ នៅពេលប្រទេសកម្ពុជាកើតមានសង្គ្រាមជាហូរហែ ប្រពៃណី វប្បធម៌របស់ជនជាតិចាមក៏បាត់បង់បន្តិចម្ដងៗ។



ម៉ាត់ ម៉ៃស្នះ ភេទស្រី អាយុ៧២ឆ្នាំ រស់នៅស្រុកកោះសូទិន ខេត្តកំពង់ចាម។
(ស៊ាង ចិន្ដា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំចេះត្បាញសំពត់សូត្រតាំងពីអាយុ១៣ឆ្នាំ និងកាន់កីតម្បាញរាល់ថ្ងៃ។ នាសម័យមុនមុខរបរតម្បាញសូត្រ គឺថ្លៃថ្នូរ ហើយប្រជាជនផ្តល់តម្លៃខ្លាំងណាស់។ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំបានរៀបការជាមួយប្ដីរបស់ខ្ញុំឈ្មោះ កសឹម ប្រកបមុខរបរនេសាទត្រី។ ក្រោយពីរៀបការរួច ខ្ញុំមានកូនចំនួន៣នាក់។ ខ្ញុំបានមករស់នៅលើទូកនេសាទជាមួយប្ដីរបស់ខ្ញុំ ចំណែកមុខរបរត្បាញសំពត់សូត្ររបស់ខ្ញុំក៏ផ្អាកជាបណ្ដោះអាសន្ន។

នៅពេលយោធាខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានបំផុសឲ្យជនជាតិចាមនៅក្នុងភូមិកោះសូទិន រៀបចំអីវ៉ាន់ និងត្រៀមធ្វើដំណើរទៅរស់នៅប្រទេសអារ៉ាប់។ ប្រជាជនចាមនៅក្នុងភូមិ រួមទាំងគ្រួសារខ្ញុំឪពុកម្ដាយខ្ញុំបានចាកចេញពីភូមិកោះសូទិនតាមការចាត់ចែងរបស់កម្មាភិបាលខ្មែរក្រហម។ នៅតាមផ្លូវ យោធាខ្មែរក្រហមបញ្ជាឲ្យគ្រួសារខ្ញុំទុករបស់មានតម្លៃ និងលុយកាក់ ព្រោះទៅដល់ទីនោះមិនខ្វះខាតឡើយ។ តាមពិត យោធាខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំតាមរថភ្លើងទៅកាន់ភូមិរហាលសួង ខេត្តបាត់ដំបង។ រយៈពេលកន្លះឆ្នាំបន្ទាប់ពីការជម្លៀស ឪពុកខ្ញុំបានធ្លាក់ខ្លួនឈឺដោយសារការបរិភោគមិនបានគ្រប់គ្រាន់ហើយស្លាប់នៅទីនោះ។ តមកប្ដីរបស់ខ្ញុំ និងកូនប្រុសច្បងរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺ និងស្លាប់ដោយសារការអត់ឃ្លានទៀត។ នៅអំឡុងពេលកូននិងប្ដីរបស់ខ្ញុំស្លាប់ គឺខ្ញុំទើបសម្រាលកូនទី៣បានរយៈពេល

មួយខែប៉ុណ្ណោះ។ ទោះបីខ្ញុំនៅសរសៃខ្ចីក៏អង្គការមិនឲ្យខ្ញុំឈប់សម្រាកដែរ គឺអង្គការបានចាត់តាំងខ្ញុំទៅកាប់គល់ឈើ និងដកស្មៅ។ ក្រោយពេលរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅសល់តែខ្ញុំ ម្ដាយរបស់ខ្ញុំ និងកូនតូចៗរបស់ខ្ញុំប៉ុណ្ណោះ។ យើងធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ។ នៅតាមផ្លូវ កូនស្រីរបស់ខ្ញុំទាំងពីរកើតជំងឺអុតស្វាយ រីឯម្ដាយរបស់ខ្ញុំមានវ័យចំណាស់ពិបាកក្នុងការធ្វើដំណើរ។ ខ្ញុំបានសុំរថយន្តរបស់កងទ័ពវៀតណាមជិះមកខេត្តកំពង់ចាម។ ពេលមកដល់ភូមិកំណើត ផ្ទះរបស់ខ្ញុំត្រូវបានខ្មែរក្រហមរុះរើគ្មានសល់ឡើយ។ ខ្ញុំបានក្រាលកន្ទេលលើដីដើម្បីដេកបណ្ដោះអាសន្ន។ ម្ដាយរបស់ខ្ញុំ និងខ្ញុំចេញទៅនេសាទ ដើម្បីយកត្រីទៅដូរយកសម្ភារប្រើប្រាស់ប្រចាំថ្ងៃ និងរៀបចំសាងសង់ខ្ទមសម្រាប់ស្នាក់នៅ។

នៅឆ្នាំ១៩៨០ ជនជាតិចាមនៅក្នុងភូមិដែលមានជីវភាពធូរធារ បាននាំគ្នាទៅទិញសម្ភារសម្រាប់ត្បាញ។ ប៉ុន្តែការត្បាញនោះ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងចែកដល់កូនចៅប៉ុណ្ណោះ គឺមិនទាន់មានការលក់ដូរឡើយ។ ខ្ញុំបានសន្សំប្រាក់រៀបចំធ្វើកីត្បាញ ព្រមទាំងស៊ីឈ្នួលត្បាញឲ្យប្រជាជនក្នុងភូមិរហូតដល់ឆ្នាំ២០១៥ ទើបឈប់ ព្រោះគ្មានទីផ្សារ។ ចំពោះគោមសំពត់សូត្រចាម គឺមានច្រើនម៉ូតណាស់ ដូច្នេះយើងបានបែងចែកវាជាបី គឺ ទី១) គោមវល្លិ៍, ទី២) គោមផ្កា និងផ្លែឈើ និងទី៣) គោមរូបសត្វ។ ចំណែកការជ្រលក់ពណ៌យើងមិនអាចសម្គាល់បានច្បាស់លាស់ឡើយ ព្រោះពណ៌សំពត់សូត្រចាមមានភាពខុសគ្នាពីមួយជំនាន់ទៅមួយជំនាន់ ដូចជា ជំនាន់សង្គមចាស់យើងប្រើផ្ទៃពណ៌ក្រហមសុទ្ធ ហើយចំណងគោមគឺមានពណ៌ក្រហមលឿង និងបៃតង។ ក្រោយមកទៀត អ្នកត្បាញចាប់ផ្ដើមប្រើផ្ទៃស្រអាប់ៗ ហើយពណ៌ចំណងក៏មានតែពីរពណ៌ដែរ។

ខ្ញុំយល់ថា សំពត់សូត្រចាម ក្បាច់គោមសំពត់ចាមអាចនឹងបាត់បង់នៅពេលខាងមុខនេះ ព្រោះសព្វថ្ងៃនេះ ក្មេងស្រីជនជាតិចាមនៅក្នុងភូមិហាក់មិនចាប់អារម្មណ៍នឹងការថែរក្សាការត្បាញដែលជាប្រពៃណីរបស់ខ្លួនឡើយ។

គម្រោងនេះគាំទ្រដោយប្រទេសតួកគី តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការ និងអភិវឌ្ឍន៍របស់ប្រទេសតួកគីដោយសហការជាមួយស្ថានទូតតួកគីប្រចាំនៅប្រទេសកម្ពុជា។



ស្ត្រីជនជាតិចាម នៅស្រុកកោះសូទិន ខេត្តកំពង់ចាម កំពុងចងមងសម្រាប់នេសាទត្រី។
(ស៊ាន ចិន្ដា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



សហគមន៍នេសាទរបស់ជនជាតិចាម នៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម។
(ស៊ាន ចិន្ដា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម

ទូច វណ្ណេត



ការចាក់បញ្ចាំងវីដេអូឯកសារ «កុំស្មានបងភ្លេច៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់ អេនរ៉ូល» នៅក្នុងពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គាំទ្រដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) និងមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំពិធីសម្ពោធដាក់ឲ្យប្រើប្រាស់សំណង់ចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម និងការបង់ចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅកណ្តាលវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម កាលពីឆ្នាំ២០២២ កន្លងមក។ កម្មវិធីសម្ពោធចេតិយមានការចូលរួមពីលោក សៀង ស៊ីផាន ក្រុមប្រឹក្សាឃុំគគរ, លោកស្រី នែនស៊ី អ៊ីសស្ទីក ប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID), អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំគគរ, លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។

ជាកិច្ចចាប់ផ្តើម លោក សៀង ស៊ីផាន ក្រុមប្រឹក្សាឃុំគគរ ថ្លែងអំពីសារសំខាន់នៃការចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ លោក ស៊ីផាន រំឭកអំពីរឿងរ៉ាវដែលខ្លួនបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម រួមមាន ការឃ្លាតឆ្ងាយពីក្រុមគ្រួសារ ការអត់ឃ្លាន និងការកាប់សម្លាប់។ លោក ស៊ីផាន បានបញ្ជាក់ថា «រឿងរ៉ាវរបស់ខ្ញុំ និងអ្នករស់រានមានជីវិតពីរបបខ្មែរ



ពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លោកស្រី នែនស៊ី អ៊ីសស្ទីក ប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ថ្លែងសុន្ទរកថា នៅក្នុងពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រហមនៅភូមិចំការសាមសិប គឺត្រូវបានរំឭកនៅទីតាំងចេតិយដែលជាទីតាំងប្រវត្តិសាស្ត្រ»។ លោក ស៊ីផាន បានថ្លែងអំណរគុណដល់ម្ចាស់ជំនួយ គឺទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិដែលបានសាងសង់ចេតិយនេះ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានរៀបចំកម្មវិធីសម្ពោធនេះឡើង។

លោកស្រី នែនស៊ី អ៊ីសស្ទីក ប្រធានទីភ្នាក់ងារសហរដ្ឋ អាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ថ្លែងអំពីការពេញចិត្ត និងគាំទ្រចំពោះការផ្តួចផ្តើមគំនិតក្នុងការសាងសង់ចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហមនៅក្នុងមូលដ្ឋាន។

លោក តុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិគគរ ថ្លែងថា «ថ្ងៃនេះគឺជាថ្ងៃដ៏មានសារសំខាន់ចំពោះខ្ញុំ និងអ្នកភូមិចំការសាមសិប ក្នុងការដាក់សម្ពោធសំណង់ចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម។ ចេតិយនេះគឺជាទីតាំងរំឭកអំពីប្រវត្តិរឿងរ៉ាវអំពីការរស់នៅក្នុងរបបខ្មែរក្រហម និងការចងចាំអំពីរឿងរ៉ាវទុក្ខលំបាករបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ខ្ញុំ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិចំការសាមសិប ឃុំគគរ បន្តចូលរួមផ្តួចផ្តើមគំនិត និងចែករំលែករឿងរ៉ាវរបស់ខ្លួនដែលបានឆ្លងកាត់ទៅដល់ក្មេងជំនាន់ក្រោយដើម្បីទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញ។ ជាចុងក្រោយ ខ្ញុំបាទតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិចំការសាមសិប សូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ(USAID) ដែលបានឧបត្ថម្ភក្នុងការសាងសង់ចេតិយ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងក្រុមការងារដែលបានគាំទ្រដល់គំនិតផ្តួចផ្តើមនេះឲ្យកើតចេញជារូបរាង។ សូមអរគុណដល់អ្នកស្ម័គ្រចិត្តកម្ពុជា ដែលបានចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយកចិត្តទុកដាក់លើសុខភាពរបស់គាត់»។

បន្ទាប់ពីការថ្លែងសុន្ទរកថា គណៈអធិបតី លោកតា លោកយាយ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស



ពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចូលរួមពិធីបង្វិលពពិលនៅជុំវិញចេតិយចំនួន៣ជុំ បន្ទាប់មកប្រគេនទេយ្យទានដល់ព្រះសង្ឃ និងសូត្រមន្តបង្សុកូលឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម។

ស្របពេលកម្មវិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំកម្មវិធីមួយចំនួនទៀតដូចខាងក្រោម៖

## ពិព័រណ៍រូបថតអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

នៅវេលាម៉ោង៣:៣០នាទីរសៀល អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៣ ប្រចាំខេត្តកំពង់ចាម រៀបចំដាក់តាំងពិព័រណ៍រូបថតអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ការចាប់ផ្តើមការសាងសង់សំណង់ចេតិយ និងសកម្មភាពការងាររបស់អ្នកស្ម័គ្រចិត្តកម្ពុជាចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅមូលដ្ឋាន។ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សនៃអនុវិទ្យាល័យគគរ និងអ្នកភូមិជាច្រើនបានចូលទស្សនាពិព័រណ៍រូបថតនេះ។ ខាងក្រោម គឺជាទស្សនៈយល់ឃើញរបស់អ្នកចូលរួម ៖

អ៊ំប្រុស **អៀង សារឿន** យល់ថា «ការដាក់តាំងបង្ហាញរឿងរ៉ាវរបស់អ្នកដែលបានឆ្លងកាត់របបខ្មែរក្រហម បានរំឭកដល់ខ្ញុំអំពីការចងចាំមិនអាចបំភ្លេចបាននៃការបាត់បង់សាច់ញាតិ ការលំបាក និងការកាប់សម្លាប់នៅក្នុងរបបខ្មែរក្រហម។ ពិព័រណ៍នេះមានសារសំខាន់ណាស់ដើម្បីឲ្យក្មេងជំនាន់ក្រោយយល់ដឹងអំពីប្រវត្តិសាស្ត្រ»។

លោកយាយ **មុយ ហ៊ាង** លើកឡើងថា «នៅពេលខ្ញុំឃើញរូបភាព និងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្សេងទៀត ខ្ញុំនឹកឃើញដល់ពេលវេលាលំបាកដែលខ្ញុំធ្វើការនៅកងចល័តនារីនៅក្នុងរបបខ្មែរក្រហម»។

លោកគ្រូ **រស់ បញ្ញា** បង្រៀនមុខវិជ្ជាប្រវត្តិវិទ្យានៅអនុវិទ្យាល័យភូមិថ្មី បង្ហាញចំណាប់អារម្មណ៍ថា



លោកស្រី នែនស៊ី អ៊ីសស្ទីក ប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ចូលរួមពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការដាក់តាំងពិព័រណ៍នៅទីតាំងចេតិយនេះ គឺល្អខ្លាំងណាស់ដើម្បីផ្តល់ការយល់ដឹងពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមបន្ថែមទៀត ដើម្បីរំឭកដល់ប្រជាជនកម្ពុជាដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំស្នើសុំឲ្យមានការដាក់តាំងពិព័រណ៍បែបនេះបន្តទៀត ។ ខ្ញុំនឹងដឹកនាំសិស្សមកធ្វើទស្សនកិច្ចនៅទីតាំងចេតិយនេះនាពេលអនាគត។



មន្ត្រីនគរបាលកំពុងមើលពិព័រណ៍រូបថតនៅក្នុងពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ការចាក់បញ្ចាំងវីដេអូឯកសារ «កុំស្មានបងភ្លេចៈ ខ្មែរបាត់បង់តន្ត្រី រ៉ក់ អេន រ៉ូល»

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំការចាក់បញ្ចាំងវីដេអូឯកសារមានចំណងជើងថា **«កុំស្មានបងភ្លេច»** ដែលបង្ហាញអំពីតន្ត្រី វប្បធម៌ និងប្រវត្តិសាស្ត្រកម្ពុជា។ ការបញ្ចាំងវីដេអូឯកសារនេះ គឺធ្វើឡើងនៅកណ្តាលវាលស្រែជិតទីតាំងចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម ដោយមានការចូលរួមទស្សនាពីអ្នកភូមិចំការសាមសិបជាច្រើន។ ការបញ្ចាំងវីដេអូឯកសារនេះចាប់ផ្តើមពីវេលាម៉ោង៦:៣០នាទីល្ងាចដល់វេលាម៉ោង៨:៣០នាទីយប់។



ការដាក់តាំងពិព័រណ៍រូបថតនៅក្នុងពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមរៀបចំពិធីបង្សុកូលឧទ្ទិសកុសលដល់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម

**ទូច វរណ្ណាត**



ស្តូបរំឭកដល់អ្នកដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហមក្នុងសហគមន៍គគរ។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ សមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំគគរ គាំទ្រដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ចូលរួមប្រារព្ធទិវាជាតិនៃការចងចាំ ដោយបានរៀបចំពិធីបង្សុកូលឧទ្ទិសកុសលដល់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហមនៅចេតិយរំឭកសម្រាប់សហគមន៍ និងដើម្បីរំឭកដល់អ្នកដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហមក្នុងសហគមន៍គគរ និងបង្កើនស្មារតីចងចាំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាក្នុងកម្រិតមូលដ្ឋាន។









ប្រជាជនក្នុងសហគមន៍ចូលរួមរៀបចំពិធីបង្សុកូលឧទ្ទិសកុសលដល់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហមនៅឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាមៗ ( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងស្រុកកំពង់សៀមខេត្តកំពង់ចាម

សាំង ចិន្តា និង ទូច វណ្ណាត

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសាររយៈពេល ៤ថ្ងៃជាមួយអ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ដើម្បីស្តាប់រឿងរ៉ាវជីវិតរបស់គាត់ដែលបានឆ្លងកាត់របបខ្មែរក្រហម។ ខាងក្រោម គឺជារឿងរ៉ាវសង្ខេបរបស់គាត់៖

## ប៊ុន ឡៅ ហាន



ប៊ុន ឡៅ ហាន ភេទស្រី អាយុ៧១ឆ្នាំ ជាអតីតកងចល័តនារី និងជាអ្នករស់រានមានជីវិត រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម បានចែករំលែករឿងរ៉ាវជីវិតរបស់ខ្លួនក្នុងរបបខ្មែរក្រហមដូចតទៅ៖ ខ្ញុំកើតនៅឆ្នាំ១៩៥១ ក្នុងគ្រួសារកសិករមួយ នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំមានម្តាយឈ្មោះ អេង ណយស្រីម និងឪពុកឈ្មោះ ប៊ុន ណាល់។ ឪពុកម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមសម្លាប់នៅឆ្នាំ១៩៧៧។ ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន៦នាក់។ ខ្ញុំរៀននៅសាលាបឋមសិក្សាគគរដល់ថ្នាក់ទី៩ចាស់។ ខ្ញុំចេះអាន និងសរសេរបានបន្តិចបន្តួច។ ក្រោយមកទៀត ខ្ញុំឈប់រៀន ដោយសារជីវភាពក្រីក្រ។ ខ្ញុំជួយឪពុកម្តាយត្បាញក្រមាលក់ និងធ្វើកិច្ចការងារផ្ទះ។ នៅពេលដែលខ្ញុំត្បាញក្រមាបានប្រហែល២០ ឈ្មួញកណ្តាលតែងតែចុះមកទិញយកទៅលក់បន្ត។ ខ្ញុំទទួលដំណឹងអំពីព្រឹត្តិការណ៍រដ្ឋប្រហារនៅខែមីនា ឆ្នាំ ១៩៧០ តាមរយៈវិទ្យុ។ បន្ទាប់ពីរដ្ឋប្រហារកើតឡើងបាន១ខែ ខ្ញុំឃើញអ្នកភូមិជាច្រើនធ្វើបាតុកម្មដង្ហែតាមផ្លូវចេញពីភូមិទៅទីរួមខេត្តកំពង់ចាម។ ខ្ញុំមិនបានចូលរួមធ្វើបាតុកម្មនោះទេ។ ខ្ញុំបន្តត្បាញក្រមាដូចធម្មតា។ ប៉ុន្មានថ្ងៃក្រោយមក បាតុករទាំងអស់បានដង្ហែឆ្លងកាត់ភូមិម្តងទៀតក្នុងទិសដៅមកកាន់ទីក្រុងភ្នំពេញ។ នៅឆ្នាំ១៩៧១ កងទ័ពរំដោះខ្មែរក្រហម បានចូលមកដល់ និងបានសុំអ្នកភូមិស្នាក់នៅ។ វត្តមានរបស់កងទ័ពរំដោះខ្មែរក្រហមនៅក្នុងភូមិគឺជាសញ្ញានៃការផ្ទុះឡើងការប្រយុទ្ធគ្នានាពេលខាងមុខ។ នៅចុងឆ្នាំ១៩៧១ ទាហានលន់ នល់ជាច្រើនត្រូវបានបញ្ជូនទៅឈរជើងនៅបន្ទាយកោះរកា និងរកាគយ។ បន្ទាប់មកទាហានលន់ នល់ បើកការវាយប្រហារទៅលើកងទ័ពរំដោះខ្មែរក្រហម។ ទាហានលន់ នល់ បញ្ជូនកងទ័ពអាកាសទៅទម្លាក់គ្រាប់បែក និងបាញ់ប្រហារមកលើកងទ័ពរំដោះខ្មែរក្រហម។ ខ្ញុំ និងក្រុមគ្រួសាររត់ភៀសខ្លួនចេញពីផ្ទះទៅស្នាក់នៅបណ្តោះអាសន្នជាមួយពូនៅជីហែ ដែលជាតំបន់រំដោះខ្មែរក្រហម ស្ថិតនៅត្រើយម្ខាងនៃទន្លេមេគង្គ ដើម្បីសុវត្ថិភាព។ នៅ

ឆ្នាំ១៩៧២ ខ្ញុំរៀបការជាមួយប្ដីឈ្មោះ ឈិន ហុក ដែលធ្វើការនៅកងយុវជន។ នៅឆ្នាំ១៩៧៣ ខ្ញុំបង្កើតបានកូនប្រុសម្នាក់។ នៅក្នុងឆ្នាំ១៩៧៣ដដែល ប្ដីរបស់ខ្ញុំបានស្លាប់ដោយសារជំងឺ។ ខ្ញុំចិញ្ចឹមកូនតែម្នាក់ឯង។ គ្រួសារ និងខ្ញុំបន្តស្នាក់នៅដីហែរ ហូតដល់កងទ័ពរំដោះខ្មែរក្រហមបានវាយកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

ខ្ញុំបានដឹងដំណឹងនេះពីអ្នកភូមិថា កងទ័ពរំដោះខ្មែរក្រហមបានវាយយកទីក្រុងភ្នំពេញ។ ខ្ញុំ និងគ្រួសារត្រឡប់មកភូមិវិញ។ ប៉ុន្មានខែក្រោយមក ប្រធានសហករណ៍បង្កើតក្រុមសាមគ្គី ដែលក្រោយមកបានប្ដូរទៅជា «សហករណ៍»។ វេលានេះខ្ញុំចាប់ផ្ដើមធ្វើការងារនៅក្នុងសហករណ៍។ កូនរបស់ខ្ញុំគឺនៅជាមួយម្ដាយរបស់ខ្ញុំមើលថែ។ នៅក្នុងភូមិ កងចល័តត្រូវបានបែងចែកជា៖ ទី១) កងកុមារ គឺចាប់ពីអាយុ៦ឆ្នាំដល់១១ឆ្នាំ។ ទី២) កងចល័តយុវជន គឺចាប់ផ្ដើមអាយុ១២ឆ្នាំដល់លើស២០ឆ្នាំ ទី៣) កង៣ គឺជាកងសម្រាប់អ្នកដែលបានរៀបការរួចហើយ (ក្រុមមនុស្សវ័យកណ្ដាល) ទី៤) កងវ័យជរា គឺសម្រាប់អ្នកដែលមានវ័យចំណាស់ និងមិនអាចធ្វើការបាន។ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅកងចល័តគឺ «កង៣» ដែលមានគ្នាប្រហែល៣០០នាក់។ សមមិត្ត វ៉ាត គឺជាប្រធានកង៣។ ខ្ញុំត្រូវបានចាត់ឲ្យជីកកាស់គល់ឈើ និងជីកដីនៅទីតាំងរួមមាន៖ ទំនប់រពាក់វាលទួលស្រែ និង ទំនប់ត្រួយចេក។ ខ្ញុំធ្វើការពីព្រលឹមទល់ព្រលប់ជារៀងរាល់ថ្ងៃ និងទទួលបានរបបអាហារតិចតួច និងគ្មានពេលមើលថែកូន និងឪពុកម្ដាយ។ ចាប់ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ការសម្លាប់រង្គាលបានចាប់ផ្ដើមនៅក្នុងភូមិ៖

**ដំណាក់កាលទី១៖** នៅខែកក្កដា ឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានមកដល់ភូមិ និងចាប់ផ្ដើមគ្រប់គ្រង។ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី ចាប់ផ្ដើមស្វែងរក និងចាប់ខ្លួនកម្មាភិបាលមូលដ្ឋានយកមកសម្លាប់។

**ដំណាក់កាលទី២៖** នៅខែកញ្ញា ឆ្នាំ១៩៧៧ បន្ទាប់ពីសម្លាប់កម្មាភិបាលមូលដ្ឋាន និងអ្នកពាក់ព័ន្ធ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបន្តដាក់គោលដៅកំណត់ និងចាប់ផ្ដើមចាប់ខ្លួនអ្នកភូមិ។ នៅក្នុងរយៈពេលនេះ ប្រជាជនខ្មែរអ៊ីស្លាមប្រហែល៥០គ្រួសារ ដែលកំពុងរស់នៅភូមិចំការសាមសិប ត្រូវបានខ្មែរក្រហមចាប់ និងដឹកយកទៅសម្លាប់ទាំងគ្រួសារ។ ទីតាំងសម្លាប់គឺនៅក្នុងឡថ្នាំជក់ និងនៅក្រោយភូមិ។

នៅចុងឆ្នាំ១៩៧៨ នៅពេលដែលខ្ញុំកំពុងធ្វើការនៅទំនប់ត្រួយចេក ខ្ញុំបានឮសំឡេងគ្រាប់ផ្លោង និងស្នូរកាំភ្លើងនៅសមរភូមិ ខ្ញុំរត់ត្រឡប់មកផ្ទះវិញ។ នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានប្រមូលអ្នកភូមិដើរទៅទំនប់ត្រួយចេក។ គោលបំណងនៃការប្រមូលអ្នកភូមិយកទៅទីតាំងខាងលើនេះ គឺដើម្បីសម្លាប់ចោល។ ខ្ញុំ និងគ្រួសារមិនទៅទេ និងបានរួចផុតពីការសម្លាប់របស់ខ្មែរក្រហម នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ភូមិនៅខែមករា ឆ្នាំ១៩៧៩។ នៅឆ្នាំ១៩៨២ ខ្ញុំនិងគ្រួសារ ចាប់ផ្ដើមប្រកបរបរកសិកម្ម ដោយបានដាំបន្លែ និងតម្បាញក្រមាលក់ ដើម្បីរកចំណូលចិញ្ចឹមជីវិតរហូតមកដល់បច្ចុប្បន្ន។

## ប៊ុន ចាន់ថុល



ប៊ុន ចាន់ថុល ភេទស្រី អាយុ៦២ឆ្នាំ អតីតកងចល័តនារី និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុក

កំពង់សៀម ខេត្តកំពង់ចាមបានពិពណ៌នាអំពីរយៈពេលមួយថ្ងៃធ្វើការនៅការដ្ឋានទំនប់។ ចាន់ថុល នៅតែចងចាំអំពីថ្ងៃដែលខ្លួនធ្វើការគ្មានពេលសម្រាក និងហូបមិនគ្រប់គ្រាន់ និងបានរៀបរាប់ថា៖ ខ្ញុំកើតនៅឆ្នាំ១៩៦០ នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំគឺជាកូនទី៥ក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន៦នាក់។ ខ្ញុំរៀននៅសាលាបឋមសិក្សាគគរ។ ខ្ញុំរៀនត្រឹមថ្នាក់ទី១០។ មួយខែក្រោយពីមានរដ្ឋប្រហារនៅខែមីនា ឆ្នាំ១៩៧០បាតុកម្មបានកើតមានឡើង។ ក្នុងស្ថានភាពប្របូកប្របល់បែបនេះ ខ្ញុំសម្រេចចិត្តឈប់រៀន និងនៅផ្ទះជួយការងារឪពុកម្តាយ។ ក្រោយមកទៀតកងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ក្នុងភូមិ។ បន្ទាប់មក ការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ផ្ទុះឡើងជាញឹកញាប់។ គ្រួសាររបស់ខ្ញុំរត់ភៀសខ្លួនចេញពីភូមិដើម្បីស្វែងរកទីកន្លែងសុវត្ថិភាព គឺនៅដីហៃដែលជាតំបន់រំដោះខ្មែរក្រហម។ នៅពេលនោះ ខ្ញុំមានអាយុប្រហែល ១២ឆ្នាំ។ ខ្ញុំបន្តរៀនសូត្រនៅតំបន់រំដោះខ្មែរក្រហម។ សមមិត្ត ប៉ូ បង្រៀនសិស្សប្រហែល ២០នាក់ នៅក្រោមផ្ទះរបស់អ្នកភូមិ។ សិស្សទាំងអស់ រៀនអក្សរ និងលេខនៅពេលព្រឹក ខណៈពេលដែលមិនមានការបង្រៀនអ្វីពេលរសៀលនោះឡើយ។ នៅចុងឆ្នាំ ១៩៧៣ គ្រួសារខ្ញុំវិលត្រឡប់មករស់នៅភូមិចំការសាមសិបវិញ។ ភូមិចំការសាមសិប ត្រូវបានទាហាន លន់ នល់ ទម្លាក់គ្រាប់បែកជាច្រើន។ នៅពេលដែលកងទ័ពរំដោះខ្មែរក្រហមវាយដណ្តើមយកបានទីរួមខេត្តកំពង់ចាមនៅចុងឆ្នាំ១៩៧៣ អ្នកភូមិជាច្រើនបានវិលត្រឡប់មកផ្ទះវិញ។ នៅឆ្នាំ១៩៧៤ ខ្ញុំរស់នៅក្នុងផ្ទះ និងធ្វើស្រែចម្ការ។ បន្ទាប់ពីកងទ័ពរំដោះខ្មែរក្រហមវាយចូលកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឃើញប្រជាជនថ្មីជាច្រើនដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញដើរតាមផ្លូវនៅមុខផ្ទះ។ ប្រជាជនជម្លៀសខ្លះបានសុំអ្នកភូមិស្នាក់នៅមួយយប់ ខណៈដែលប្រជាជនជាច្រើនផ្សេងទៀតបន្តដំណើរទៅមុខទៀត។ នៅចុងឆ្នាំ១៩៧៥ ខ្ញុំមានអាយុ១៣ឆ្នាំ។ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅកងចល័តស្រុក ដែលមានមនុស្សប្រហែល៣០០នាក់។ សមមិត្ត នីន គឺជាប្រធានកងចល័តស្រុក ខណៈពេលដែលសមមិត្ត ដា គឺជាប្រធានកងតូច។ ចាប់ពីឆ្នាំ១៩៧៦ ដល់ចុងឆ្នាំ១៩៧៨ ខ្ញុំត្រូវផ្ទេរទៅធ្វើការនៅការដ្ឋាន និងទំនប់ រួមមាន ល្អាក ត្រយចេក និងព្រៃទទឹង។ ខ្ញុំអាចចងចាំការងារពេញមួយថ្ងៃដែលខ្ញុំបានធ្វើនៅពេលនោះដូចតទៅ៖

- ប្រហែលម៉ោង៣ទៀបភ្លឺ សមមិត្ត ដា ផ្លុំកញ្ចែដាស់ និងក្រោកឈរតម្រង់ជួរ។ នៅក្នុងកងតូច មានសមមិត្តប្រហែល៣០នាក់។
- ប្រហែលម៉ោង៣:៣០នាទីទៀបភ្លឺ សមមិត្ត ដា ណែនាំឲ្យខ្ញុំ និងអ្នកគ្រប់គ្នាសម្រេចផែនការការងារ ជីកដី៣ម៉ែត្រការ៉េ និងទៅយកសម្ភារធ្វើការ។
- ប្រហែលម៉ោង៣:៤០នាទីទៀបភ្លឺ យើងទាំងអស់គ្នាដើរទៅការដ្ឋានធ្វើការ។ នៅយប់ខ្វះ ខ្ញុំមើលមុខគ្នាមិនស្គាល់នោះឡើយ។
- ប្រហែលម៉ោង៤ទៀបភ្លឺ ខ្ញុំចាប់ផ្តើមជីក និងរែកដី។
- ប្រហែលម៉ោង៦ព្រឹក ខ្ញុំជីកដីបានប្រហែលកន្លះម៉ែត្រការ៉េ។
- ប្រហែលម៉ោង៦:៤៥នាទីព្រឹក សមមិត្ត ដា ផ្លុំកញ្ចែដើម្បីឲ្យអ្នកគ្រប់គ្នាសម្រាកបន្តិច។ បន្ទាប់ពីសម្រាករួចហើយ សមមិត្ត ដាផ្លុំកញ្ចែម្តងទៀតដើម្បីឲ្យសញ្ញាដល់អ្នកគ្រប់គ្នាបន្តការងាររហូតដល់ពេលសម្រាកបាយថ្ងៃត្រង់។
- នៅម៉ោង១១ព្រឹក ខ្ញុំហូបបបរាវមួយចាន និងសម្រាក។
- ម៉ោង១២ថ្ងៃត្រង់ អ្នកគ្រប់គ្នាត្រូវត្រឡប់មកទីតាំងធ្វើការ និងធ្វើការរហូតគ្រប់ផែនការកំណត់ត្រឹមម៉ោង៥ល្ងាច។
- បើមិនទាន់គ្រប់ផែនការកំណត់ទេ ខ្ញុំត្រូវបន្តធ្វើការរហូតដល់ម៉ោង៦ឬ៧យប់។ អ្នកដែលបានជីកដីនិងរែកដីគ្រប់តាមផែនការកំណត់អាចទទួលបាន

របបអាហារ។

- ចាប់ពីម៉ោង៩ដល់ម៉ោង១០យប់ ខ្ញុំត្រូវយាមនៅកន្លែងសម្រាក។ បន្ទាប់ពីយាមរួចរាល់ ទើបខ្ញុំអាចចូលដេក។

សកម្មភាពការងារពេញមួយថ្ងៃ គឺនៅតែស្ថិតក្នុងការចងចាំរបស់ខ្ញុំ។ គ្រាមួយ ដែលខ្ញុំយល់ថាបាត់បង់អ្វីៗគ្រប់យ៉ាងនោះគឺនៅពេលដែលឪពុករបស់ខ្ញុំត្រូវបានចាប់យកទៅសម្លាប់។ សមមិត្ត ស្រ៊ុន បានប្រាប់ខ្ញុំថាឪពុកខ្ញុំត្រូវបានបណ្តើរទៅកន្លែងសម្លាប់នៅខាងទួលស្រែ។ ខ្ញុំបានរត់ទៅជួបគាត់ជាលើកចុងក្រោយ។ ខ្ញុំឃើញគាត់ត្រូវបានបណ្តើរដោយកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីទៅខាងទួលស្រែ។ ពេលនោះគឺជាលើកចុងក្រោយដែលខ្ញុំបានឃើញគាត់។ នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ ខ្ញុំបានរត់គេចខ្លួនត្រឡប់មកភូមិវិញ។ ខ្ញុំបានបន្តធ្វើស្រែចម្ការ ប៉ុន្តែឥឡូវនេះ ខ្ញុំមិនមានកម្លាំងធ្វើស្រែចម្ការបានទៀតទេ។ ខ្ញុំនៅផ្ទះ និងតែងតែចងចាំថ្ងៃដែលខ្ញុំធ្វើការនៅតាមទំនប់ និងវេលាពេលចុងក្រោយដែលខ្ញុំបានឃើញឪពុករបស់ខ្ញុំ។

## អេង ស្រ៊ី



អេង ស្រ៊ី ភេទស្រី អាយុ៦៧ឆ្នាំ អតីតកងចល័តនិងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលកំពុងរស់នៅភូមិកោះរការក្នុង ឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានរំឭកអំពីដំណើរជីវិតក្នុងរបបខ្មែរក្រហមថា ខ្ញុំកើតនៅឆ្នាំ១៩៥៥ នៅភូមិដំបងដែក ឃុំកោះរកា ស្រុកកំពង់សៀម។ ខ្ញុំជាកូនទីប្រាំក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន៧ នាក់។ កាលពីនៅវ័យក្មេង ខ្ញុំចូលរៀននៅសាលាបឋមសិក្សាដំបងដែក។ ខ្ញុំរៀនត្រឹមថ្នាក់ទី១១ចាស់ ប៉ុន្តែក្រោយមកទៀត ខ្ញុំឈប់រៀន។ នៅពេលនោះខ្ញុំមានអាយុប្រហែល១០ឆ្នាំ។ ខ្ញុំជួយការងារឪពុកម្តាយនៅផ្ទះ។ បន្ទាប់ពីមានរដ្ឋប្រហារនៅដើមឆ្នាំ១៩៧០ និងការផ្ទុះឡើងសង្គ្រាមរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម គ្រួសាររបស់ខ្ញុំភៀសខ្លួនចេញពីភូមិ។ ចាប់ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៣ គ្រួសាររបស់ខ្ញុំ រត់ភៀសខ្លួនពីកន្លែងមួយទៅកន្លែងមួយ រួមមានភូមិទួលស្រែ ភូមិរមាស ភូមិរកាគយ ភូមិដីឥដ្ឋ ភូមិទន្លូង និងភូមិមហាខ្ញូង។ អ្នកភូមិម្នាក់ប្រាប់គ្រួសារខ្ញុំថា ផ្ទះរបស់យើងត្រូវបានឆេះអស់ដោយសារតែការទម្លាក់គ្រាប់បែក។ នៅចុងឆ្នាំ១៩៧៣ ខ្ញុំដឹងថា ទីរួមខេត្តកំពង់ចាមត្រូវបានវាយបែក។ ក្រោយមកទៀត គឺនៅឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញក៏ត្រូវបានកាន់កាប់ដោយកងទ័ពរំដោះខ្មែរក្រហម។ បន្ទាប់មក ខ្ញុំនិងក្រុមគ្រួសារបានត្រឡប់មកភូមិវិញ និងសង់កូនខ្ទមមួយសម្រាប់រស់នៅ។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានដាក់ឲ្យធ្វើការនៅក្នុងសហករណ៍។ ខ្ញុំធ្វើការនៅក្នុងកងចល័តស្រុក ដោយបានទៅលើកទំនប់ និងជីកប្រឡាយនៅទីតាំងផ្សេងៗ រួមមានទំនប់រពាក់ ជើងព្រៃ ទំនប់ស្ទឹងជីនិត និងស្ទឹងត្រង់។ ខ្ញុំធ្វើការពីម៉ោង៧ព្រឹកដល់ម៉ោង៥ល្ងាច។ ចំណែកឯរបបអាហារ គឺខ្ញុំទទួលបានតែបបររាវមួយចាន។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានផ្លាស់ទៅលើកទំនប់ល្អាក។ ចុងឆ្នាំ១៩៧៨ ខ្ញុំរៀបការប្តី ដោយមានការរៀបចំពីអង្គការ។ នៅពេលនោះ មានគ្នាប្រហែល៣០គូដែលរៀបចំដោយអង្គការ។ ពិធីរៀបការនៅពេលនោះ គឺមានតែរយៈពេលប្រហែលមួយម៉ោងតែប៉ុណ្ណោះ។ ខ្ញុំប្រាប់អង្គការថា ខ្ញុំស្ម័គ្រចិត្តរៀបការ តាមការរៀបចំរបស់អង្គការ។ នៅថ្ងៃបន្ទាប់ គ្រួសារខ្ញុំ និងប្តីប្រពន្ធ៤គូទៀតត្រូវបានបញ្ជូនត្រឡប់ទៅរស់នៅភូមិក្រឡាវិញ។ អ្វីៗទាំងអស់គឺស្ថិតនៅក្រោមការរៀបចំរបស់អង្គការតែប៉ុណ្ណោះ។ នៅពេលដែលកងទ័ពវៀតណាមចូល

ជិតមកដល់នៅដើមឆ្នាំ១៩៧៩ ខ្ញុំនិងប្តីវិលត្រឡប់មកភូមិវិញ និងប្រកបរបរជាកសិកររហូតមកដល់បច្ចុប្បន្ននេះ។

## សាន់ ហឿង



សាន់ ហឿង ភេទប្រុស អាយុ៦២ឆ្នាំ អតីតកងចល័តស្រុក និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានចែករំលែកបទពិសោធន៍ និងរឿងរ៉ាវដែលខ្លួនបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមថា ខ្ញុំកើតនៅក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ខ្ញុំមានបងប្អូនប្រុសស្រីទាំងអស់ចំនួន៧ នាក់ (ប្រុស៣នាក់ និងស្រី៤នាក់)។ ខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារកសិករ។ ឪពុករបស់ខ្ញុំមានឈ្មោះ សាន់ ធុយ និងម្តាយមានឈ្មោះ ថន លុច។ ខ្ញុំរៀបការជាមួយ ប្អូន ចាន់ថុល និងមានកូនប្រុសស្រីចំនួន៣នាក់។ នៅវ័យកុមារ ខ្ញុំរៀនថ្នាក់ទី១០នៅសាលាបឋមសិក្សា គគរ។ ខ្ញុំអាចសរសេរ និងអានអក្សរបានបន្តិចបន្តួច។ នៅពេលដែលមានរដ្ឋប្រហារទម្លាក់សម្តេចឪនៅដើមឆ្នាំ១៩៧០ ខ្ញុំឈប់រៀន និងមកជួយធ្វើការងារផ្ទះឪពុកម្តាយ។ នៅឆ្នាំ១៩៧២ ខ្ញុំស្ម័គ្រចិត្តធ្វើជាកងឈ្លបឃុំ ដែលមានគ្នាទាំងអស់ចំនួន១០នាក់ក្នុងមួយក្រុម។ ភូមិចំការសាមសិប គឺជាសមរភូមិក្តៅរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ នៅពេលដែលសមរភូមិនៅកោះរកាផ្ទុះឡើង ខ្ញុំត្រូវបានបញ្ជូនទៅលីសែងអ្នករបួសយកមកព្យាបាលនៅមន្ទីរពេទ្យដែលស្ថិតនៅក្នុងតំបន់រំដោះខ្មែរក្រហម។ នៅឆ្នាំ១៩៧៣ ខ្ញុំត្រូវបានកងទ័ពខ្មែរក្រហមបញ្ជូនមកភូមិដើម្បីទៅប្រយុទ្ធនៅខ្សែត្រៀមជួរមុខ និងវាយផ្តាច់យកទីរួមខេត្តកំពង់ចាម។ នៅចុងឆ្នាំ១៩៧៣ និងដើមឆ្នាំ១៩៧៤ កងទ័ពរំដោះខ្មែរក្រហមវាយបែកបន្ទាយទាហានលន់ នល់ និងបន្តទៅទីរួមខេត្តកំពង់ចាម។ នៅក្នុងសមរភូមិវាយប្រយុទ្ធនេះ ខ្ញុំក៏ត្រូវបានបញ្ជូនទៅសែងអ្នករងរបួសដើម្បីព្យាបាលនៅមន្ទីរពេទ្យស្រុករការគយ និងខ្មោចកងទ័ពដែលបានស្លាប់នៅក្នុងសមរភូមិ។ នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានផ្លាស់មកកងចល័តស្រុកវិញ។ ចាប់ពីឆ្នាំ១៩៧៦ដល់ឆ្នាំ១៩៧៨ ខ្ញុំទៅធ្វើការនៅកងចល័តជាច្រើនកន្លែងរួមមាន៖

- ឆ្នាំ១៩៧៦៖ ខ្ញុំផ្លាស់ទៅធ្វើការដកស្ទូង និងកាប់ព្រៃនៅស្រុកព្រៃឈរ និងស្រុកជើងព្រៃ។ ខ្ញុំចាប់ផ្តើមធ្វើការចាប់ពីម៉ោង៧ ព្រឹកដល់ម៉ោង១១ថ្ងៃត្រង់ និងចូលធ្វើការវិញចាប់ពីម៉ោង១ ដល់ម៉ោង៥ ល្ងាច ទើបឈប់។
- ឆ្នាំ១៩៧៧៖ ខណៈពេលខ្ញុំផ្លាស់មកធ្វើការនៅទំនប់ត្រួយចេក ខ្ញុំកើតមានជំងឺគ្រុនចាញ់ និងត្រូវបានបញ្ជូនមកព្យាបាលនៅក្នុងវិហារចាមស្ថិតនៅភូមិកំពង់ក្របី។ ខ្ញុំទទួលបានថ្នាំលេប១ថ្ងៃ២ដង និងព្យាបាលជិត២ខែ។ បន្ទាប់ពីធូរស្រាលបន្តិច ខ្ញុំត្រូវបានចាត់តាំងឲ្យទៅឃ្វាលគោចំនួន២០០ក្បាល។
- ឆ្នាំ១៩៧៨៖ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅឡផ្ដដូ ស្ថិតក្រោមការគ្រប់គ្រងដោយកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចំនួន២នាក់។ ខ្ញុំមិនចាំឈ្មោះរបស់កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីទាំងនោះទេ។នៅឆ្នាំ១៩៧៩ ខ្ញុំឃើញរថក្រោះនិងកងទ័ពវៀតណាមស្ថិតនៅត្រើយទន្លេបិទបានបាញ់ផ្លោងមកលើកងទ័ពខ្មែរក្រហម។ នៅពេលនោះ ខ្ញុំត្រូវបានជម្លៀសទៅភ្នំហាន់ជ័យ និងរពាក់។ ដោយដឹងអំពីស្ថានភាពមិនស្រួល ខ្ញុំលួចរត់មកផ្ទះវិញ បន្ទាប់ពីបានដេកមួយយប់។

## ទូច វ៉ា



ទូច វ៉ា ភេទប្រុស អាយុ៥៦ឆ្នាំ អតីតកុមារមូលដ្ឋាន និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានរំឭកអំពីការចងចាំពីកុមារភាពនៅក្នុងរបបខ្មែរក្រហមថា ខ្ញុំឈ្មោះ ទូច វ៉ា កើតនៅភូមិរម្លួល ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ឪពុករបស់ខ្ញុំឈ្មោះ ងិច ទូច និង ម្តាយឈ្មោះ ងាន គីន។ ខ្ញុំមានបងប្អូនប្រុសស្រីទាំងអស់ចំនួន៦នាក់។ ខ្ញុំកើតនៅក្នុងគ្រួសារកសិករ និងមិនបានរៀនសូត្រឡើយ ពីព្រោះភូមិរបស់ខ្ញុំត្រូវបានប្រែក្លាយទៅជាសមរភូមិរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម បន្ទាប់ពីមានរដ្ឋប្រហារនៅឆ្នាំ១៩៧០។ ឪពុកម្តាយបានពរខ្ញុំរត់ចេញពីភូមិ ដើម្បីរកកន្លែងសុវត្ថិភាព។ នៅឆ្នាំ១៩៧៤ ខ្ញុំ និងគ្រួសារបានវិលត្រឡប់ចូលភូមិវិញ។ នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានដាក់នៅក្នុងកងកុមារ ដើម្បីរើសលាមកសត្វ កាត់ទន្ទ្រានខែត្រធ្វើជីដាក់ស្រែ។ ខ្ញុំរែកសំណាបយកទៅឲ្យអ្នកស្ទូងនៅវាលស្រែគោកតាង្គួន។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានផ្លាស់ទៅធ្វើការនៅរោងចិញ្ចឹមមាន់។ នៅពេលនោះ មានកុមារទាំងអស់សរុបចំនួន១០នាក់ ដើម្បីមើលថែ និងសម្អាតរោងមាន់។ នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានផ្លាស់ប្តូរទៅរោងបាយ ដោយបានដើរបេះត្រួយអំពិលសម្រាប់ចុងភៅដាំស្ល។ នៅពេលនោះ ខ្ញុំហូបតែបបរមួយកូនចានប៉ុណ្ណោះ។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានបញ្ជូនទៅហ្វឹកហ្វឺនក្បួនសឹក ដើម្បីត្រៀមវាយទប់កងទ័ពវៀតណាម។ នៅក្នុងមួយក្រុម មានកងទ័ពហ្វឹកហ្វឺនចំនួន២០នាក់។ នៅដើមឆ្នាំ១៩៧៩ កងទ័ពខ្មែរក្រហមទទួលរងបរាជ័យដោយកងទ័ពវៀតណាមនៅមាត់ទន្លេមេគង្គ។ ខ្ញុំលួចរត់មកផ្ទះដើម្បីជួបជាមួយឪពុកម្តាយ និងបងប្អូនវិញ។

## ភួង ស្រ៊ន់



ភួង ស្រ៊ន់ ភេទស្រី អាយុ៥៣ឆ្នាំ អតីតកងកុមារមូលដ្ឋាន និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិដំបងដែក ឃុំកោះរការ ស្រុកកំពង់សៀម ខេត្តកំពង់ចាម បាននិយាយប្រាប់អំពីការចងចាំពីកុមារភាពរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមថា ខ្ញុំកើតនៅភូមិដំបងដែក ឃុំកោះរការ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំរៀបការជាមួយប្តីឈ្មោះទូច វ៉ាន់ និងមានកូនប្រុសស្រីទាំងអស់ចំនួន៤នាក់។ ខ្ញុំមានឪពុកឈ្មោះ ភួង ផន និងម្តាយឈ្មោះ ផ្លុក លី។ ខ្ញុំមានបងប្អូនប្រុសស្រីទាំងអស់ចំនួន៦នាក់។ កាលពីវ័យកុមារ ខ្ញុំរៀនសូត្រត្រឹមថ្នាក់ទី៩ចាស់នៅសាលាបឋមសិក្សាដំបងដែក។ ក្រោយមកទៀត ខ្ញុំឈប់រៀន ពីព្រោះឪពុកម្តាយមានជីវភាពខ្វះខាត។ បន្ទាប់ពីឈប់រៀន ខ្ញុំមកជួយការងារឪពុកម្តាយនៅផ្ទះវិញ។ នៅពេលនោះ ខ្ញុំប្រកបរបរជាអ្នកលក់ទឹកអំពៅដើម្បីយកប្រាក់ផ្គត់ផ្គង់ជីវភាពខ្វះខាតនៅក្នុងគ្រួសារ។ នៅពេលនោះ ខ្ញុំមានអាយុជិត១០ឆ្នាំ។ ខាងក្រោមនេះគឺជាការចងចាំរបស់ខ្ញុំអំពីការឆ្លុះឡើងនូវសង្គ្រាម និងរបបខ្មែរក្រហម៖

- ឆ្នាំ១៩៧០៖ ខ្ញុំដឹងខ្លះអំពីព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចឪ

- ឆ្នាំ១៩៧១៖ កងទ័ពរំដោះខ្មែរក្រហមចូលមកដល់ក្នុងភូមិ។
- ឆ្នាំ១៩៧៣៖ សង្គ្រាមរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ផ្ទុះកាន់តែខ្លាំងឡើងៗ ការបាញ់ផ្លោង ការទម្លាក់គ្រាប់បែក បណ្ដាលឲ្យផ្ទះរបស់អ្នកភូមិឆេះ។ គ្រួសារខ្ញុំបានរត់ចេញពីភូមិ តាមរទេះគោទៅដល់ភូមិថ្មី ដែលជាតំបន់រំដោះរបស់ខ្មែរក្រហម។
- ឆ្នាំ១៩៧៥៖ គ្រួសារខ្ញុំវិលត្រឡប់មកភូមិវិញ។ នៅចុងឆ្នាំ១៩៧៥ ឪពុកម្ដាយរបស់ខ្ញុំ ត្រូវបានចាត់តាំងធ្វើការនៅសហករណ៍។ បងប្អូនរបស់ខ្ញុំត្រូវទៅធ្វើការនៅតាមកងចល័តរៀងៗខ្លួន។ ចំណែកឯខ្ញុំត្រូវចូលធ្វើការនៅកងកុមារ គឺដើរកាត់ស្លឹកឈើ និងរើសអាចម៍គោ ធ្វើជីដាក់ស្រែ។ មិនយូរប៉ុន្មាន ឪពុករបស់ខ្ញុំបានធ្លាក់ខ្លួនឈឺ និងស្លាប់ដោយសារតែការហូបអាហារមិនគ្រប់គ្រាន់ និងគ្មានថ្នាំព្យាបាល។
- ឆ្នាំ១៩៧៦៖ ភូមិដបងដែកត្រូវបានទឹកជំនន់ជន់លិច។ គ្រួសាររបស់ខ្ញុំត្រូវបានបញ្ជូនទៅភូមិទួលស្រែ។
- ឆ្នាំ១៩៧៧៖ ម្ដាយ និងបងប្អូនរបស់ខ្ញុំ ត្រូវទៅធ្វើការងាររួមមាន៖ កាប់ឆ្ការព្រៃដើម្បីពង្រីកផ្ទៃដីដាំដុះស្រូវ និងភ្ជួររាស់ដីដាំស្រូវ។ បន្ទាប់ពីប្រមូលផលស្រូវរួចរាល់ គ្រួសារខ្ញុំត្រូវបានបញ្ជូនមកភូមិវិញ។
- ឆ្នាំ១៩៧៨៖ គ្រួសារខ្ញុំត្រូវបានផ្លាស់ទៅរស់នៅ និងលើកទំនប់ព្រែកជីក អស់រយៈពេល៣ខែ។
- ឆ្នាំ១៩៧៩៖ ខណៈពេលដែលគ្រួសារខ្ញុំធ្វើការនៅការដ្ឋានទំនប់ព្រែកជីក កងទ័ពវៀតណាមចូលមកដល់។ នៅពេលនោះគ្រួសាររបស់ខ្ញុំរួចផុតពីសេចក្ដីស្លាប់ និងធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។



ទិដ្ឋភាពថតពីលើអាកាស នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឯកអគ្គរដ្ឋទូតហ្វីលីពីនប្រចាំកម្ពុជា ទស្សនកិច្ចមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម និងទីតាំងស្រាវជ្រាវ

**ទូច វណ្ណេត**





លោកស្រី ម៉ារៀ អាមេលីតា ស៊ី. អាគីណូ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋហ្វីលីពីនប្រចាំព្រះរាជាណាចក្រកម្ពុជា បានធ្វើដំណើរមកទស្សនកិច្ចមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម និងទីតាំងស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។
(ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

លោកស្រី ម៉ារៀ អាមេលីតា ស៊ី. អាគីណូ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋហ្វីលីពីនប្រចាំព្រះរាជាណាចក្រកម្ពុជា បានធ្វើដំណើរមកទស្សនកិច្ចមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដោយមានការទទួលការស្វាគមន៍ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម កាលពីខែធ្នូ ឆ្នាំ២០២២ កន្លងមក។

បន្ទាប់ពីចូលទស្សនាការិយាល័យ បន្ទប់តម្កល់ឯកសារខ្មែរក្រហម បណ្ណាល័យ និងសាលពិព័រណ៍រូបថតនៃមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមរួចមក លោកស្រីឯកអគ្គរដ្ឋទូតហ្វីលីពីន អមដំណើរដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានចុះទៅកាន់ទីតាំងស្រាវជ្រាវផ្សេងៗទៀត រួមមាន ទី១) ចេតិយរំឭកសម្រាប់សហគមន៍ស្ថិតនៅវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម, ទី២) វត្តរការគយដែលជាអតីតសមរភូមិក្តៅរវាងទាហាន លន់ នល់

និងកងទ័ពរំដោះខ្មែរក្រហមចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧២ និង ទី៣) សហគមន៍ជនជាតិចាម នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ដែលជាទីតាំងតម្បាញសូត្រចាម។

ដំណើរទស្សនកិច្ចរបស់លោកស្រីឯកអគ្គរដ្ឋទូតហ្វីលីពីន ចាប់ផ្តើមពីវេលាម៉ោង១០ព្រឹក ដល់វេលាម៉ោង៤រសៀល។













លោកស្រី ម៉ារៀ អាមេលីតា ស៊ី. អាគីណូ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋហ្វីលីពីនប្រចាំព្រះរាជាណាចក្រកម្ពុជា បានធ្វើដំណើរមកទស្សនកិច្ចមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និងទីតាំងស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។
( ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»

## កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន ស្គន់

*លី ដេវីត*



សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែន ស្គន់ ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ( លីដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមនៃមជ្ឈមណ្ឌលឯកសារកម្ពុជាចុះចែកសៀវភៅ«សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បោះពុម្ពដោយព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ចំនួន៣១៥ក្បាល ដល់សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី១២នៃវិទ្យាល័យ ហ៊ុន សែន ស្គន់ដែលមានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៦ ក្នុងភូមិតាសែន ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៣។ បច្ចុប្បន្ន វិទ្យាល័យ ហ៊ុន សែន ស្គន់ មានសិស្សានុសិស្សសិក្សាសរុបចំនួនជាង១០០០នាក់ ក្នុងនោះមានសិស្សានុសិស្សកំពុងរៀនថ្នាក់ទី១២ ចំនួន៣១៥នាក់។





*សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែន ស្គន់ ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (លីដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ជាកិច្ចចាប់ផ្តើម លោក ខូវ ណារិន នាយករងវិទ្យាល័យ ហ៊ុន សែន ស្គន់ ទទួលស្វាគមន៍ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និងថ្លែងអំណរគុណចំពោះការចុះចែកសៀវភៅនេះ។ លោកបន្តថា សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» គឺជាឯកសារប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់សម្រាប់សិស្សានុសិស្សរៀនថ្នាក់ទី១២ ដើម្បីបង្កើនចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជា ជាការត្រៀមលក្ខណៈក្នុងការប្រឡងមធ្យមសិក្សាទុតិយភូមិ។ ជាចុងក្រោយ ខ្ញុំតំណាងគណៈគ្រប់គ្រងវិទ្យាល័យ សូមថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៃមជ្ឈមណ្ឌលឯកសារកម្ពុជាចំពោះការផ្តល់សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» និងសៀវភៅមួយចំនួនទៀត សម្រាប់តម្កល់ទុកនៅក្នុងបណ្ណាល័យសិក្សារបស់វិទ្យាល័យ»។

ជាកិច្ចបន្ត លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ធ្វើការណែនាំខ្លួន និងក្រុមការងារ។ ឆ្លៀតឱកាសនេះ លោក ស៊ាង ចិន្តា លើកឡើងអំពីមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលជាសាខារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងតួនាទីរបស់មជ្ឈមណ្ឌលស្រាវជ្រាវនេះ។ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តអនុវត្តកិច្ចការងារស្នូល

របស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅតាមមូលដ្ឋាន ក្នុងការចងក្រងឯកសារ អប់រំ និងផ្សព្វផ្សាយឯកសារស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលគ្រប់គ្រងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ បន្ទាប់ពីការផ្តល់បទបង្ហាញយ៉ាងខ្លីអំពីមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម លោក ស៊ាង ចិន្តា ពន្យល់អំពីសារសំខាន់នៃសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាឯកសារប្រវត្តិសាស្ត្រសម្រាប់សិស្សានុសិស្ស ដើម្បីធ្វើការសិក្សាឈ្វេងយល់ចេញពីព្រះរាជកំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងព្រះរាជដំណើរអមព្រះបាទនរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរមកកាន់ប្រទេសកម្ពុជា។

ជាចុងក្រោយ លោក ស៊ាង ចិន្តា លើកទឹកចិត្តសិស្សានុសិស្សដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ប្រឹងប្រែងសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រ និងថែរក្សាសៀវភៅនេះជាឯកសារប្រវត្តិសាស្ត្រផ្ទាល់ខ្លួន។

បន្ទាប់ពីទទួលបានសៀវភៅ«សាក្សីប្រវត្តិសាស្ត្រ» សិស្សានុសិស្សបានបង្ហាញចំណាប់អារម្មណ៍ និងទស្សនយល់ឃើញដូចខាងក្រោម៖

**មឿន ស្រីពី** អាយុ ១៨ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យ ហ៊ុនសែន ស្គន់ រៀបរាប់ថា៖ «ខ្ញុំសប្បាយចិត្ត នៅពេលដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»នេះ។ ខ្ញុំយល់ឃើញថាសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» គឺពិតជាល្អសម្រាប់រូបខ្ញុំនិងមិត្តភក្តិផ្សេងទៀតដើម្បីបង្កើនការយល់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រនាពេលនោះ។ អ្វីដែលខ្ញុំទទួលបានពីសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» នេះ ខ្ញុំនឹងយកទៅចែករំលែកបន្តទៅកាន់អ្នកដែលខ្ញុំស្គាល់ និងសិស្សប្អូនជំនាន់ក្រោយទៀត។ ជាចុងក្រោយ ខ្ញុំសូមអរគុណដល់ព្រះរាជបណ្ណាល័យ ហ្វូម៉ែ ដែលបានផ្តល់សៀវភៅនេះមកខ្ញុំ»។

**ផាង ភ័ក្រ** អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យ ហ៊ុន សែន ស្គន់ លើកឡើងថា «ខ្ញុំមានអារម្មណ៍សប្បាយចិត្ត និងមានមោទកភាពក្នុងការទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាព្រះរាជនិពន្ធផ្ទាល់របស់ហ្វូងយាយ។ ខ្ញុំសំណូមពរទៅកាន់ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ បន្តចែកសៀវភៅប្រវត្តិសាស្ត្រដ៏ល្អនេះទៅកាន់សិស្សានុសិស្សផ្សេងទៀត នៅវិទ្យាល័យរបស់ខ្ញុំដែលមិនទាន់ទទួលបាន»។

**ទុយ ស្រីណាច** អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យ ហ៊ុន សែន ស្គន់រំលេចពីការចង់ដឹងព្រះរាជដំណើររបស់ព្រះអង្គទាំងទ្វេរនាពេលនោះថា នៅពេលដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ខ្ញុំមានអារម្មណ៍រីករាយ។ សៀវភៅនេះបានផ្តល់ចំណេះដឹងដល់ខ្ញុំក្នុងបរិបទប្រវត្តិសាស្ត្រពេលដែល ហ្វូងយាយអមព្រះរាជដំណើរសម្តេចតាមកកាន់មាតុប្រទេសនាពេលដែលប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងភ្នក់ភ្លើងសង្គ្រាម។ សំណូមពររបស់ខ្ញុំគឺសូមឲ្យព្រះរាជបណ្ណាល័យ ហ្វូងម៉ែ បង្កើតកម្មវិធីចុះចែកសៀវភៅបន្ថែមទៀត។



សិស្សានុសិស្សវិទ្យាល័យ ហ៊ុនសែន ស្គន់ ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (លីដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ស្មេះ ហានីហ្វះ ៖ គ្រួសារខ្ញុំគឺជាអ្នកតម្បាញ

***មីន សាណាស់***



*ស្មេះ ហានីហ្វះ រស់នៅឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ស្មេះ ហានីហ្វះ ភេទស្រី អាយុ ៧៣ឆ្នាំ ខ្ញុំមានទីកន្លែងកំណើតនិងរស់នៅភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧១ ខ្ញុំរៀបការជាមួយប្ដីឈ្មោះ ម៉ាត់ យូណេស មានមុខរបរគឺជាជាងសាងសង់ផ្ទះឈើ និងមានកូនចំនួន៤នាក់ គឺប្រុសចំនួន២នាក់ និង ស្រីចំនួន២នាក់។ ក្រោយរៀបការបានរយៈពេលបីថ្ងៃ ក៏មានការទម្លាក់គ្រាប់បែកចំផ្ទះរបស់ខ្ញុំរស់នៅ បណ្ដាលឲ្យបាត់បង់ទ្រព្យសម្បត្តិអស់ ប៉ុន្តែមិនបណ្ដាលឲ្យស្លាប់មនុស្សទេ។ គ្រួសាររបស់ខ្ញុំបានផ្អាកត្បាញតាំងពីពេលនោះមក។

គ្រួសារខ្ញុំគឺជាអ្នកត្បាញសំពត់សូត្រ ក្រមា និងសារុងសូត្រ នៅភូមិកំពង់ក្របី តាំងពីមុនសម័យបារាំងកាន់កាប់ស្រុកភូមិម្ល៉េះ។ ចំណែកម្ដាយខ្ញុំគឺជាអ្នកជំនាញខាងពិនិត្យសំពត់សូត្រ ត្បាញ ចងគោមពណ៌ និងជាអ្នកទិញសំពត់សូត្រ សារុង ពីអ្នកភូមិកំពង់ក្របីយកទៅលក់នៅទីរួមខេត្តកំពង់ចាម។ ម្ដាយខ្ញុំដឹងថាគោមសំពត់តូចៗគឺជាតម្រូវការរបស់បងប្អូនជនជាតិខ្មែរ ហើយគោមមានផ្កាធំៗ គោមរូបក្បាក ឈរធំៗ សម្រាប់បងប្អូនជនជាតិចាម ជាហេតុនាំឲ្យគាត់មានភាពងាយស្រួលក្នុងការលក់នៅតាមទីផ្សារ។ ចំណែកអ្នកភូមិក៏មានការងារត្បាញច្រើន ព្រោះសំពត់លក់ដាច់ច្រើន។

អ្នកបង្កើតគោម ឬចងគឺសុទ្ធតែអ្នកឆ្លាតវៀសវៃ អត់ធ្មត់ ទើបអាចរចនាគោមសំពត់សូត្រយ៉ាងល្អប្រណិត ប្លែកៗ ថ្មីសម្រាប់អ្នកប្រើប្រាស់។ ប្រហែលនៅឆ្នាំ១៩៧២ វត្តមានកងទ័ពរំដោះខ្មែរក្រហមចូលមកគ្រប់គ្រងក្នុងភូមិរបស់ខ្ញុំ ហើយគ្រួសារខ្ញុំស្ថិតក្នុងបញ្ជីអ្នកមានធនធាន និងស្ថិតក្រោមការតាមដានរបស់កងទ័ពរំដោះ។ ក្រុមគ្រួសារខ្ញុំត្រៀមខ្លួនរត់ចេញពីភូមិដោយឃើញថា ជារៀងរាល់យប់កងទ័ពរំដោះខ្មែរក្រហមមកហៅមនុស្សប្រុសដែលមានចំណេះដឹងក្នុងភូមិឲ្យទៅជាមួយពួកគេ។ ប្រសិនជាមិនចុះពីលើផ្ទះ កងទ័ពរំដោះខ្មែរក្រហមយកកាំបិតផ្គាក់រុកពីក្រោមផ្ទះ។ នៅដើមឆ្នាំ១៩៧៤ គ្រួសារខ្ញុំរត់គេចទៅរស់នៅក្នុងខេត្តកំពង់ចាម បន្ទាប់មកទៅរស់នៅតាមភូមិ ដើម្បីលាក់ប្រវត្តិរូបឪពុករបស់ខ្ញុំដែលជាអតីតទាហាន លន់ នល់។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមកាន់កាប់ប្រទេសបានទាំងស្រុង ដូច្នេះគ្រួសារ

ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅធ្វើការនៅខាងកំពង់ថ្ម ខេត្តកំពង់ធំ។

នៅឆ្នាំ១៩៧៩ ខ្ញុំនិងប្ដីបាននាំកូនៗត្រឡប់មកស្រុកកំណើតវិញ ប៉ុន្តែផ្ទះ និងដីរបស់យើងមានអ្នកចូលមករស់នៅ និងកាន់កាប់អស់ទៅហើយ ហេតុនេះគ្រួសារខ្ញុំបានសុំដីណាដែលទំនេរពីរដ្ឋអំណាចដើម្បីសង់រោងតូចមួយសម្រាប់រស់នៅបណ្ដោះអាសន្ន។ ពេលនោះប្ដីរបស់ខ្ញុំមានជំនាញផ្នែកសាងសង់ស្រាប់ក៏ដើរសង់ផ្ទះអ្នកភូមិដោយប្ដូរពីថ្លៃឈ្នួលជាប្រាក់មកយក ពោត អង្ករ ឬសាច់ មកផ្គត់ផ្គង់គ្រួសារ។

នៅឆ្នាំ១៩៨២ ខ្ញុំចាប់ផ្ដើមត្បាញក្រមាអំបោះសម្រាប់ប្រើប្រាស់ក្នុងផ្ទះ និងលក់យកប្រាក់ខ្លះ។ បន្ទាប់មកប្រហែលជាឆ្នាំ១៩៩២ ខ្ញុំចាប់ផ្ដើមត្បាញសំពត់សូត្រឡើងវិញ។ ខ្ញុំបានបង្រៀនកូនស្រីខ្ញុំទាំងពីរនាក់ឲ្យចេះត្បាញ ជ្រលក់ពណ៌ ចងគោម ប៉ុន្តែកូនៗរបស់ខ្ញុំមិនចេះស្ទាត់ទេ។ ក្មេងៗជំនាន់ក្រោយចេះតែត្បាញមួយមុខប៉ុណ្ណោះ។ ចំពោះគោម ដែលខ្ញុំធ្លាប់ត្បាញ និងចងគោម មានដូចជា គោមសណ្ដាន់, គោមក្បាកមួយ ឬ ក្បាកពីរ, គោមមាន់, គោមសំរោង, គោមខ្ទុងមិញ និងគោមជាច្រើនប្រភេទទៀត។ គោមទាំងនេះ គឺជាគោមដែលជនជាតិចាមចូលចិត្តធ្វើ ហើយវាសុទ្ធតែជាប្រភេទគោមធំៗ ប្រសិនបើជាគោមតូចៗ គឺខ្ញុំធ្វើសម្រាប់លក់ចេញឲ្យបងប្អូនខ្មែរ។ ចំណែកពណ៌គឺជំនាន់១៩៩០ គឺខ្ញុំនឹងអ្នកភូមិប្រើល័ក្តធម្មជាតិ ហើយល័ក្តខ្មែរមានពណ៌ដូចជា លឿង ក្រហម បៃតង ស្វាយ ខ្មៅ និង ខៀវ។



សំពត់សូត្រដែលជនជាតិចាមត្បាញនៅស្រុកកោះសូទិន ខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឧបករណ៍រវៃអំបោះរបស់ជនជាតិចាមនៅស្រុកកោះសូទិន ខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម៉ៅ វណ្ណា ៖ ខ្ញុំនៅចាំពាក្យសម្តីរបស់មិត្ត ជាច និយាយមុនពេលខ្មែរក្រហមនាំគាត់ទៅសម្លាប់ថា «ខ្មែរក្រហមមិនដែលសាហាវយ៉ាងហ៊ីក្លែរនោះទេ»

***សាំង ចិន្តា***



ម៉ៅ វណ្ណា អាយុ៦២ឆ្នាំ រស់នៅក្នុងភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ។ (សាំង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ម៉ៅ វណ្ណា ភេទស្រី អាយុ៦២ឆ្នាំ រស់នៅក្នុងភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំរៀបការជាមួយប្តីឈ្មោះ សុខ ងុយ និងមានកូនប្រុសស្រីចំនួន៣នាក់។ ខ្ញុំគឺជាអតីតនាយកសាលាបឋមសិក្សាទីប្រជុំ ដែលស្ថិតនៅភូមិទី៨នេះ។ ខ្ញុំមានឪពុកឈ្មោះ ម៉ៅ លាងគ្រី ដែលជាគ្រូបង្រៀននៅវិទ្យាល័យជម្ពូវ័ន និងម្តាយឈ្មោះ ម៉ៅ សុផល គឺជាមេផ្ទះ។ ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំត្រូវបានខ្មែរក្រហមសម្លាប់ គឺនៅសល់តែរូបខ្ញុំនិងប្អូនម្នាក់ប៉ុណ្ណោះដែលរួចរស់ជីវិត។ នៅវ័យកុមារ ខ្ញុំទៅរៀននៅសាលាបឋមសិក្សាចុងកោះរហូតដល់ថ្នាក់ទី៧ចាស់។ នៅពេលនោះ ខ្ញុំស្នាក់នៅជាមួយយាយនៅក្នុងភូមិកំណើតចំណែកឯឪពុកម្តាយ និងបងប្អូនផ្សេងទៀតរបស់ខ្ញុំរស់នៅទីក្រុងភ្នំពេញ។ ប៉ុន្មានខែបន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មានអ្នកភូមិបានទៅចូលរួមដង្ហែបាតុកម្មប្រឆាំងនឹងរដ្ឋប្រហារនេះនៅទីរួមខេត្តកំពង់ចាម។ ខ្ញុំមិនបានទៅចូលរួមទេ គឺខ្ញុំស្នាក់នៅផ្ទះជាមួយយាយរបស់ខ្ញុំ។ ក្រោយមកទៀត កងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ និងបានស្នាក់

នៅក្រោមផ្ទះរបស់អ្នកភូមិទី៨។ នៅចុងឆ្នាំ១៩៧០ និងដើមឆ្នាំ១៩៧១ សង្គ្រាមរវាង ទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើងជាច្រើនសមរភូមិនៅស្រុកកោះសូទិន។ ចាប់ពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៣ ទាហាន លន់ នល់ បានបើកការវាយប្រហារទៅលើកងទ័ពរំដោះខ្មែរក្រហម ដែលឈរជើងនៅក្នុងស្រុកកោះសូទិនកាន់តែខ្លាំងឡើងៗ ដោយមានការព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្ញុំ ឪពុកម្តាយរបស់ខ្ញុំបានមកយកខ្ញុំទៅរស់នៅជាមួយពួកគាត់នៅជាយក្រុងភ្នំពេញវិញ។ ខ្ញុំបានចូលរៀនបន្តនៅសាលាបឋមសិក្សាជម្ពូវ័នរហូតដល់ថ្នាក់ទី៨ នៅវិទ្យាល័យជម្ពូវ័នដដែល។

នៅដើមឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំបានទទួលដំណឹងថាកងទ័ពខ្មែរក្រហមបានចូលមកកៀកទីក្រុងភ្នំពេញហើយ។ នៅពេលនោះ ឪពុករបស់ខ្ញុំបានប្រាប់ម្តាយខ្ញុំឲ្យនាំកូនៗចូលក្នុងក្រុងភ្នំពេញ និងទៅស្នាក់នៅផ្ទះម្តុំទួលស្វាយព្រៃបណ្តោះអាសន្ន។ ចំណែកឯឪពុករបស់ខ្ញុំជិះកង់មកតាមក្រោយ។ បន្ទាប់ពីស្នាក់នៅមិនបានប៉ុន្មានផង ទីក្រុងភ្នំពេញត្រូវបានកងទ័ពរំដោះខ្មែរក្រហមវាយបែក និងគ្រប់គ្រង។ គ្រួសាររបស់ខ្ញុំ គឺស្ថិតនៅក្នុងចំណោមគ្រួសាររាប់ពាន់ផ្សេងទៀត ដែលត្រូវបានខ្មែរក្រហមជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ។ ឪពុកម្តាយរបស់ខ្ញុំសម្រេចចិត្តនាំកូនៗត្រឡប់មកភូមិកំណើតនៅកោះសូទិន ដើម្បីរស់នៅជាមួយយាយរបស់ខ្ញុំវិញ។ គ្រួសាររបស់ខ្ញុំបានធ្វើដំណើរជាច្រើនថ្ងៃទើបមកដល់ភូមិ។

បន្ទាប់ពីមកដល់ភូមិវិញ គ្រួសាររបស់ខ្ញុំត្រូវបានប្រជាជនមូលដ្ឋានហៅថាប្រជាជន១៧មេសា ព្រោះមានប្រវត្តិរូបធ្លាប់ធ្វើជាគ្រូបង្រៀននៅក្នុងរបបចាស់។ បន្ទាប់មក ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅការដ្ឋានភូមិតាណុង គឺជាកន្លែងប្រមូលផ្តុំប្រជាជនដែលជាប់និន្នាការជាមួយរបបលន់នល់ ដើម្បីលត់ដំខ្លួន។ នៅពេលនោះ ខ្ញុំមិនបានទៅនៅជាមួយឪពុកម្តាយ និងបងប្អូនទេ ពីព្រោះយាយរបស់ខ្ញុំបានប្រាប់មេភូមិថា ខ្ញុំគឺជាអ្នកមូលដ្ឋានចាស់។

នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានដាក់ឲ្យធ្វើការនៅក្នុងកងចល័តនារី គឺធ្វើស្រែ ជីកដី និងលើកទំនប់។ នៅឆ្នាំ១៩៧៧ កងចល័តនារីរបស់ខ្ញុំត្រូវបានផ្លាស់ទីកន្លែងធ្វើការទៅការដ្ឋានឆ្នេរត្រវិញ ដែលនៅទីកន្លែងនោះ ខ្ញុំស្ទើរតែត្រូវបានចាប់យកទៅសម្លាប់ និងជាកន្លែងដែលខ្ញុំឃើញផ្ទាល់ភ្នែកពីទុក្ខវេទនារបស់គ្រួសារខ្ញុំ។ ខ្ញុំតែងតែលួចទៅជួបឪពុកម្តាយរបស់ខ្ញុំក្នុងស្ថានភាពស្គមស្គាំង និងភិតភ័យ។ ខ្ញុំបានត្រឹមតែសួរសុខទុក្ខ និងមិនអាចធ្វើអ្វីបានលើសពីនេះទេ។ ចំណែកឯកងចល័តនារីរបស់ខ្ញុំវិញ ត្រូវទៅជីកដី លើកដី និងធ្វើស្រែគ្មានពេលសម្រាក និងគ្មានអាហារហូបគ្រប់គ្រាន់។ កងចល័តនារីកន្លែងខ្ញុំធ្វើការ មានសមាជិកមិត្តនារីទាំងអស់៩៧នាក់។ នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកដល់ និងចាប់ផ្តើមចាប់កម្មាភិបាលមូលដ្ឋាន និងប្រធានកងយកទៅសម្លាប់ចោល។ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីក៏ចាប់ផ្តើមស្រាវជ្រាវប្រវត្តិប្រជាជន១៧មេសា។ នៅពេលនោះ កងចល័តនារីនៅសេសសល់ប្រហែល ៦០នាក់ប៉ុណ្ណោះ។

នៅយប់មួយ ប្រធានកងចល័តនារីឈ្មោះ ស្រ៊ាង បានដើរស្រង់ឈ្មោះអ្នកដែលមានប្រវត្តិជាប្រជាជន ១៧ មេសា។ ខ្ញុំដឹងថា ប្រជាជន១៧មេសា នៅពេលនោះគឺត្រូវបានស្រង់ឈ្មោះបានចំនួន ១៣នាក់ រួមទាំងឈ្មោះរបស់ខ្ញុំផងដែរ។ ប៉ុន្តែមិត្តនារី ស្រ៊ាង ដែលជាអតីតមិត្តរៀនថ្នាក់ទី១១ នៅសាលាបឋមសិក្សាចុងកោះជាមួយគ្នា ស្គាល់ខ្ញុំ និងមិនបានហៅខ្ញុំដើម្បីរៀបចំបាយពោតដើម្បីយកទៅសម្លាប់ចោលនោះទេ។ ចំណែកឯអ្នក១២នាក់ផ្សេងទៀតត្រូវបានមិត្តនារី ស្រ៊ាង ប្រាប់ឲ្យរៀបចំបាយពោត និងហៅទៅតាមគាត់។ នៅយប់ដដែល ប្រជាជន១៧ មេសាបានងើបអង្គុយ និងពិភាក្សាគ្នាអំពីការរៀបចំបាយ និងការផ្លាស់ទៅកន្លែងផ្សេងទៀត។ នៅពេលនោះ មិត្តថាច ដែលរៀនបានខ្ពង់ខ្ពស់ និងចប់ថ្នាក់មហាវិទ្យាល័យ និយាយទៅកាន់អ្នកទាំងអស់គ្នាថា «កុំទៅបារម្ភពេក ខ្មែរក្រហមមិនដែលសាហាវជាងហ៊ីត្លែរ

នោះទេ»។ ការលើកឡើងរបស់មិត្ត ថាច នៅពេលនោះ គឺគាត់មិនជឿថា ខ្មែរក្រហម សម្លាប់ខ្មែរនោះទេ។ ប៉ុន្តែអ្វីដែលមិត្ត ថាច និយាយនោះគ្រាន់តែជាការយល់ខុស។ ខ្មែរក្រហម បានបណ្តើរអ្នកទាំង ១២នាក់ ដែលត្រូវបានស្រង់ឈ្មោះ និងប្រាប់ឲ្យរៀបចំបាយ យកទៅសម្លាប់ចោលយ៉ាងព្រៃផ្សៃក្បែរការដ្ឋានដែលខ្ញុំ និងអ្នកផ្សេងទៀតកំពុងធ្វើការ។

នៅឆ្នាំ១៩៧៨ ខ្ញុំទទួលបានដំណឹងថា ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំត្រូវបានខ្មែរក្រហមយកទៅសម្លាប់ និងទម្លាក់ចោលក្នុងទន្លេ ពីព្រោះតែជាប់ប្រវត្តិជាប្រជាជន១៧ មេសា។ បន្ទាប់ពីកងទ័ពវៀតណាមចូលមកដល់នៅដើមឆ្នាំ១៩៧៩ ខ្ញុំមិនបានរត់ទៅជាមួយខ្មែរក្រហមមកពីភូមិភាគនិរតីទេ។ ខ្ញុំបានវិលត្រឡប់មកភូមិទី៨វិញ ដើម្បីរស់នៅជាមួយយាយរបស់ខ្ញុំ និងប្អូនម្នាក់ដែលរួចផុតពីការសម្លាប់នៅពេលនោះ។ នៅឆ្នាំ១៩៨០ ខ្ញុំបានបង្រៀនកូនអ្នកភូមិនៅសាលាបឋមសិក្សាទីប្រជុំ និងក្រោយមកទៀតទទួលតួនាទីជានាយកសាលា។ បន្ទាប់ពីខ្ញុំចូលនិវត្តន៍ ខ្ញុំលក់នំនិងអាហារនៅក្នុងសាលា និងបន្តបង្រៀនកូនអ្នកភូមិក្នុងតួនាទីជាគ្រូកិច្ចសន្យា។



សិស្សសាលានៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម ជិះទូកដទៅសាលារៀន។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សសាលានៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម ជិះកង់ត្រឡប់ទៅផ្ទះ។
(ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឌឿន គឹមសាន ៖ អតីតប្រធានក្រុមនៅការដ្ឋានផ្លូវត្រ

***អេង ខណ្ឌិកា***



ឌឿន គឹមសាន អាយុ៦៣ឆ្នាំ បច្ចុប្បន្នគឺជាប្រធានភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។
(លី ដេវីត / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឌឿន គឹមសាន អាយុ៦៣ឆ្នាំ រស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ និងបច្ចុប្បន្នគឺជាប្រធានភូមិទីប្រាំបី។ ខ្ញុំរៀបការប្រពន្ធឈ្មោះ ភួង ពៅ និងមានកូនចំនួនបួននាក់។ឪពុកខ្ញុំឈ្មោះ អៀ សុខាន់និងម្តាយឈ្មោះ អែម គឹមអុល។ ខ្ញុំគឺជាកូនទី៧ ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៧ នាក់។ កាលនៅពីក្មេងខ្ញុំទៅរស់នៅជាមួយបងស្រីនៅ ទីរួមខេត្តកំពង់ចាម និងចូលរៀននៅសាលាបឋមសិក្សាដីដុះ។ បន្ទាប់មក ខ្ញុំប្តូរទៅរៀននៅ សាលាបឋមសិក្សាទួលថ្មរហូតដល់ថ្នាក់ទី៩។

បន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំឃើញបាតុកម្ម ផ្ទុះឡើង និងក្បួនបាតុករដង្ហែចូលមកដល់ទីរួមខេត្ត។ នៅឆ្នាំ១៩៧១ និងឆ្នាំ១៩៧២ ខ្ញុំបន្តរស់នៅជាមួយបងស្រីនៅ ទីរួមខេត្តកំពង់ចាមដដែល ប៉ុន្តែខ្ញុំឈប់រៀនពីព្រោះពេលនោះមានការប្រយុទ្ធគ្នារវាង ទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមផ្ទុះកាន់តែខ្លាំងឡើងៗ។ កងទ័ពរំដោះខ្មែរក្រហមបើកការវាយប្រហារ និងរំកិលចូលមកទីរួមខេត្តកំពង់ចាមបន្តិចម្តងៗ។ នៅឆ្នាំ១៩៧៣ កងទ័ពរំដោះខ្មែរក្រហមបើកការវាយប្រយុទ្ធជាទ្រង់ទ្រាយធំ និងរំដោះតំបន់ជាយ ទីរួមខេត្តកំពង់ចាម ដែលជាកន្លែងខ្ញុំស្នាក់នៅជាមួយបងស្រី។ ខ្ញុំនិងបងស្រីត្រូវបានជម្លៀសទៅនៅភូមិរកាគយ ក្នុងស្រុកកងមាស។ យើងបានស្នាក់នៅភូមិនេះបានមួយរយៈ។

នៅពាក់កណ្តាលឆ្នាំ១៩៧៣ ទីរួមខេត្តកំពង់ចាមត្រូវឡោមព័ទ្ធដោយកងទ័ពរំដោះខ្មែរក្រហម គឺមានតែផ្លូវទឹកប៉ុណ្ណោះដែលជាផ្លូវអាចចូលក្នុងទីរួមខេត្តកំពង់ចាមបាន។ ទាហានម៉ារីន លន់ នល់តែងតែបើកកប៉ាល់ចម្បាំង និងកប៉ាល់ដឹកស្បៀង ព្រមទាំងសម្ភារសឹកផ្សេងៗពីទីក្រុងភ្នំពេញទៅ ទីរួមខេត្តកំពង់ចាម ហើយជាញឹកញាប់បានទទួលរងការវាយប្រហារដោយកងទ័ពរំដោះខ្មែរក្រហមពីត្រើយម្ខាងនៃទន្លេមេគង្គ។ នៅឆ្នាំ១៩៧៣ ដដែល កងទ័ពរំដោះខ្មែរក្រហមវាយរំដោះបានពាក់កណ្តាល ទីរួមខេត្តកំពង់ចាម និងបន្តប្រយុទ្ធជាមួយ ទាហាន លន់ នល់ ដែលនៅសេសសល់ម្តុំសាលាខេត្ត។

នៅឆ្នាំ១៩៧៤ ខ្ញុំត្រឡប់មករស់នៅភូមិកំណើតជាមួយឪពុកម្តាយវិញ។ ចន្លោះពីឆ្នាំ១៩៧៤ និងដើម

ឆ្នាំ១៩៧៥ ខ្ញុំត្រូវកងទ័ពរំដោះខ្មែរក្រហមឲ្យចូលធ្វើការក្នុងកងប្រវាស់ដៃដើម្បីជួយប្រូតស្រូវ និងប្រមូលដំណាំផ្សេងៗ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្ដើមបង្កើតសហករណ៍ និងចាត់ឲ្យប្រជាជនធ្វើការនៅកងចល័តតាមការដ្ឋានផ្សេងៗ។ ខ្ញុំត្រូវបញ្ជូនឲ្យទៅធ្វើការនៅកងវ័យដែលមានទិសដៅធ្វើស្រែ និងលើកទំនប់នៅការដ្ឋានឆ្ន័ត្រ។ ខ្ញុំត្រូវក្រោកពីម៉ោង៤ និងត្រូវចូលរួមប្រជុំជួររយៈពេលមួយម៉ោង។ ខ្ញុំចាប់ផ្ដើមធ្វើការពីម៉ោង៦ដល់ម៉ោង១១ព្រឹក។ បន្ទាប់ពីខ្ញុំហូបបបរនៅរោងបាយរួមរួច ខ្ញុំត្រូវបន្តធ្វើការចាប់ពីម៉ោង១ដល់ម៉ោង៥ល្ងាច។ ម៉ោង៦ ដល់ម៉ោង៧យប់ គឺជាម៉ោងធ្វើការងារសង្គមនិយម គឺខ្ញុំនិងសមមិត្តផ្សេងទៀតត្រូវកាប់ដើមទន្ទ្រានខែត្រ និងស្រង់កំប្មោកដើម្បីយកមកធ្វើជី។ ខ្ញុំមិនបានដឹងថាម៉ោងសង្គមនិយមនេះយ៉ាងម៉េចទេ គឺគ្រាន់តែធ្វើតាមបទបញ្ជារបស់ប្រធានកងក្ដាប់រួមប៉ុណ្ណោះ។

នៅឆ្នាំ១៩៧៧ អង្គការចាត់តាំងខ្ញុំឲ្យធ្វើជាប្រធានកង «ក»។ នៅកងចល័តវ័យបុរសត្រូវបានបែងចែកជា៣កង៖ ទី១) គឺកង «ក» មានចំនួន១០កង ហើយក្នុងមួយកងៗមានសមមិត្តចំនួន១០នាក់។ ខ្ញុំគឺជាប្រធានកង «ក» ម្នាក់ក្នុងចំណោមប្រធានកង «ក» សរុបចំនួន១០នាក់។ ទី២) គឺកង «ខ» មានចំនួន៣កង ហើយក្នុងមួយកងមានសមមិត្តចំនួន៣០នាក់។ កង «ខ» គឺគ្រប់គ្រងលើកង «ក»។ ទី៣) គឺកង «គ» ដែលក្ដាប់រួមកង «ខ» ។ ប្រធានឈ្មោះមិត្ត ឆាត និងអនុប្រធានឈ្មោះមិត្តប៊ិន។ នៅក្នុងការដ្ឋានឆ្ន័ត្រ ខ្ញុំនៅចងចាំអំពីព្រឹត្តិការណ៍សំខាន់ៗចំនួន៣ មុនការមកដល់របស់កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីនៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ដែលធ្វើការចាប់ខ្លួននិងសម្លាប់កម្មាភិបាលមូលដ្ឋាន។

**ព្រឹត្តិការណ៍ទី១)** គឺការទៅទទួលប្រធានតំបន់២២ ឈ្មោះមិត្ត ស៊ឹម នៅឆ្នាំ១៩៧៦។ បន្ទាប់ពីទទួលប្រធានតំបន់២២រួចរាល់ ខ្ញុំត្រូវទៅធ្វើការវិញ។

**ព្រឹត្តិការណ៍ទី២)** គឺការទៅកាប់ដូងឲ្យមេការចិននៅរោងចក្រចម្ការកៅស៊ូពាមជាំង។ នៅព្រឹកមួយក្នុងឆ្នាំ១៩៧៦ កង «ក» របស់ខ្ញុំត្រូវបានបញ្ជាឲ្យបេះផ្លែដូងជាច្រើន និងដឹកមួយឡានធំចេញពីការដ្ឋានទៅរោងចក្រចម្ការកៅស៊ូពាមជាំង។ ពេលទៅដល់រោងចក្រ ខ្ញុំបានដឹកនាំសមមិត្តឲ្យកាប់ដូងដើម្បីយកឲ្យមេការចិនដែលកំពុងធ្វើការនៅរោងចក្រចម្ការកៅស៊ូ។ នៅពេលនោះ ខ្ញុំឃើញមានមេការចិនប្រុសស្រីប្រមាណ២០ទៅ៣០នាក់ ក្នុងសម្លៀកបំពាក់ខោខ្មៅអាវខ្មៅដូចខ្ញុំ បានដើរមកយកដូងផឹក។ ខ្ញុំក៏បានឲ្យដូងទៅមេការចិន។ មេការចិននោះបានងក់ក្បាលដើម្បីបង្ហាញការអរគុណ។ ខ្ញុំឮមេការចិននិយាយគ្នាថាចូលចិត្តផឹកទឹកដូង តាមរយៈអ្នកបកប្រែភាសាម្នាក់នៅទីនោះ។ បន្ទាប់ពី មេការចិនផឹកទឹកដូងរួច ខ្ញុំនិងកង «ក» ត្រូវអង្គការដឹកមកការដ្ឋានវិញ។

**ព្រឹត្តិការណ៍ទី៣)** គឺការទៅលើកដីនៅស្ថានីយស្តុកទឹកទួលទម្លាប់ស្ថិតនៅស្រុកអូររាំងឪ។ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅការដ្ឋានទួលទម្លាប់ដើម្បីជីកស្រះ និងលើកដីទប់មាត់ស្រះប្រវែង១០០ម៉ែត្រ។ ក្នុងអំឡុងពេលនោះ ខ្ញុំក៏បានឃើញអ្នកជំនាញការចិនមួយក្រុមទៀតដែលភាគច្រើនស្លៀកខោខ្លី និងពាក់ស្បែកជើងខ្ទុបចូលមកពិនិត្យដំណើរការម៉ាស៊ីនបូមទឹកធំៗនៅក្នុងរោង។ អ្នកជំនាញការចិនក៏បានចុះមកមើលកន្លែងខ្ញុំកំពុងជីកដីដែរ។ នៅពេលរសៀល អ្នកជំនាញការចិនទាំងនោះត្រូវបានខ្មែរក្រហមដឹកត្រឡប់ទៅវិញ ព្រោះមិនមានកន្លែងស្នាក់នៅ គឺមានតែកងធារាសាស្ត្រយាមកន្លែងប៉ុណ្ណោះ។ អ្នកជំនាញការចិនទាំងនេះមកពិនិត្យការដ្ឋានបានតែពីរថ្ងៃតែប៉ុណ្ណោះ ចំណែកការដ្ឋានស្ថានីយស្តុកទឹកនេះបានបញ្ចប់ការសាងសង់ក្នុងរយៈពេលតែ៣ខែ។

បន្ទាប់មក ខ្ញុំត្រូវបានបញ្ជូនមកធ្វើការនៅការដ្ឋានឆ្ន័ត្រវិញ។ ខ្ញុំបន្តធ្វើការនៅការដ្ឋាននេះ រហូតដល់ពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចូលមករំដោះប្រជាជនចេញពីរបបខ្មែរក្រហម ទើបខ្ញុំវិលត្រឡប់មករស់នៅជួបជុំគ្រួសារវិញ។

# ជា ខេងថៃ ៖ ប្រធានមន្ទីរពាណិជ្ជកម្ម តំបន់ ៤១ ក្នុងរបបខ្មែរក្រហម

**ស៊ាង ចិន្តា**



ជា ខេងថៃ អាយុ៧០ឆ្នាំ គឺជាកសិករ រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជា ខេងថៃ អាយុ៧០ឆ្នាំ គឺជាកសិករ រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំគឺជាគ្រូបង្រៀនចូលនិវត្តន៍កាលពីឆ្នាំ២០១១។ ខ្ញុំរៀបការប្រពន្ធឈ្មោះ យា ឆេងស៊ិន និងមានកូនចំនួន៤នាក់។ ខ្ញុំកើតនៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ ខ្ញុំមានឪពុកឈ្មោះ ជា ម៉េត និងម្តាយឈ្មោះ គា ណៃគីម។ ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន៣នាក់។ នៅវ័យកុមារ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាកំពង់ក្របី រហូតដល់ចប់ថ្នាក់ទី៧ និងបានប្រឡងជាប់ដើម្បីបន្តការរៀនសូត្រនៅវិទ្យាល័យព្រះសីហនុ។ ប្រហែលជា ៣ខែបន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅដើមឆ្នាំ១៩៧០ ខ្ញុំឃើញមានបាតុកម្មដង្ហែចូលមកទីរួមខេត្តកំពង់ចាមរយៈពេល៣ថ្ងៃ។ នៅពេលនោះ ខ្ញុំរៀនថ្នាក់ទី៦។ បើទោះបីជាមានការធ្វើបាតុកម្មយ៉ាងណាក្តី ខ្ញុំនៅតែបន្តការសិក្សា និងស្នាក់អាស្រ័យជាមួយឪពុកមានៅទីរួមខេត្តកំពង់ចាម។ បន្ទាប់ពីបាតុកម្មបានបញ្ចប់ ការផ្ទុះអាវុធរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានកើតឡើង។ នៅឆ្នាំ១៩៧១ កងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ភូមិកំណើតរបស់ខ្ញុំដើម្បីត្រៀមវាយបន្ទាយ លន់ នល់ នៅម្តុំកោះរការ។ ខ្ញុំតែងតែមកលេងផ្ទះដោយដើរតាមផ្លូវវាង។ មូលហេតុដែលខ្ញុំមិនអាចមកតាមផ្លូវពីព្រែកដើមចាន់មកភូមិចំការសាមសិប គឺមានទាហាន លន់ នល់ ត្រូវបានដាក់ឈរជើងដើម្បីទប់ទល់ និងវាយប្រហារទៅលើកងទ័ពរំដោះខ្មែរក្រហមនៅភូមិជិតនោះ។ ខ្ញុំបានបន្តរៀននៅវិទ្យាល័យព្រះសីហនុរហូតដល់ឆ្នាំ១៩៧៣ ត្រឹមថ្នាក់ទី៣។ ខ្ញុំបានឈប់រៀន បន្ទាប់ពីមកលេងផ្ទះនាពេលចុងសប្តាហ៍។ នៅពេលនោះ គា របស់ខ្ញុំបាននិយាយប្រាប់ខ្ញុំថាកុំវិលទៅរៀននៅទីរួមខេត្តកំពង់ចាម ព្រោះស្ថានការណ៍ច្របូកច្របល់។

ចាប់តាំងពីឆ្នាំ១៩៧៣ មក ខ្ញុំបានចូលបម្រើបដិវត្តន៍ និងត្រូវបានមិត្ត ជឿន ដែលជាមេភូមិក្នុងតំបន់រំដោះនាពេលនោះ ដាក់ឈ្មោះខ្ញុំចូលធ្វើការផ្សារ



កំពង់ចម្លងនៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅកងពាណិជ្ជកម្មស្រុកកំពង់សៀម។ នៅក្នុងកងពាណិជ្ជកម្មស្រុក មានសមមិត្តប្រហែលជា១០នាក់ ដែលមានតួនាទីដឹកជញ្ជូនសម្ភារប្រើប្រាស់ផ្សេងៗ។ នៅឆ្នាំ១៩៧៣ ដដែល ខ្ញុំត្រូវបានផ្លាស់ទៅធ្វើការនៅមន្ទីរពាណិជ្ជកម្មតំបន់៤១ ដែលមានមិត្ត ផួន គឺជាប្រធាន។ នៅពេលនោះ ខ្ញុំទទួលបានមុខងារជាអ្នកកត់ត្រា និងធ្វើបញ្ជីទំនិញសម្ភារប្រើប្រាស់។ នៅមន្ទីរពាណិជ្ជកម្មតំបន់៤១នេះ មានសមមិត្តទាំងអស់ចំនួន ១០នាក់ ដែលត្រូវបានចាត់តាំងធ្វើការងារផ្សេងៗគ្នា។ សមរភូមិរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមផ្ទុះកាន់តែខ្លាំងឡើង។ កងពាណិជ្ជកម្មតំបន់ ៤១ បានដឹកជញ្ជូន... កងពាណិជ្ជកម្មតំបន់ ៤១ បានជិះកង់ទៅដឹកអីវ៉ាន់សម្ភារប្រើប្រាស់ពីព្រំប្រទល់វៀតណាម ដើម្បីយកមកចែកចាយនៅតាមស្រុកនានាក្នុងតំបន់។

បន្ទាប់ពីទីក្រុងភ្នំពេញត្រូវបានរំដោះនៅឆ្នាំ១៩៧៥ ខ្ញុំនៅបន្តធ្វើជាអ្នកកត់បញ្ជីទំនិញនៅមន្ទីរពាណិជ្ជកម្មតំបន់៤១ ដដែល ដែលស្ថិតនៅទីប្រជុំជនថ្នល់ទទឹង ស្រុកព្រៃឈរ។ ខ្ញុំមិនដែលបានមកលេងផ្ទះទេ។ តាមអ្វីដែលខ្ញុំដឹងនោះគឺតំបន់៤១ ស្ថិតនៅភូមិភាគកណ្តាលដែលមាន កែ ពក គឺជាលេខាភូមិភាគ មានស្រុកចំណុះចំនួន៥ រួមមាន៖ ស្រុកកំពង់សៀម (ហៅថាស្រុក៨៨), ស្រុកព្រៃឈរ (ហៅថាស្រុក៧៧), ស្រុកកងមាស (ហៅថាស្រុក១០១), ស្រុកជើងព្រៃ(ហៅថាស្រុក៤៤) និងស្រុកបាធាយ (ហៅស្រុក៧៣)។ នៅឆ្នាំ១៩៧៦ តំបន់៤១ មានប្រធានឈ្មោះមិត្ត តាំង។ ប្រធានមន្ទីរពាណិជ្ជកម្មតំបន់គឺមិត្ត សាន ដែលបានចាត់តាំងឲ្យខ្ញុំកត់ត្រាបញ្ជីសម្ភារប្រើប្រាស់ក្នុងឃ្លាំង។ នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកដល់ និងចាប់ផ្តើមចាប់ខ្លួនកម្មាភិបាលមូលដ្ឋាន។ នៅពេលនោះ មិត្ត តាំង ប្រធានតំបន់ និងមិត្ត សាន ត្រូវបានចាប់ខ្លួន និងសម្លាប់។ មិត្ត ស៊ុប ប្រធានមន្ទីរ

សន្តិសុខតំបន់ គឺជាអ្នកដើរចាប់។ ប៉ុន្តែក្រោយមក មិត្ត ស៊ុប ត្រូវបានសម្លាប់ដោយកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីវិញ។ នៅក្នុងឆ្នាំដដែល សមមិត្ត អោ អាន ត្រូវបានផ្លាស់មកគ្រប់គ្រងតំបន់ ៤១។ បន្ទាប់ពីការមកដល់របស់ សមមិត្ត អោ អាន មានការចាប់ប្រធានកង និងកម្មាភិបាលមូលដ្ឋាននៅតាមស្រុកកាន់តែច្រើនឡើង។ ខ្ញុំត្រូវបានចាត់តាំងធ្វើជាប្រធានមន្ទីរពាណិជ្ជកម្ម។ ថ្នាក់លើប្រាប់ថា ខ្ញុំមិនទាន់ត្រូវបានចាប់យកទៅសម្លាប់នៅពេលនេះ ពីព្រោះតែមិនទាន់មានអ្នកជំនួសចេះធ្វើបញ្ជីនៅឃ្លាំង។ ចាប់តាំងពីពេលនោះមក ខ្ញុំបានកិនគ្រាប់ស្លែង និងដាក់តាមខ្លួនរហូត។ នៅពេលដែលខ្ញុំត្រូវបានចាប់ខ្លួនធ្វើទារុណកម្ម ខ្ញុំនឹងសម្លាប់ខ្លួនដោយការលេបគ្រាប់ស្លែងដែលកិនរួចជាស្រេចនោះ។ ខ្ញុំខ្លាចការធ្វើទារុណកម្ម។ រាល់ពេលខ្ញុំទៅមន្ទីរតំបន់ ៤១ ខ្ញុំតែងតែព្រួសួរការសួរចម្លើយ និងសម្រែកឈឺចុកចាប់ចេញពីកន្លែងធ្វើទារុណកម្ម។ ខ្ញុំមិនចង់ជួបភាពឈឺចុកចាប់បែបនេះទេ។ មិនយូរមិនឆាប់ ខ្ញុំនឹងត្រូវបានចាប់ខ្លួន ដូច្នេះខ្ញុំបានត្រៀមគ្រាប់ស្លែងកិនដាក់តាមខ្លួន។ ក្នុងអំឡុងពេលធ្វើជាប្រធានមន្ទីរពាណិជ្ជកម្ម ខ្ញុំតែងតែដឹកនាំកងដឹកជញ្ជូនពាណិជ្ជកម្មទៅយកអំបិល សម្ភារប្រើប្រាស់ និងក្រណាត់ខ្មៅនៅមន្ទីរភូមិភាគកណ្តាលនៅម្តុំចំការលើ។ បន្ទាប់ពីដឹកអំបិល សម្ភារប្រើប្រាស់ និងក្រណាត់ចូលឃ្លាំង មិត្ត អោ អាន លេខាតំបន់ ៤១ មិនអនុញ្ញាតឲ្យដឹកយកទៅចែកនៅតាមបណ្តាស្រុកក្នុងតំបន់នោះឡើយរហូតដល់របស់ទាំងអស់នេះនៅសល់ពេញឃ្លាំង។ ខ្ញុំដឹងថា មិត្ត កែ ពក លេខាភូមិភាគ បានបញ្ជាឲ្យលេខាតំបន់៤១ គឺ មិត្ត អោ អាន ធ្វើការចែកចាយសម្ភារប្រើប្រាស់ ជាពិសេសក្រណាត់ខ្មៅទៅកាន់ស្រុកផ្សេងៗ ប៉ុន្តែ មិត្ត អោ អាន មិនស្តាប់និងអនុវត្តតាមនោះឡើយ។ នៅថ្ងៃមួយចុងឆ្នាំ១៩៧៧ ខ្ញុំបានឡើងទៅដឹកសម្ភារប្រើប្រាស់បន្ថែមនៅមន្ទីរភូមិភាគ និងសរសេរសំបុត្រអនាមិកមួយរាយការណ៍ដល់លេខាភូមិភាគអំពីការមិនចែកចាយសម្ភារប្រើប្រាស់ ជាពិសេសក្រណាត់ខ្មៅនៅតំបន់៤១។ រយៈពេល ២ទៅ៣ថ្ងៃបន្ទាប់មក នីរសារភូមិភាគចំនួន២នាក់ត្រូវបានបញ្ជូនមក ដើម្បីពិនិត្យមើលឃ្លាំងនៅមន្ទីរពាណិជ្ជកម្មតំបន់ ៤១។ ប៉ុន្មានថ្ងៃក្រោយមក មិត្ត អោ អាន បានឡើងទៅប្រជុំនៅមន្ទីរភូមិភាគ។ បន្ទាប់ពីការប្រជុំនៅមន្ទីរភូមិភាគ មិត្ត អោ អាន បានបញ្ជាឲ្យកងពាណិជ្ជកម្មតំបន់ចាប់ផ្តើមចែកចាយសម្ភារ និងក្រណាត់ខ្មៅនៅតាមស្រុក និងសហករណ៍នៅក្នុងតំបន់៤១។ ខ្ញុំមានការព្រួយបារម្ភជាខ្លាំងពីការដែលអង្គការដឹងថា ខ្ញុំគឺជាអ្នកសរសេរសំបុត្រអនាមិកជូនលេខាភូមិភាគ។ នៅឆ្នាំ១៩៧៨ ខ្ញុំបន្តធ្វើការនៅមន្ទីរពាណិជ្ជកម្មតំបន់៤១ដដែល។ នៅពេលដែលកងទ័ពវៀតណាមវាយចូលមកដល់នៅដើមឆ្នាំ១៩៧៩ ខ្ញុំត្រូវបានជម្លៀសជាមួយអ្នកផ្សេងទៀតទៅទិសខាងលិចប្រទេស។ ដោយសារតែភ័យខ្លាចការនាំទៅសម្លាប់ ខ្ញុំ និងមិត្ត៣នាក់ទៀតបានលួចឡានជិះរត់ទៅខាងចំការលើ និងបានទុកឡានចោលក្នុងចម្ការចេក។ ខ្ញុំបានបន្តដើរមកកាន់ភូមិកំណើតវិញ និងរួចផុតពីសេចក្តីស្លាប់ក្នុងរបបខ្មែរក្រហម។ នៅឆ្នាំ១៩៨១ ខ្ញុំចូលបង្រៀនសិស្សនៅសាលាបឋមសិក្សាកំពង់ក្របី និងចូលនិវត្តន៍អស់រយៈពេលជិត១០ឆ្នាំហើយ។



ផ្លូវក្រាលបេតុងនៅទីប្រជុំជនស្រុកកោះសូទិន ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទូទ័ល សារ៉ស់៖ អ្នកត្បាញក្រមាឱ្យអង្គការខ្មែរក្រហម

*មីន សាណាស់*




*ទូទ័ល សារ៉ស់ រស់នៅឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ខែកក្កដា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ទូទ័ល សារ៉ស់ ភេទស្រី អាយុ៧៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ កាលជំនាន់ដើមខ្ញុំប្រកបរបរត្បាញសំពត់សូត្រ និងក្រមា។ ចំណែកឪពុកខ្ញុំឈ្មោះ ទូទ័ល គឺជាអ្នកធ្វើកន្ទេល និងមានចំណេះដឹងផ្នែកសាសនាក្នុងភូមិមួយរូប ហើយម្ដាយខ្ញុំឈ្មោះ សុះភាស គឺជាអ្នកបង្កើតគោមសំពត់សូត្រត្បាញ ដែលជារបរបន្ទាប់បន្សំជួយជីវភាពក្នុងគ្រួសារ។ ឪពុកម្ដាយខ្ញុំមានកូនចំនួន១០នាក់គឺប្រុស៥នាក់ និង ស្រីចំនួន៥នាក់។ បងៗប្រុសខ្ញុំសុទ្ធតែជាទាហាន លន់នល់។ ក្រោយរបបខ្មែរក្រហម គឺបងប្អូនខ្ញុំនៅសល់តែពីរនាក់តែប៉ុណ្ណោះ គឺខ្ញុំ និងបងប្រុសខ្ញុំម្នាក់ដែលបានរត់គេចខ្លួនទៅប្រទេសវៀតណាម។

កាលពីតូច ឪពុកម្ដាយខ្ញុំជំរុញខ្ញុំឲ្យសិក្សាពីក្បួនច្បាប់ផ្នែកសាសនាដល់អាយុប្រហែលជា១៥ឆ្នាំ ខ្ញុំឈប់រៀនហើយងាកមករៀនសូត្ររបរប្រពៃណីតម្បាញសូត្រពីម្ដាយខ្ញុំ។ ម្យ៉ាងទៀត ខ្ញុំចង់ជួយសម្រាលការងារគាត់។ ដំបូងម្ដាយខ្ញុំឲ្យរៀនត្បាញជាមុនសិន។ បន្ទាប់ពីខ្ញុំចេះត្បាញហើយ គាត់ចាប់ផ្ដើមបង្រៀនខ្ញុំឲ្យចងគោម ហើយណែនាំខ្ញុំដាក់ពណ៌អុំឲ្យត្រូវជាមួយគោមសំពត់នីមួយៗ។ ទម្រាំខ្ញុំចេះចាំនិងអាចចងគោមបានដោយខ្លួនឯង វាមិនមែនជារឿងងាយស្រួលទេ គឺយូរណាស់ បានធ្វើចេញជាសំពត់មួយ។ កាលខ្ញុំនៅត្បាញសំពត់បានប្រវែងតែពីរម៉ែត្រគឺកាត់ចេញហើយ មិនដូចបច្ចុប្បន្នត្រូវត្បាញឲ្យបានបួនម៉ែត្ររួចហៅថាមួយក្បិន។ ប្រហែលនៅក្នុងអំឡុងឆ្នាំ១៩៦២ ឈ្មួញពេញនិយមទិញសំពត់គោមផ្កាវំយោល ផ្កាម្លិះ ផ្ការាំង គោមភ្នែកគោ កូនហ៊ីងគោមផ្កាទទឹមតូចៗ គោមភ្នែកមាន់ និង គោមចំណិតសណ្ដាន់។ គោមទាំងនេះមានពណ៌លឿង ក្រហម ខ្មៅ និងបៃតង ដោយប្រើល័ក្តធម្មជាតិ ឬហៅម្យ៉ាងទៀតល័ក្តខ្មែរ។ គោមដែលខ្ញុំបានរៀបរាប់នេះ គឺសុទ្ធតែជាគោមដែលខ្ញុំធ្លាប់ចងដោយផ្ទាល់ ហើយអតិថិជនចូលចិត្តប្រើប្រាស់។ ឈ្មួញទិញយកទៅលក់បន្តដោយកក់យកគោមទាំងនេះជាបន្តបន្ទាប់។

នៅក្នុងឆ្នាំ១៩៦៧ ឪពុកម្ដាយខ្ញុំបានរៀបចំពិធីរៀបការឲ្យខ្ញុំនិងប្ដីខ្ញុំឈ្មោះ ស្មាស់ អេល។ ខ្ញុំរៀបការហើយនៅតែបន្តការងារតម្បាញរបស់ខ្ញុំដដែល។ ក្រោយពីមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម

សីហនុនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០មិនបានប៉ុន្មានផង ស្រាប់តែឃើញមានព្រឹត្តិការណ៍ប្លែកៗនៅក្នុងភូមិ គឺខ្ញុំឃើញមានកងកម្លាំងរំដោះខ្មែរក្រហមចូលមកគ្រប់គ្រង ហើយចាត់តាំងប្តីរបស់ខ្ញុំកាន់តួនាទីខាងគ្រប់គ្រងឃុំ ឬហៅថាកាន់ខាងគមនាគមន៍ៗ ក្រោយមក ហាក់ម គួន និង អ្នកមានធនធានក្នុងភូមិត្រូវកងកម្លាំងរំដោះមកហៅឲ្យចុះពីលើផ្ទះ និងយកទៅវាល់យប់ៗ សូម្បីតែឪពុករបស់ខ្ញុំ និងបងប្រុសៗរបស់ខ្ញុំក៏កងកម្លាំងរំដោះខ្មែរក្រហមចាប់យកទៅដែរ ព្រោះបងប្រុសរបស់ខ្ញុំធ្វើជាទាហានលន់ នល់ ។ ខ្ញុំខំស្រែកថា កុំយកគាត់ទៅអី គួរយោគយល់ប្តីរបស់ខ្ញុំផង គាត់ក៏ជាអ្នកធ្វើការឲ្យកងកម្លាំងរំដោះដែរៗ ប៉ុន្តែសម្តីដែលកងកម្លាំងរំដោះតបមកខ្ញុំវិញគឺតែ «ឯងឡើងលើផ្ទះវិញទៅគ្មានប្រយោជន៍ទេ»ៗ ក្រោយពីចាប់ឪពុកខ្ញុំនិងបងៗបានបីថ្ងៃ ព្រឹកឡើងពេលខ្ញុំចុះពីផ្ទះដាន់កាំជណ្តើរ ស្រាប់តែឃើញខោអាវឪពុកនិងបងៗរបស់ខ្ញុំៗ ខ្ញុំដឹងក្នុងចិត្តរួចហើយថាពួកគាត់ត្រូវកងកម្លាំងរំដោះខ្មែរក្រហមយកទៅសម្លាប់ៗ

នៅឆ្នាំ១៩៧៥ ក្រោយពីកងទ័ពខ្មែរក្រហមរំដោះទីក្រុងភ្នំពេញរួច ខ្មែរក្រហមចាប់ផ្តើមជម្លៀសជនជាតិចាមចេញពីភូមិ ដោយទុកតែប្រាំមួយគ្រួសារសម្រាប់ត្បាញក្រមា និងធ្វើនំពុម្ពបារាំងៗ ខ្ញុំត្បាញក្រមាឲ្យកងទ័ពខ្មែរក្រហមរហូតដល់ចុងឆ្នាំ១៩៧៨ៗ ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យធ្វើជាមេក្រុមកីតម្បាញ ដឹកនាំជ្រលក់ពណ៌ រវៃអំបោះ ហាលអំបោះៗ ក្រមាដែលខ្ញុំត្បាញគឺមានពណ៌ខ្មៅលាយក្រហម គឺជាប្រភេទក្រមាបង់កៗ ក្រមាដែលខ្ញុំត្បាញភាគច្រើនឃើញកម្មាភិបាលខ្មែរក្រហមជូនដល់កូនកម្លោះកូនក្រមុំ ដែលអង្គការបានរៀបចំផ្សំផ្គុំៗ ទោះបីជាប្តីរបស់ខ្ញុំគឺជាប្រធានឃុំ ប៉ុន្តែសម្ភារ ដូចជា ក្រណាត់ ក្រមា និង នំ គឺខ្ញុំមិនដែលបានបរិភោគ ឬប្រើប្រាស់ឡើយៗ



កីសម្រាប់ត្បាញក្រមារបស់ជនជាតិចាមនៅស្រុកកោះសូទិន ខេត្តកំពង់ចាមៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំរស់នៅក្នុងភូមិដដែល និងរង់ចាំមើលផ្លូវ បងប្អូន កូនក្មួយត្រឡប់មកវិញៗ ប៉ុន្តែជាអកុសល បងប្រុស បងស្រីរួមជាមួយបងថ្លៃប្រុសស្រី ខ្ញុំមិនបានវិលត្រឡប់មកវិញទេរហូតមកដល់សព្វថ្ងៃនេះៗ ខ្ញុំនិងប្តីប្រកបមុខរបររនេសាទត្រីលក់យកប្រាក់ផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ និងសន្សំលុយប្រាក់ខ្លះដើម្បីទុកចាយវាយសម្រាប់ថ្ងៃខាងមុខៗ ខ្ញុំនិងប្តី មិនមានកូនទេ ដូច្នេះខ្ញុំបានយកក្មួយពីរនាក់មកចិញ្ចឹមៗ

នៅឆ្នាំ១៩៨៤ ខ្ញុំឃើញអំបោះសូត្រមានលក់នៅលើទីផ្សារ ហើយដោយសារខ្ញុំមានចំណេះជំនាញពីម្តាយរបស់ខ្ញុំស្រាប់ ដូច្នេះខ្ញុំក៏រៀបចំដំឡើងកីត្បាញសំពត់សូត្រឡើងវិញៗ ខ្ញុំរកឈើថ្មី និងស្វែងរកគ្រឿងកីតម្បាញចាស់ៗមកផ្សំគ្នាដំឡើងទៅជាកីៗ ខ្ញុំរៀបចំរវៃសូត្រ ស្វែងរកល័ក្តជ្រលក់ ហាលសូត្រ ចំណែកប្តីរបស់ខ្ញុំរៀបចំកីៗ គោមដែលខ្ញុំធ្វើដំបូងបន្ទាប់ពីអាក់ខានធ្វើជាយូរឆ្នាំ គឺគោមក្បៀកបន្ទាប់មកគោមសំរោង គោមចំណិតសណ្តាន់ និងគោមជាច្រើនទៀតៗ ចំណែកពណ៌ គឺមានពណ៌បៃតង ពណ៌ក្រហម ពណ៌លឿង និងពណ៌ស្វាយៗ សព្វថ្ងៃ ភូមិកំពង់ក្របីលែងមានកីតម្បាញសំពត់សូត្រទៀតហើយ ព្រោះសំពត់សូត្រគ្មានទីផ្សារៗ នៅក្នុងភូមិមានតែកីត្បាញក្រមា ហើយសល់តែបួនទៅប្រាំកីតែប៉ុណ្ណោះៗ ខ្ញុំពិតជាសោកស្តាយស្នាដៃត្បាញដែលជាប្រពៃណីដ៏ដូនជីតាបន្សល់ទុកឲ្យ ហើយប្រសិនបើគ្មានការចាប់អារម្មណ៍លើការត្បាញនេះទៀតទេ នឹងធ្វើឲ្យបាត់បង់នៅពេលខាងមុខៗ

# ស្រេង ស៊ីថា ៖ ខ្មែរក្រហមសម្លាប់ក្រុមគ្រួសារ និងម្ដាយរបស់ខ្ញុំទាំងមានផ្ទៃពោះជិតគ្រប់ខែ

**ទូច វណ្ណាត**



ស្រេង ស៊ីថា អាយុ៦២ឆ្នាំ បច្ចុប្បន្នរស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (ស៊ាង ចិន្ដា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ស្រេង ស៊ីថា អាយុ៦២ឆ្នាំ បច្ចុប្បន្នរស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំគឺជាអតីតគ្រូបង្រៀនថ្នាក់ទី១នៅសាលាបឋមសិក្សាទីប្រជុំ។ ខ្ញុំរៀបការប្ដីឈ្មោះ អ៊ុត ម៉ៅ និងមានកូនប្រុសស្រីទាំងអស់ចំនួន៤នាក់។ ខ្ញុំមានឪពុកឈ្មោះ ស ស្រេង គឺជានាយទាហានក្នុងរបប លន់ នល់ និងម្ដាយឈ្មោះ ម៉ែន ជា។ ខ្ញុំគឺជាកូនទី៣ក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន៧នាក់។ ខ្ញុំមានស្រុកកំណើតនៅភូមិចុងកោះដើង ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ នៅវ័យកុមារ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាទួលថ្មរហូតដល់បញ្ចប់ថ្នាក់ទី៧ចាស់។ ខ្ញុំបានប្រឡងចូលរៀនថ្នាក់ទី៦នៅវិទ្យាល័យព្រះសីហនុ។

បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ នៅដើមឆ្នាំ១៩៧០ ខ្ញុំឃើញមានការធ្វើបាតុកម្មនៅទីរួមខេត្តកំពង់ចាម។ បាតុកម្មបានអូសបន្លាយរយៈពេលប្រហែល២ទៅ៣ថ្ងៃ។ មិនយូរប៉ុន្មានបន្ទាប់ពីបាតុកម្មបានបញ្ចប់ សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើង។ នៅពេលនោះ ឪពុករបស់ខ្ញុំគឺជានាយទាហាន លន់ នល់ ថ្នាក់អនុសេនីយ៍ឯក។ ចាប់ពីចុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧២ សង្គ្រាមរវាងទាហាន លន់ នល់ ដែលឈរជើងនៅតាមក្រវាត់ក្រុងកំពង់ចាម និងកងទ័ពរំដោះខ្មែរក្រហមដែលឈរជើងនៅតាមភូមិផ្ទុះឡើងកាន់តែខ្លាំងឡើងៗ។ នៅឆ្នាំ១៩៧៣ ដោយបានឃើញស្ថានការណ៍មិនស្រួល ឪពុករបស់ខ្ញុំបាននាំគ្រួសារទៅជិះយន្តហោះស្ថិតនៅម្ដុំវាលវង់ ក្នុងក្រុងកំពង់ចាម ដើម្បីរកកន្លែងសុវត្ថិភាពគឺទីក្រុងភ្នំពេញ។ បន្ទាប់មកឪពុករបស់ខ្ញុំបានផ្លាស់ទៅធ្វើការនៅកំពង់សោម។ ខ្ញុំនិងក្រុមគ្រួសារបានទៅរស់នៅជាមួយឪពុកនៅទីនោះដែរ។

នៅឆ្នាំ១៩៧៤ ឪពុករបស់ខ្ញុំបានផ្លាស់មកធ្វើការនៅភ្នំពេញវិញ។ នៅពេលនោះ ឪពុកនិងម្ដាយរបស់ខ្ញុំបានទិញផ្ទះមួយនៅម្ដុំវត្តទឹកល្អក់។ ខ្ញុំបានចូលរៀននៅសាលាឯកជនមួយឈ្មោះតារាសាស្ត្រ ដោយបានរៀនត្រឹមថ្នាក់ទី៤។ ប៉ុន្មានខែបន្ទាប់មក ឪពុករបស់ខ្ញុំទទួលបានតួនាទីជាបាឡាត់ខេត្តកំពត។ នៅពេលនោះ ឪពុករបស់ខ្ញុំបានធ្វើដំណើរទៅកាន់ខេត្តកំពតតាមរយៈ

យន្តហោះខ្នាតតូច ព្រោះការធ្វើដំណើរតាមផ្លូវគោកគឺមិនមានសុវត្ថិភាពឡើយ ហើយអាចទទួលរងការវាយប្រហារពីកងទ័ពរំដោះខ្មែរក្រហម។ ម្តាយ និងបងប្អូនរបស់ខ្ញុំផ្សេងទៀតគឺបន្តរស់នៅទីក្រុងភ្នំពេញ។ នៅពេលដែលកងទ័ពរំដោះខ្មែរក្រហមខិតជិតមកដល់ទីក្រុងភ្នំពេញ ឪពុករបស់ខ្ញុំសម្រេចចិត្តជិះយន្តហោះខ្នាតតូចវិលត្រឡប់មកភ្នំពេញដើម្បីជួបជុំជាមួយគ្រួសារ។ ឪពុករបស់ខ្ញុំបានមកដល់ផ្ទះវិញនៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ គឺមួយថ្ងៃមុនពេលកងទ័ពរំដោះខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ។ នៅវេលាប្រហែលម៉ោង៨រសៀល ខ្ញុំឮសូរគ្រាប់បែកធ្លាក់នៅម្តុំផ្ទះខ្ញុំរស់នៅ។

នៅថ្ងៃបន្ទាប់ គឺថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពរំដោះខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុង។ កងទ័ពខ្មែរក្រហមបានមកគោះទ្វារផ្ទះ ប៉ុន្តែឪពុករបស់ខ្ញុំបានសុំស្នាក់នៅផ្ទះមួយយប់សិន។ នៅព្រឹកថ្ងៃបន្ទាប់គឺថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានមកប្រាប់គ្រួសារខ្ញុំឲ្យចាកចេញពីទីក្រុងភ្នំពេញត្រឹមតែ៣ថ្ងៃប៉ុណ្ណោះ។ ភ្លាមនោះ ម្តាយខ្ញុំបានរៀបចំយកមុង ភួយ និងខោអាវខ្លះៗមុនពេលចាកចេញពីផ្ទះ។ គ្រួសាររបស់ខ្ញុំដើរតាមផ្លូវទឹកល្អក់ រហូតដល់អង់តែនទួលគោក ឆ្ពោះទៅគីឡូម៉ែត្រលេខ៦ និងបន្តទៅព្រែកក្តាមដើម្បីឆ្លងទន្លេទៅខាងកំពង់ចាម។ ខ្ញុំឃើញប្រជាជនជាច្រើននាក់ដើរពាសពេញផ្លូវទៅព្រែកក្តាម។ គ្រួសារខ្ញុំដើររយៈពេល៤ថ្ងៃទើបទៅដល់កំពង់ចម្លងព្រែកក្តាម។ ខ្ញុំនៅចាំបានថា កងទ័ពខ្មែរក្រហមបានស្កាត់សួរអំពីប្រវត្តិរបស់ប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញ។ ការស្កាត់សួរអំពីប្រវត្តិរូបលើកទី១គឺនៅក្នុងវត្តមួយ ដែលខ្ញុំមិនចាំឈ្មោះ។ នៅពេលនោះ ឪពុករបស់ខ្ញុំប្រាប់កងទ័ពខ្មែរក្រហមថា គាត់គឺជាអ្នកបើកឡាននៅភ្នំពេញ។ ការស្កាត់សួរប្រវត្តិរូបលើកទី២គឺនៅម្តុំរការកោង។ ប្រជាជនជាច្រើននាក់ ដែលត្រូវបានស៊ើបដឹងថា ធ្លាប់បម្រើការជាគ្រូបង្រៀន ទាហាន ឬមន្ត្រីក្នុងរបបលន់ នល់ ត្រូវបានកងទ័ពខ្មែរក្រហមមិនអនុញ្ញាតឲ្យបន្តដំណើរទៅមុខទៀតទេ និងក្រោយមកត្រូវបានយកទៅសម្លាប់ចោល។ គ្រួសារខ្ញុំបន្តដំណើរទៅដល់ភូមិត្រពាំងស្នោរ និងបានស្នាក់នៅប្រហែល១ខែ។

នៅខែមិថុនា ឆ្នាំ១៩៧៥ គ្រួសារខ្ញុំបានលួចរត់ទាំងយប់ចេញពីភូមិត្រពាំងស្នោរ មកភូមិកំណើតរបស់ជីដូនដែលកំពុងរស់នៅគឺភូមិប្រមាត់ដី ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម។ ចាប់ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ខ្ញុំចូលធ្វើការក្នុងកងចល័តនារីឃុំស្វាយទាប ដោយបានដើរលើកទំនប់ជីកប្រឡាយ និងភ្ជួររាស់។ ចំណែកឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំត្រូវបានដាក់ឲ្យធ្វើការនៅតាមកងចល័តរៀងៗខ្លួន។ នៅថ្ងៃមួយ ខ្ញុំនិងកងចល័តនារីផ្សេងទៀតត្រូវបានប្រធានកងប្រាប់ឲ្យទៅប្រជុំនៅផ្ទះលេខាភូមិភាគ គឺមិត្ត កែ ពក។ នៅពេលនោះ ខ្ញុំឃើញមានកងចល័តជាច្រើនបានអង្គុយប្រជុំ។ មិត្ត កែ ពក បាននិយាយឲ្យយើងខិតខំធ្វើការងារ។ នៅឆ្នាំ១៩៧៨ កងចល័តនារីរបស់ខ្ញុំត្រូវបានផ្លាស់ប្តូរទៅលើកទំនប់នៅខេត្តកំពង់ធំគឺទំនប់១មករាអស់រយៈពេល៣ខែ។ ការដ្ឋានទំនប់១មករា មិនទាន់បញ្ចប់នៅឡើយទេ ប៉ុន្តែកងចល័តនារីរបស់ខ្ញុំត្រូវបានផ្លាស់មកកាន់ភូមិប្រមាត់ដីវិញ។ បន្ទាប់ពីមកដល់ភូមិបានប្រហែល២ទៅ៣ខែ ខ្ញុំត្រូវបានមិត្តរឿនដែលជាប្រធានកងចល័តឃុំ ជ្រើសរើសឲ្យចូលក្នុងកងកម្លាំងស្រួច ដែលមានសមមិត្តនារីប្រហែល២៥នាក់ ដើម្បីទៅធ្វើការនៅកន្លែងនេសាទត្រីនៅខេត្តកំពង់ធំ និងទៅបោចវល្លិ៍នៅខេត្តព្រះវិហារ។ ខ្ញុំបាននិយាយលាឪពុកម្តាយ និងបងប្អូនមុនពេលចាកចេញដំណើរទៅ។ បន្ទាប់ពីបានទៅធ្វើការឆ្ងាយពីភូមិរយៈពេល៣ខែ ខ្ញុំបានសុំច្បាប់មកលេងផ្ទះបាន៣ថ្ងៃ។ នៅពេលដែលខ្ញុំចេញពីផ្ទះវិលត្រឡប់ទៅធ្វើការងារវិញ ប្អូនប្រុសរបស់ខ្ញុំបានសុំខ្ញុំទៅជាមួយដែរ។ ប៉ុន្តែខ្ញុំមិនបានយកប្អូនទៅជាមួយទេ ពីព្រោះខ្ញុំធ្វើការបោចវល្លិ៍នៅក្នុងព្រៃក្បែរភ្នំត្បែង គឺពិបាករស់នៅខ្លាំងណាស់។ ៤ថ្ងៃបន្ទាប់ពីខ្ញុំចាកចេញពីផ្ទះលើកនេះ ខ្ញុំទទួលបានដំណឹងថា គ្រួសាររបស់ខ្ញុំរួមមានឪពុកម្តាយដែលកំពុងពពោះជិតគ្រប់ខែ និងបងប្អូនទាំងអស់ត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ទាំងអស់។ នៅពេលទទួលដំណឹងអំពីការស្លាប់របស់

គ្រួសារ ខ្ញុំគ្មានព្រលឹងក្នុងខ្លួនឡើយ។ ប៉ុន្តែមិត្ត រឿន បាននិយាយលើកទឹកចិត្តខ្ញុំឲ្យពង្រឹងស្មារតីក្នុងការ ធ្វើការងារ ពីព្រោះខ្ញុំត្រូវបានដាក់ឲ្យស្ថិតនៅក្នុង ប្រជាជនមានប្រវត្តិរូបមិនល្អ ដែលប្រឈមការចាប់ យកទៅសម្លាប់គ្រប់ពេលវេលា។

នៅពេលដែលកងទ័ពវៀតណាមវាយចូល មកដល់ទីរួមខេត្តកំពង់ចាម នៅដើមឆ្នាំ១៩៧៩ កងចល័តទាំងអស់ត្រូវបានរំសាយ។ នៅពេលនោះ ខ្ញុំនិងមិត្តនារី៣នាក់ទៀត រត់ចេញពីកងនិងបាន ចែវទូកតាមទន្លេមកភូមិកំណើតវិញ ប៉ុន្តែត្រូវកងទ័ព ខ្មែរក្រហមដែលនៅសេសសល់បានឃាត់ខ្លួនយើង។ ក្រោយមក ខ្ញុំនិងមិត្តនារីពីរនាក់ទៀតត្រូវបានដោះ លែងវិញ ហើយយើងចែវទូករហូតមកដល់ភូមិ។ ខ្ញុំដឹងថា មានប្រជាជនជាច្រើនគ្រួសារក៏បានចែវទូក នៅពីក្រោយខ្ញុំ ប៉ុន្តែត្រូវបានខ្មែរក្រហមចាប់យកទៅ សម្លាប់ទាំងអស់។ ខ្ញុំរួចផុតពីសេចក្តីស្លាប់នាពេល នោះ ប៉ុន្តែបានបាត់បង់សមាជិកគ្រួសារទាំងអស់។ នៅឆ្នាំ១៩៨០ ខ្ញុំបានផ្លាស់មករស់នៅភូមិទី៨ ស្រុក កោះសូទិន ខេត្តកំពង់ចាម។ នៅឆ្នាំ២០១០ ខ្ញុំចាប់ ផ្តើមបង្រៀនសិស្សនៅសាលាបឋមសិក្សាទំប្រជុំ រហូតដល់ចូលនិវត្តន៍នៅឆ្នាំ២០២០។ បច្ចុប្បន្នខ្ញុំលក់ ដូរបន្តិចបន្តួចនៅផ្ទះដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។



ទំបន់១មករា ក្នុងខេត្តកំពង់ធំ អំឡុងឆ្នាំ១៩៧៨។
(ហ្គុនណា បឺយស្រ្តម / មជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាអប់រំអំពីការថែទាំសុខភាព និងពិនិត្យសុខភាពជូនជនពិការ ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម នៅខេត្តកំពង់ចាម

គីម សុវណ្ណដានី និង សុខ វណ្ណៈ





អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មកចូលរួមវេទិកាអប់រំអំពីការថែទាំសុខភាព និងបានពិនិត្យសុខភាពជាមួយក្រុមគ្រូពេទ្យជំនាញ នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (លី ដេវីត / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខែមេសា គឺជាខែដែលកើតមានអំពើប្រល័យពូជសាសន៍នៅលើពិភពលោក ហើយក៏ជាខែដែលប្រជាជនកម្ពុជាប្រារព្ធពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិរបស់ខ្លួនដែរ។ ដោយឡែកនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលកងទ័ពខ្មែរក្រហមទទួលបានជោគជ័យទាំងស្រុង ហើយក៏ជាថ្ងៃនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដើម្បីទៅធ្វើស្រែចម្ការនៅតាមតំបន់ដែលបានកំណត់ដោយមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អាកាសធាតុក៏ចាប់ផ្ដើមក្ដៅខ្លាំងនៅក្នុងខែមេសានេះ ដែលងាយនឹងបណ្ដាលឲ្យកើតជំងឺផ្សេងៗជាពិសេស សុខភាពទារក កុមារតូច និងមនុស្សចាស់ជរា។

នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣ នេះដែរ ក្រុមការងារមានការសោកស្ដាយយ៉ាងខ្លាំងចំពោះដំណឹងមរណភាព អតីតអ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី២ ឈ្មោះដាតច័ន្ទសម្ផស្ស អាយុ២៣ឆ្នាំ ដោយសារជំងឺគាំងបេះដូង។ ការបាត់បង់ធនធានដ៏ល្អមួយនេះបានពញ្ញាក់ស្មារតីដល់ក្រុមការងារឲ្យកាន់តែខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់បន្តការអប់រំផ្សព្វផ្សាយពីការថែទាំសុខភាពបឋមដល់អ្នករស់រានមានជីវិតពី



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មកចូលរួមវេទិកាអប់រំអំពីការថែទាំសុខភាព និងបានពិនិត្យសុខភាពជាមួយក្រុមគ្រូពេទ្យជំនាញ នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (លី ដេវីត / មជ្ឈមណ្ឌលឯកសារកម្ពុជា)

របបខ្មែរក្រហមដើម្បីទប់ស្កាត់មិនឲ្យមានជំងឺផ្សេងៗ និងយល់ដឹងពីការថែទាំជំងឺទាំង១០ប្រភេទរួមមាន៖ ១) ជំងឺលើសឈាម, ២) ជំងឺក្រពះពោះវៀន, ៣) ជំងឺគ្រុនចាញ់, ៤) ជំងឺផ្លូវចិត្ត, ៥) ជំងឺបេះដូង, ៦) ជំងឺឈឺសន្លាក់, ៧) ជំងឺហឺតរ៉ាំរ៉ៃ, ៨) ជំងឺទឹកនោមផ្អែម, ៩) ជំងឺរបេង និង ១០) ជំងឺឆ្កួតជ្រូក ដែលតែងតែកើតមានលើមនុស្សចាស់ និងការស្វែងរកការព្យាបាលដ៏ត្រឹមត្រូវដើម្បីចៀសវាងការខាតបង់ថវិកា និងខកខានពេលវេលាព្យាបាលឬទទួលបានការជួយសង្គ្រោះទាន់ពេលវេលា។

បន្ថែមលើនេះទៅទៀត ការពិនិត្យសុខភាពជាប្រចាំឆ្នាំ ពិតជាមានសារសំខាន់បំផុតដល់មនុស្សចាស់ ក៏ដូចជាមនុស្សវ័យកណ្ដាល ព្រោះយើងអាចដឹងពីរោគវិនិច្ឆ័យច្បាស់លាស់ ក៏ដូចជាការស្វែងរកឃើញជំងឺក្នុងដំណាក់កាលដំបូង ដើម្បីទទួលបានការព្យាបាលទាន់ពេលវេលា។ គ្រប់ពេលដែលក្រុមការងារចុះធ្វើការតាមមូលដ្ឋាន ប្រជាជនដែលមានវ័យចំណាស់តែងតែត្អូញត្អែរអំពីបញ្ហាសុខភាពដែលចុះខ្សោយជារៀងរាល់ថ្ងៃ គឺបញ្ហាប្រឈមចម្បងបំផុត ដែលប៉ះពាល់ដល់ស្ថានភាពជីវភាពរស់នៅរបស់ប្រជាជនតាមទីជនបទដាច់ស្រយាល។

នៅថ្ងៃទី០៥ និងទី០៦ ខែមេសា ឆ្នាំ២០២៣ ក្រុមការងារនៃគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងវិញនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយមន្ទីរសម្រាក និងពិនិត្យព្យាបាល កែវវណ្ណៈ បានរៀបចំពិនិត្យសុខភាពបឋមដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២៥នាក់ ដែលរស់នៅស្រុកកំពង់សៀម និងស្រុកកោះសូទិន ខេត្តកំពង់ចាម។ មុនការចាប់ផ្តើមពិនិត្យសុខភាពជូនអ៊ំពូមីង អ្នកស្រី អ៊ូ បញ្ញា គឺជាគិលានុបដ្ឋាយិកា បានផ្ដល់អនុសាសន៍ដល់ការថែទាំសុខភាពអ៊ំពូមីង ដោយការតាមដានសុខភាពជាប្រចាំ ជាពិសេស គឺការពិនិត្យតាមដានសម្ពាធឈាម

របស់អ៊ំពូមីង ដែលមានវ័យចំណាស់ ព្រោះជំងឺលើសឈាមត្រូវបានវេជ្ជបណ្ឌិតប៉ែក ខាងអ៊ីរ៉ុបចាត់ទុកជាឃាតករសម្ងាត់។

ក្រោយពីបានពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តកំពង់ចាមរួចមក វេជ្ជបណ្ឌិត ណាត លាងងីម ឯកទេសជំងឺទូទៅ បានរកឃើញថា ៨០ភាគរយនៃអ្នកទទួលបានការពិនិត្យសុខភាព មានបញ្ហាសតិអារម្មណ៍ដោយនៅមានការរងសម្ពាធផ្លូវអារម្មណ៍ខ្លាំងនៅឡើយ ព្រោះអ៊ំពូមីងមានវ័យចាស់ដែលធ្លាប់ឆ្លងកាត់បទពិសោធន៍ក្នុងរបបខ្មែរក្រហមសម្រាន្តមិនលក់ យល់សប្តិអាក្រក់ ជាកត្តាបង្កឲ្យមានជំងឺប្រចាំកាយផ្សេងៗដូចជា ជំងឺទឹកនោមផ្អែម និងជំងឺលើសឈាមជាដើម។ ក្នុងនោះដែរ ការយល់ខុសចំពោះការប្រើប្រាស់ថ្នាំ ឬប្រើប្រាស់ថ្នាំខុសវេជ្ជបញ្ជាក៏ជាកត្តាជំរុញឲ្យការព្យាបាលមិនមានប្រសិទ្ធភាព និងអាចឈានដល់ការវិវឌ្ឍន៍កាន់តែធ្ងន់ធ្ងរឡើង។ ជាអនុសាសន៍របស់អ្នកស្រី អ៊ូ បញ្ញា សំណូមពរឲ្យមានការអប់រំពីសុខភាពផ្លូវចិត្ត និងការអប់រំឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមយល់ពីការទទួលទានអាហារ ត្រឹមត្រូវតាមស្ថានភាពសុខភាព និងស្ថានភាពជំងឺរបស់អ៊ំពូមីងទាំងអស់គ្នា។








អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មកចូលរួមវេទិកាអប់រំអំពីការថែទាំសុខភាព និងបានពិនិត្យសុខភាពជាមួយក្រុមគ្រូពេទ្យជំនាញ នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ( លី ដេវីត / មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ការចងចាំអំពីជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ក្នុងពិធីបុណ្យដាលាន

ទូច វណ្ណាត





នៅថ្ងៃសុក្រ ទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គាំទ្រដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រារព្ធពិធីបុណ្យដាលាន បន្ទាប់ពីបានបញ្ចប់ការច្រូតកាត់ និង ប្រមូលផលស្រូវ។
( លី ដេវីត / មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅថ្ងៃសុក្រ ទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គាំទ្រដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រារព្ធពិធីបុណ្យដាលានបន្ទាប់ពីបានបញ្ចប់ការច្រូតកាត់ និងប្រមូលផលស្រូវទុកក្នុងជង្រុកស្រូវរបស់ខ្លួន។ ពិធីបុណ្យដាលានដែលត្រូវបានធ្វើឡើងនៅកណ្តាលវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ត្រូវបានចូលរួមដោយលោក សៀង ស៊ីថាន ក្រុមប្រឹក្សាឃុំគគរ, លោក តុង សុភា តំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និងយុវជន-យុវនារីជាច្រើនទៀត។ ពិធីបុណ្យដាលានរួមបញ្ចូលកម្មវិធីសូត្រមន្តបង្សុកូលឧទ្ទិសកុសលដល់ជនរងគ្រោះដែល បានស្លាប់ក្នុងរបបខ្មែរក្រហម ការហូបអាហារជុំគ្នា ការទស្សនាពិព័រណ៍រូបភាពដែលបង្ហាញអំពីការធ្វើការហួសកម្លាំង និងគ្មានអាហារហូបគ្រប់គ្រាន់ និងការចាក់បញ្ចាំងវីដេអូឯកសារ។ ជាកិច្ចចាប់ផ្តើម លោក សៀង ស៊ីផាន ក្រុមប្រឹក្សាឃុំគគរ ថ្លែងអំពីសារសំខាន់នៃការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម និងការថែរក្សាមានសន្តិភាពបច្ចុប្បន្ន។ លោកក្រុមប្រឹក្សាឃុំបន្តរំឭកអំពីរឿងរ៉ាវដែលខ្លួនបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ដូចជា ការធ្វើការងារហួសកម្លាំង ការរស់នៅឃ្លាតឆ្ងាយពីគ្រួសារ ការអត់ឃ្លាន និងការកាប់សម្លាប់។ លោក តុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមអ្នករស់រាន

មានជីវិតពីរបបខ្មែរក្រហមនៅភូមិគគរ លើកឡើងថា ការប្រារព្ធពិធីបុណ្យដាលាននេះត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ ដែលអ្នកភូមិរស់នៅភូមិចំការសាមសិប ឃុំគគរ ចម្អិនអាហារ និងប្រគេនចង្ហាន់ដល់ព្រះសង្ឃ ដើម្បីសម្តែងការដឹងគុណដល់ម្ចាស់ទឹកម្ចាស់ដីថែរក្សាដំណាំស្រូវអស់រយៈពេល១ឆ្នាំ។ លោក គុង សុភា បានបន្ថែមថា «យើងមិនអាចបំភ្លេចដងដែរថា វាលស្រែនេះក៏ជាកន្លែងដែលមានមនុស្សស្លាប់ក្នុងរបបខ្មែរក្រហម ដូច្នេះយើងសូមឧទ្ទិសកុសលដល់ជនរងគ្រោះដែលបានស្លាប់ក្នុងពេលនោះ»។ ជាចុងបញ្ចប់ លោក ស៊ាង ចិន្តា នាំយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលជាសាខារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកឡើងពីសារសំខាន់នៃការចូលរួមរបស់សហគមន៍ទាំងមូលក្នុងការថែរក្សាការចងចាំអំពីរឿងរ៉ាវកើតឡើងក្នុងរបបខ្មែរក្រហម សម្រាប់ក្មេងជំនាន់ក្រោយ។ ពិធីបុណ្យដាលានបានចាប់ផ្តើមនៅវេលាម៉ោង៩ព្រឹក និងបញ្ចប់នៅវេលាម៉ោង៩យប់។







អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មកចូលរួមបុណ្យដាលាន និងទស្សនាពិព័រណ៍រូបថត។
( លី ដេវីត / មជ្ឈមណ្ឌលឯកសារកម្ពុជា )

# វេទិកាប្រវត្តិសាស្ត្រ និងសុខភាពសម្រាប់
## អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការនៅស្រុកកោះសូទិន

ទូច វណ្ណេត និង លី ដេវីត



នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំវេទិកាប្រវត្តិសាស្ត្រ និងសុខភាព សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ដោយមានការចូលរួមពីលោក ឡឿន គឹមសាន មេភូមិទី៨, អ្នកគ្រូ ម៉ៅ វណ្ណា តំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងឃុំកោះសូទិន រួមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០នាក់មកពីស្រុកកោះសូទិន និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។ (លី ដេវីត / មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំវេទិកាប្រវត្តិសាស្ត្រ និងសុខភាព សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិនដោយមានការចូលរួមពីលោក ឡឿន គឹមសាន មេភូមិទី៨, អ្នកគ្រូ ម៉ៅ វណ្ណា តំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងឃុំកោះសូទិន រួមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០នាក់មកពីស្រុកកោះសូទិន និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។ វេទិកានេះបានប្រព្រឹត្តទៅនៅក្រោយផ្ទះរបស់អ្នកភូមិទី៨ ឃុំកោះសូទិន ក្នុងគោលបំណងដើម្បីបង្កើតឲ្យមានឱកាសជួបសួរសុខទុក្ខ និងឈ្វេងយល់អំពីបទពិសោធន៍ជីវិតក្នុងរបបខ្មែរក្រហម និងស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ជាការចាប់ផ្តើម លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានថ្លែងបើកវេទិកាដោយបានរំឭកអំពីសារសំខាន់នៃការចងចាំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលប្រជាជនកម្ពុជាឆ្លងកាត់រាល់ទុក្ខវេទនា, ការ



នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំវេទិកាប្រវត្តិសាស្ត្រ និងសុខភាព សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ដោយមានការចូលរួមពីលោក ឡឿន គីមសាន មេភូមិទី៨, អ្នកគ្រូ ម៉ៅ វណ្ណា តំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងឃុំកោះសូទិនរួមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០នាក់មកពីស្រុកកោះសូទិន និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។ ( លី ដេវីត / មជ្ឈមណ្ឌលឯកសារកម្ពុជា )

បែកបាក់គ្រួសារ និងការបាត់បង់ជីវិត។ ផ្អែកតាមការស្រាវជ្រាវរបស់ក្រុមការងារ និងអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលបានជួបសួរសុខទុក្ខ និងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅស្រុកកោះសូទិនចំនួនប្រហែល៣០០នាក់ មានជនរងគ្រោះជាច្រើនត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់នៅវត្តចុងកោះ ខណៈពេលដែលអ្នកភូមិផ្សេងទៀតត្រូវបានបញ្ជូនទៅធ្វើការងារផ្សេងៗនៅក្នុងកងចល័ត នៅតាមការដ្ឋាន ក្នុងនោះគឺ ការដ្ឋានអ្ន័ត្រ។ អ្នករស់រានមានជីវិតនៅមូលដ្ឋានកោះសូទិននៅតែចងចាំមិនភ្លេចរាល់ទុក្ខវេទនា និងការបាត់បង់សមាជិកគ្រួសាររបស់ខ្លួនក្នុងរបបខ្មែរក្រហម។ អ្នករស់រានមានជីវិតភាគច្រើនបន្តទទួលរងផលប៉ះពាល់ពីរបបខ្មែរក្រហម ទាំងសុខភាពរាងកាយ និងសុខភាពផ្លូវចិត្ត។

ជាកិច្ចបន្តលោកសោមសេរីសមាជិកក្រុមប្រឹក្សាឃុំកោះសូទិនបានថ្លែងចំណាប់អារម្មណ៍ថា វេទិកានេះគឺល្អដែលក្រុមការងារបានចុះមកជួប និងសួរសុខទុក្ខអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានកោះសូទិន ដើម្បីដឹងអំពីបទពិសោធន៍ក្នុងរបបខ្មែរក្រហម និងស្ថានភាពសុខភាព ក៏ដូចជាការផ្តោតការយកចិត្តទុកដាក់ដល់ជនពិការក្នុងមូលដ្ឋាននេះ។

បន្ទាប់មក អ្នកស្រី សូ ហ្វារីណា នាយិការងមជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកឡើងអំពីគម្រោងប្រវត្តិសាស្ត្រ និងសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលអ្នកស្ម័គ្រចិត្តកម្ពុជាបានចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទូទាំងប្រទេស។ ក្នុងជំនួបវេទិកានេះផងដែរ ក្រុមការងារនឹងផ្តោតទៅលើការចែករំលែកបទពិសោធន៍ជីវិតរបស់អ៊ំប្រុសអ៊ំស្រីក្នុងរបបខ្មែរក្រហម ស្ថានភាពសុខភាព និងតម្រូវការរបស់ជនពិការ។

អ្នកគ្រូ ម៉ៅ វណ្ណា តំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានកោះសូទិនបានថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចុះមកជួបផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិទី៨នេះ។ អ្នកគ្រូ ម៉ៅ វណ្ណា បន្តថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅមូលដ្ឋាននេះ ដែលមានអាយុកាន់តែច្រើន និងសុខភាពកាន់តែខ្សោយ នៅតែចងចាំអំពី



នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំវេទិកាប្រវត្តិសាស្ត្រ និងសុខភាព សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ដោយមានការចូលរួមពីលោក ឡឿន គឹមសាន មេភូមិទី៨, អ្នកគ្រូ ម៉ៅ វណ្ណា តំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងឃុំកោះសូទិន រួមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០នាក់មកពីស្រុកកោះសូទិន និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។ (លី ដេវីត / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ការរងទុក្ខវេទនា និងការស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ អ្នកគ្រូ ម៉ៅ វណ្ណា បានរំឭកអំពីរឿងរ៉ាវរបស់គាត់ដែលស្ទើរតែត្រូវបានយកទៅសម្លាប់ និងការសម្លាប់របស់ខ្មែរក្រហមទៅលើគ្រួសាររបស់គាត់ ដោយបានចាប់ចង និងសម្លាប់ទម្លាក់ចូលក្នុងទឹកទន្លេ។ អ្នកគ្រូ ម៉ៅ វណ្ណា បានបាត់បង់សមាជិកគ្រួសារជាទីស្រឡាញ់ រួមមាន ឪពុកម្តាយ និងបងប្អូនប្រុសស្រីចំនួន៨នាក់។ ជាចុងក្រោយ អ្នកគ្រូ ម៉ៅ វណ្ណា ក៏បានលើកឡើងផងដែរអំពីស្ថានភាពចុះខ្សោយរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រួមទាំងគាត់ផ្ទាល់ និងសារសំខាន់នៃការបន្តនិយាយប្រាប់ក្មេងជំនាន់ក្រោយអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងមូលដ្ឋានក្នុងរបបខ្មែរក្រហម។

អ៊ំស្រី ស៊ុន ហ៊ឹម អាយុ៧៩ឆ្នាំ រស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន មានកូនប្រុសស្រីសរុបចំនួន៦នាក់ ប៉ុន្តែជាអកុសល កូនប្រុសម្នាក់របស់អ៊ំស្រីឈ្មោះ លាង បច្ចុប្បន្នអាយុ៤៥ឆ្នាំ កើតមកមិនគ្រប់ទឹកនៅឆ្នាំ១៩៨០។ នៅឆ្នាំ១៩៧៥ អ៊ំស្រី ស៊ុន ហ៊ឹម ចាប់ផ្តើមធ្វើការនៅកងប្រវាស់ដៃដើម្បីជួយច្រូតស្រូវ និងប្រមូលផលដំណាំចែកគ្នាហូប។ នៅពេលដែលសហករណ៍ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៦ អ្នកភូមិត្រូវបានដាក់ចូលធ្វើការនៅតាមកងចល័ត នៅតាមការដ្ឋានរែកដីលើកទំនប់នៅចុងកោះ។ អ៊ំស្រី ស៊ុន ហ៊ឹម ដែលនៅពេលនោះមានអាយុប្រហែល ៣០ឆ្នាំ ត្រូវបានចាត់តាំងឲ្យធ្វើការនៅកងចល័តនារី ដោយត្រូវងើបពីម៉ោង៥ព្រឹក និងចេញទៅប្រជុំជួរប្រហែលរយៈពេលកន្លះម៉ោងដើម្បីប្រាប់ពីការចាត់ចែងឲ្យទៅធ្វើការតាមគោលដៅកំណត់។ អ៊ំស្រី ហ៊ឹម ត្រូវធ្វើការចាប់ពីម៉ោង៦ដល់ម៉ោង១១ព្រឹកទើបបានឈប់សម្រាកហូបបបរថ្ងៃត្រង់ និងបន្តធ្វើការងារចាប់ពីម៉ោង១ដល់ម៉ោង៥ល្ងាច។ នៅឆ្នាំ១៩៧៧ អ៊ំស្រី ស៊ុន ហ៊ឹម និងគ្រួសារ ត្រូវបានខ្មែរក្រហមជម្លៀសទៅល្វាឯមដោយជិះទូក។ អ៊ំស្រី ស៊ុន ហ៊ឹម បន្តធ្វើការទាំងគ្មានអាហារហូបគ្រប់គ្រាន់ និងពេលសម្រាកនៅកងចល័តរួមមានដកស្ទូង និងច្រូតស្រូវរហូតដល់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានចូលមករំដោះប្រជាជននៅដើមឆ្នាំ១៩៧៩។ អ៊ំស្រី ស៊ុន ហ៊ឹម បានរួចផុតពីការធ្វើការងារហួសកម្លាំង និងសេចក្តីអត់ឃ្លាននៅពេលនោះ។ នៅដើមឆ្នាំ១៩៨០ អ៊ំស្រី ស៊ុន ហ៊ឹម បានបង្កើតកូនប្រុសម្នាក់ ឈ្មោះ ឈុនលាង ដែលមានជំងឺខ្សោយបញ្ញាតាំងពីកំណើត។


















# បណ្ណាល័យមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម

បណ្ណាល័យមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូនសិស្ស និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ អង្គការក្រៅរដ្ឋាភិបាល និងបុគ្គល ទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រ សាលាក្តីខ្មែរក្រហម។

បណ្ណាល័យមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម គឺជាកន្លែងប្រមូលផ្តុំ និងតម្កល់ឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅបណ្ណាល័យមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម មាន៥ប្រភេទ។ ប្រភេទឯកសារទីមួយ គឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបី គឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួន គឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំ គឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈបណ្ណាល័យមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម សាធារណជនអាចមកស្រាវជ្រាវឯកសារ ទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។



## បណ្ណាល័យមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម

មានទីតាំងស្ថិតនៅផ្លូវលេខ៤៧ ផ្ទះលេខ១៣១ ភូមិបឹងកុក១ សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖00ព្រឹក ដល់ម៉ោង ១២៖00 និងពេលរសៀលពីម៉ោង ២៖00 ដល់ម៉ោង ៥៖00។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣៦១១ ឬ អ៊ីម៉ែល ៖ truthchenda.s@ dccam.org ។

សូមអរគុណ!











# សិស្សវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន សង្កើប ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍

## ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ៖ «សង្គ្រាមដែលកងទ័ពរំដោះខ្មែរក្រហមប្រយុទ្ធជាមួយទាហាន លន់ នល់»

*ទូច វណ្ណេត និង លី ដេវីត*









នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ សិស្សានុសិស្សវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន សង្កើប ថ្នាក់វិទ្យាសាស្ត្រពិត ចំនួន៥៥នាក់ បានមកចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ សិស្សានុសិស្សវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន សង្កើប ថ្នាក់វិទ្យាសាស្ត្រពិត ចំនួន៥៥នាក់បានមកចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ វេទិកាថ្នាក់រៀននេះធ្វើឡើងក្នុងគោលបំណងបង្កើនចំណេះដឹងដល់សិស្សានុសិស្សស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជានាពេលអនាគត។

ជាកិច្ចចាប់ផ្ដើម លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ចាប់ផ្ដើមធ្វើបទបង្ហាញរបស់ខ្លួនស្ដីពីប្រវត្តិសាស្ត្រខ្មែរក្រហម ដោយបានផ្ដោតទៅលើព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម រួមមាន ការធ្វើរដ្ឋប្រហាររបស់ លន់ នល់, ការផ្ទុះសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម, ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង និងទីប្រជុំជន និងការកាប់សម្លាប់ទៅលើប្រជាជន។ ជាចុងក្រោយលោក ផេង ពង្សរ៉ាស៊ី ពន្យល់បន្ថែមទៅលើនិយមន័យ និងវិធីសាស្ត្រទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងអំពើប្រល័យពូជសាសន៍។

បន្ទាប់ពីការធ្វើបទបង្ហាញរបស់វាគ្មិន បានបញ្ចប់, លោក ស៊ាង ចិន្ដា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តដឹកនាំកិច្ចពិភាក្សាទៅលើប្រធានបទការផ្ទុះឡើងសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ មិនយូរប៉ុន្មានបន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើង។ កងទ័ពរំដោះខ្មែរក្រហមបានធ្វើសង្គ្រាមប្រឆាំងទាហាន លន់ នល់។ សង្គ្រាមដែលកងទ័ពរំដោះខ្មែរក្រហមបានប្រយុទ្ធជាមួយទាហាន លន់ នល់ គឺរួមមាន៖ សង្គ្រាមផ្លូវគោក សង្គ្រាមផ្លូវទឹក និងសង្គ្រាមប្រជាជន។ នៅពាក់កណ្ដាលឆ្នាំ១៩៧០ កងទ័ពរំដោះខ្មែរក្រហមចូលមកដល់ភូមិសាស្ត្រនានានៅក្នុងខេត្តកំពង់ចាម។ ទាហាន លន់ នល់ បានប្រើប្រាស់យន្តហោះទម្លាក់គ្រាប់បែកនៅភូមិសាស្ត្រណាដែលមានវត្តមានកងទ័ពរំដោះខ្មែរក្រហម ឈរជើង។ កងទ័ពរំដោះខ្មែរក្រហមអាចបានត្រឹមតែព្យាយាមបាញ់កាំភ្លើងពីដីសំដៅទៅលើយន្តហោះទម្លាក់គ្រាប់បែករបស់ទាហាន លន់ នល់ និងបានដកកងកម្លាំងរបស់ខ្លួនចេញពីភូមិសាស្ត្រទម្លាក់គ្រាប់បែក។ បន្ទាប់ពីការទម្លាក់គ្រាប់បែក ទាហានថ្មើរជើង លន់ នល់ ត្រូវបានបញ្ជូនទៅកាន់ភូមិសាស្ត្រទម្លាក់គ្រាប់បែក និងបន្តឈរជើងនៅទីនោះ។

ចន្លោះពីឆ្នាំ១៩៧១ និង១៩៧២ កងទ័ពរំដោះខ្មែរក្រហមធ្វើសង្គ្រាមផ្លូវគោកជាមួយ ទាហាន លន់ នល់ ដោយបានបើកការវាយប្រហារទៅលើបន្ទាយ លន់ នល់ និងរំដោះតំបន់ផ្សេងៗជាបន្តបន្ទាប់។ ចាប់តាំងពីឆ្នាំ១៩៧៣ ទាហាន លន់ នល់ ត្រូវបានដាក់ឲ្យឈរជើងនៅព្រំប្រទល់ទីរួមខេត្តកំពង់ចាម ដើម្បីត្រៀមប្រយុទ្ធតទល់ជាមួយកងទ័ពរំដោះខ្មែរក្រហមដែលបានដាក់កម្លាំងឡោមព័ទ្ធទីរួមខេត្ត។ ដោយមិនអាចឆ្លងកាត់តំបន់រំដោះតាមផ្លូវគោកបាន ទាហានលន់ នល់ ប្រើប្រាស់ផ្លូវទឹកតាមដងទន្លេមេគង្គ ដើម្បីដឹកសម្ភារសឹក និងស្បៀងចូលទៅទីរួមខេត្តកំពង់ចាម។ កងទ័ពរំដោះខ្មែរក្រហមតែងតែបើកការវាយប្រហារដោយបានបណ្ដែតគ្រាប់បែកបង្កើកាត់ទន្លេ និងបាញ់ចេញពីច្រាំងទន្លេ។ កងទ័ពរំដោះខ្មែរក្រហមធ្វើសង្គ្រាមផ្លូវទឹកជាមួយទាហានជើងទឹក លន់ នល់ រហូតដល់ឆ្នាំ១៩៧៥។ បន្ថែមលើបទបង្ហាញដែលលោក ស៊ាង ចិន្ដា លើកឡើងខាងលើនេះ កងទ័ពរំដោះខ្មែរក្រហមក៏បានធ្វើសង្គ្រាមប្រជាជនក្នុងគោលបំណងរក្សាការគាំទ្ររបស់ប្រជាជនរស់នៅក្នុងមូលដ្ឋានចំពោះការធ្វើសង្គ្រាមយកឈ្នះទាហាន លន់ នល់។



នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ សិស្សានុសិស្សវិទ្យាល័យសម្ដេចតេជោ ហ៊ុន សែន សង្កើប ថ្នាក់វិទ្យាសាស្ត្រពិត ចំនួន ៥៥នាក់ បានមកចូលរួមវេទិកាថ្នាក់រៀនស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាចុងបញ្ចប់នៃវេទិកាថ្នាក់រៀនចុងសប្តាហ៍នេះ សិស្សទាំងអស់បានចុះទស្សនកិច្ចសិក្សាទៅកាន់ចេតិយរំពុកសម្រាប់សហគមន៍ និងជួបសន្ទនាដោយផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ នៅពេលមកដល់ទីតាំងចេតិយរំពុកសម្រាប់សហគមន៍ លោក តុង សុភា និងអ្នកស្រី ប៊ុន ឈួមឡោម អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទទួលស្វាគមន៍សិស្សានុសិស្ស និងនិយាយប្រាប់អំពីបទពិសោធន៍ និងការបាត់បង់សាច់ញាតិក្នុងរបបខ្មែរក្រហម។

បន្ទាប់ពីវេទិកាថ្នាក់រៀនបានបញ្ចប់ យុវសិស្សចូលរួមបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖

សិស្ស **ធីម ស្រីពីន** រៀនថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្រ្តពិតនៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប បង្ហាញទស្សនយល់ឃើញរបស់ខ្លួនថា «ខ្ញុំសប្បាយចិត្តនៅពេលមកដល់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ខ្ញុំយល់ដឹងបន្ថែមអំពីប្រវត្តិសាស្រ្តខ្មែរក្រហម រួមមាន ប្រវត្តិមេដឹកនាំខ្មែរក្រហម, ការធ្វើការងាររហូតសកម្លាំង, ការបែកបាក់គ្រួសារ និងការបាត់បង់សាច់ញាតិ។ ខ្ញុំនឹងយកចំណេះដឹងដែលទទួលបានពីវេទិកាទៅចែករំលែកជាមួយមិត្តភក្តិ និងសាកសួរយាយអំពីបទពិសោធន៍របស់គាត់ក្នុងរបបខ្មែរក្រហម»។

សិស្ស **នៅ ស្រីស** រៀនថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្រ្តពិតនៃវិទ្យាល័យសម្តេចតេជោ ហ៊ុនសែន សង្កើប លើកឡើងថា «វេទិកាថ្នាក់រៀនចុងសប្តាហ៍គឺល្អសម្រាប់ខ្ញុំដែលកំពុងរៀនថ្នាក់ទី១២ និងត្រៀមប្រឡង ពីព្រោះខ្ញុំទទួលបានចំណេះដឹងច្រើនបន្ថែមទៀតលើមុខវិជ្ជាដែលខ្ញុំបានរៀននៅក្នុងថ្នាក់»។

សិស្ស **ខួន សុភា** រៀនថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្រ្តពិតនៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប និយាយថា «ការឃើញរូបភាព ការស្តាប់បទបង្ហាញរបស់លោកគ្រូ ការស្តាប់បទពិសោធន៍របស់អ៊ំៗដែលឆ្លងកាត់របបខ្មែរក្រហម និងការចុះទៅដល់ទីតាំងចេតិយរំពុក ធ្វើឲ្យខ្ញុំយល់ដឹងអំពីទុក្ខលំបាក និងវិនាសកម្មបន្សល់ទុកពីរបបខ្មែរក្រហម។ ខ្ញុំនឹងនាំយកចំណេះដឹងដែលខ្ញុំទទួលបានពីវេទិកានេះ ទៅប្រាប់មិត្តភក្តិផ្សេងទៀតដែលមិនបានមកចូលរួមវេទិកានេះ»។







នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ សិស្សានុសិស្សវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប ថ្នាក់វិទ្យាសាស្រ្តពិត ចំនួន ៥៥នាក់ បានមកចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# កូប ហ្វាទីម៉ះ ៖ របបខ្មែរក្រហមធ្វើឱ្យខ្ញុំក្លាយជាកូនកំព្រា និងជាស្ត្រីមេម៉ាយ

**មីន សាណាស់**

«ខ្ញុំមិនបោលកីតម្បាញសូត្រទេ ព្រោះនេះជាការងារដែលខ្ញុំស្រឡាញ់ចូលចិត្តតាំងពីអាយុ១៣ឆ្នាំ ហើយវាជាផ្នែកមួយដែលអាចឲ្យខ្ញុំរកប្រាក់ឲ្យកូនខ្ញុំរៀនសូត្រក្លាយជាគ្រូពេទ្យមួយរូបនៅក្នុងភូមិ» នេះគឺជាការលើកឡើងរបស់ស្ត្រីជនជាតិចាមម្នាក់។ គាត់រៀបរាប់បន្តថា «ខ្ញុំឈ្មោះ កូប ហ្វាទីម៉ះ ភេទស្រី អាយុ៦៨ឆ្នាំ មានទីកន្លែងកំណើតនៅឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ហើយបច្ចុប្បន្នរស់នៅក្នុងឃុំដដែល។ សព្វថ្ងៃខ្ញុំប្រកបមុខរបរត្បាញសំពត់សូត្រដូចម្ដាយរបស់ខ្ញុំដែរ។ ឪពុកខ្ញុំឈ្មោះ កូប គឺជាអ្នកនេសាទត្រី។ ឪពុកម្ដាយរបស់ខ្ញុំស្លាប់ក្នុងរបបខ្មែរក្រហម ដោយសារការអត់ឃ្លាន។




កូប ហ្វាទីម៉ះ អាយុ៦៨ឆ្នាំ រស់នៅឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំរៀបការជាមួយប្ដីឈ្មោះ អះម៉ាត់ ប្រហែលជាឆ្នាំ១៩៧៣ ហើយកាលនោះខ្ញុំគឺជាកូនក្រមុំស្លៀកសំពត់សូត្រគោមផ្កាកន្ទេល ពណ៌បៃតងយ៉ាងស្រស់ស្អាត។ នៅឆ្នាំ១៩៧៤ ខ្ញុំសម្រាលបានកូនប្រុសម្នាក់។ នៅឆ្នាំ១៩៧៥ កូនរបស់ខ្ញុំទើបតែចេះវារ ខ្មែរក្រហមក៏ជម្លៀសគ្រួសារខ្ញុំនិងអ្នកភូមិឯទៀតតាមរថភ្លើងទៅកាន់ខេត្តបាត់ដំបង។ គ្រួសារខ្ញុំចុះនៅចំណុចភូមិក្បាលថ្នល់ ស្រុកសង្កែ ខេត្តបាត់ដំបង។ មូលហេតុដែលនាំឲ្យមានការជម្លៀសគឺយោធាខ្មែរក្រហមប្រាប់ថា នាំអ្នកភូមិឲ្យទៅរស់នៅប្រទេសម៉ាឡេស៊ី ទើបអ្នកទាំងអស់គ្នាចាកចេញពីភូមិ។ រថភ្លើងបរមកដល់ខេត្តបាត់ដំបងភ្លាម កម្មាភិបាលខ្មែរក្រហមចាត់តាំងឲ្យប្រជាជនចុះធ្វើស្រែ និងដកស្ទូង។ ចំណែកប្ដីខ្ញុំត្រូវចុះទៅភ្ជួរស្រែ។ ក្រោយមកមិនទាន់បានមួយឆ្នាំ ស្រាប់តែឪពុកម្ដាយខ្ញុំធ្លាក់ខ្លួនឈឺ និងស្លាប់ដោយសារការអត់ឃ្លាន។ មួយខែក្រោយមកទៀតប្ដីខ្ញុំដួលសន្លប់បាត់ស្មារតីបន្ទាប់ពីត្រឡប់មកពីភ្ជួរស្រែរួចបញ្ជូនទៅពេទ្យស្រុក។ ពេទ្យបានចាក់ថ្នាំមួយម្ជុលឲ្យគាត់ហើយគាត់ក៏ស្លាប់ទៅ។ ខ្ញុំគិតថាពេទ្យមានចេតនាចាក់ថ្នាំសម្លាប់ប្ដីខ្ញុំ បុម្យ៉ាងទៀតមកពីពេទ្យទាំងនោះមិនមានចំណេះដឹងច្បាស់លាស់។ ការបាត់បង់ឪពុកម្ដាយ និងប្ដីរបស់ខ្ញុំមិនធ្វើឲ្យខ្ញុំខូចចិត្តឬយំសោកតទៀតឡើយ ព្រោះខ្ញុំគិតថាពួកគាត់បានសុខហើយ ពួកគាត់លែងវេទនា និងរស់នៅក្នុងរបបដ៏ខ្មៅងងឹតទាំងអត់ឃ្លានដូចខ្ញុំឡើយ។ ខ្ញុំត្រូវប្រឹងរស់ដើម្បីមើលថែកូនប្រុស

និងប្អូនៗ។ ពេលថ្ងៃខ្ញុំប្រឹងធ្វើការ ពេលយប់ខ្ញុំចេញទៅលួចស្រូវ និងពោតមកស្ងោរឲ្យកូននិងប្អូនៗហូប។ ពេលខ្លះខ្ញុំលួចបាន ពេលខ្លះក៏លួចមិនបាន។ របបខ្មែរក្រហមធ្វើឲ្យខ្ញុំក្លាយជាកូនកំព្រា និងជាស្ត្រីមេម៉ាយមកដល់សព្វថ្ងៃ។

នៅដើមឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយចូលមក និងបានឮសំឡេងបំផ្ទុះគ្រាប់បែក។ ពេលនោះខ្ញុំ និងប្រជាជនឯទៀតកំពុងទូលកណ្ដាប់ស្រូវយកទៅដាក់នៅទីលានបោកបែន ប៉ុន្តែកងកម្លាំងវៀតណាមដេញឲ្យអ្នកភូមិនិងខ្ញុំនាំគ្នារត់ចូលទៅក្នុងទីរួមខេត្តបាត់ដំបងវិញ។ ការធ្វើដំណើរទៅទីក្រុងបាត់ដំបង គ្រួសារខ្ញុំលំបាកជាងអ្នកផ្សេងទៀត ដោយសារប្អូនប្រុសខ្ញុំម្នាក់ស្វិតជើង ហេតុនេះពិបាកក្នុងការធ្វើដំណើរ។ ដើម្បីឲ្យទាន់គ្រួសារឯទៀត ខ្ញុំមានតែឲ្យប្អូនចុះទៅក្នុងប្រឡាយស្របជាមួយផ្លូវ រួចហែលរហូតទាល់តែមានរទេះគោណាដែលខ្ញុំអាចសុំឲ្យប្អូនខ្ញុំជិះជាមួយបាន។ ខ្ញុំអាណិតប្អូនខ្ញុំណាស់ ប៉ុន្តែមិនអាចជួយគាត់បាន ព្រោះខ្ញុំគ្មានកម្លាំងសែង។ មកដល់ទីរួមក្រុងបាត់ដំបង ខ្ញុំរៀបចំកន្លែងស្នាក់នៅ ហើយបានជួបបងប្អូន និងពូមីងមួយចំនួន។ នៅពេលរស់នៅជុំគ្នាក្នុងក្រុងបាត់ដំបង យើងទទួលដំណឹងថាជំរំជនភៀសខ្លួននៅក្នុងប្រទេសថៃ អាចបញ្ជូនជនភៀសខ្លួនខ្មែរឲ្យទៅកាន់ប្រទេសអាមេរិក ម៉ាឡេស៊ី និងអូស្ត្រាលី។ គ្រួសារខ្ញុំនិងអ្នកភូមិផ្សេងទៀតបានធ្វើដំណើរបន្តទៅកាន់ជំរំដែលមានឈ្មោះថា ណងចាន់។ នៅជំរំណងចាន់ខ្ញុំបានទទួលរបបអាហារបរិភោគគ្រប់គ្រាន់ ហើយរស់នៅក្នុងជំរំបានរយៈពេលកន្លះខែ។ ប៉ុន្តែក្រោយមក ខាងប្រទេសថៃដឹកយើងមកចោលនៅលើភ្នំដងរែក។ បន្ទាប់ពីរួចជីវិតពីភ្នំដងរែក គ្រួសារខ្ញុំធ្វើដំណើរដោយថ្មើរជើងរយៈពេលជាងមួយខែ ទម្រាំបានមកដល់ស្រុកកំណើត។ ពេលមកដល់ស្រុកកំណើតខ្ញុំចាប់ផ្ដើម យកចំណេះដឹងពីម្ដាយរបស់ខ្ញុំមកប្រើប្រាស់ ដោយដំបូងខ្ញុំដើរទៅសុំចិននៅផ្សារ ដើម្បីស៊ីឈ្នួលចាក់មងទាំងថ្ងៃទាំងយប់ ព្រោះខ្ញុំចង់សន្សំលុយទុកសង់ផ្ទះ និងទិញសម្ភារផ្សេងៗ។

ប្រហែលឆ្នាំ១៩៨៦ បងប្អូនខ្មែរនៅខាងព្រៃល្វា ជួលខ្ញុំឲ្យត្បាញសំពត់សូត្រ ព្រមទាំងផ្ដល់ជាគ្រឿងតម្បាញទាំងស្រុង។ ខ្ញុំសម្រេចចិត្តត្បាញឡើងវិញ ព្រោះវាជាការងារដែលខ្ញុំស្រឡាញ់តាំងពីអាយុ១៣ឆ្នាំ។ ខ្ញុំចាប់ផ្ដើមចងគោមដែលខ្ញុំស្រឡាញ់ពីមុន ដូចជា គោមផ្កាកន្ទុល គោមជណ្ដើរបារាំង គោមក្ងោកសម័យ គោមដបតែ គោមសំរោង និងគោមខុងមិញជាដើម។ សម្រាប់ការជ្រលក់ពណ៌គឺមានតែពណ៌លឿង ខ្មៅ ក្រហម បៃតង និងខៀវ។ ពណ៌បៃតង និងខៀវគឺពេញនិយមណាស់ចំពោះកូនក្រមុំថ្ងៃរៀបការ។ ខ្ញុំត្បាញសព្វថ្ងៃនេះ គឺដើម្បីជាការថែរក្សាប្រពៃណី ចំណេះជំនាញដែលដូនតាបន្សល់ទុក។ ខ្ញុំត្បាញក៏ចាត់ទុកជាចលនាហាត់ប្រាណមួយដែរ។ ខ្ញុំសង្ឃឹមថាទីផ្សារសូត្រនិងងើបឡើងវិញបន្ទាប់ពីជំងឺកូវីដ ១៩ ផុតរលត់ទៅ។



ឯកអគ្គរដ្ឋទូតតួកគី អាយដា អ៊ុនលូ (Ayda Ünlü) ទស្សនកិច្ចការប្រកបរបរត្បាញសូត្ររបស់ជនជាតិចាមនៅស្រុកកោះសូទិន ខេត្តកំពង់ចាម ដែលជាមុខរបរប្រពៃណីបន្សល់ទុកពីដូនតានៅក្នុងសហគន៍ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ៖

កញ្ញា ប៊ូ សំណាង គឺជាអត្តពលិកក្នុងវិញ្ញាសារត់ចម្ងាយ ៥០០០ម៉ែត្រ កី ឡាអាស៊ីអាគ្នេយ៍លើកទី៣២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

( Đức Đồng - VnExpress / មជ្ឈមណ្ឌលឯកសារកម្ពុជា )

រូបក្របក្រោយ៖

និមិត្តសញ្ញាអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា។

( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )

អង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា

DOCUMENTATION CENTER OF CAMBODIA ORGANIZATION


**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ១២ ៨៨២ ៥០៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 12 882 505 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Special Issue 2023 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.